ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# សទ្ទានុក្រម
# វេជ្ជសាស្ត្រ និង កសិកម្ម
## ខ្មែរ-អង់គ្លេស-បារាំង

# LEXICON
# OF
# MEDICINE AND AGRICULTURE
## Khmer-English-French


ក្រុមប្រឹក្សាជាតិភាសាខ្មែរ

គណៈកម្មការជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

គណៈកម្មការសុខាភិបាល

គណៈកម្មការកសិកម្ម



សីហា ២០១៥



អាសយដ្ឋាន: មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់កាកាប, ខណ្ឌពោធិ៍សែនជ័យ, រាជធានីភ្នំពេញ

ទូរសព្ទដៃ: (៨៥៥) ១២ ៩១១ ៣៥៧ / (៨៥៥) ១២ ៩០៦ ៥៨៥, អ៊ីមែល: info@nckl.gov.kh, គេហទំព័រ: www.nckl.gov.kh

# បុព្វកថា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) មានភារកិច្ចស្វែងរកឯកភាពឱ្យភាសាខ្មែរ ទាំងខាងអក្ខរាវិរុទ្ធ ទាំងខាងអំណាននិងទាំងខាងពាក្យពេចន៍។ ទោះក្នុងវេជ្ជសាស្ត្រក្ដី ក្នុងកសិកម្មក្ដី ឬ ក្នុងវិទ្យាសាស្ត្រ បច្ចេកវិទ្យាផ្សេងទៀតក្ដី តែងតែមានពាក្យប្រែជាខ្មែរផងនិងពាក្យកម្ចីផង។ ពាក្យទាំងនេះសុទ្ធតែត្រូវបាន ក.ជ.ភ.ខ. សម្រួលអក្ខរាវិរុទ្ធ ដោយយកលំនាំតាមអក្ខរាវិរុទ្ធនៃវចនានុក្រមរៀបរៀងដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥។

វាក្យសព្ទវេជ្ជសាស្ត្រនិងវាក្យសព្ទកសិកម្ម សម្បូរពាក្យកម្ចីពីភាសាបារាំង។ ក្រៅពីពាក្យខ្មែរដែលគេបានប្រើយូរមកហើយក្នុងវិស័យវេជ្ជសាស្ត្រនិងវិស័យកសិកម្ម ក.ជ.ភ.ខ.បានអនុម័តពាក្យជាច្រើនដែលក្នុងនោះមានពាក្យបកប្រែផងនិងពាក្យកម្ចីផង។

សទ្ទានុក្រមវេជ្ជសាស្ត្រនិងកសិកម្មនេះ ជាឧបករណ៍ថ្នាក់ជាតិសម្រាប់ជួយសាធារណជនខ្មែរជាពិសេសអ្នកជាប់ពាក់ព័ន្ធនឹងវិជ្ជានេះ ឱ្យប្រើពាក្យឱ្យបានដូចគ្នា។ ការប្រើពាក្យដូចគ្នា ជាការរួមចំណែកដ៏ធំធេងឱ្យភាសាខ្មែរមានឯកភាព ពីព្រោះទាំងពាក្យប្រែជាខ្មែរ ទាំងពាក្យកម្ចីសុទ្ធសាធ នឹងត្រូវក្លាយជាពាក្យខ្មែរ នៅពេលអនាគត។

សូមអ្នកស្រឡាញ់ភាសាជាតិជួយសហការប្រើពាក្យតាមសទ្ទានុក្រមនេះ ដើម្បីឱ្យភាសាយើងដើរឆ្ពោះទៅរកឯកភាពដូចតន្តិភាសាក្នុងលោកដែរ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និង ជាប្រធានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិភាសាជាតិ**

បណ្ឌិតសភាចារ្យ **សុខ អាន**

# អារម្ភកថា

ពាក្យទាក់ទងនឹងវេជ្ជសាស្ត្រនិងកសិកម្ម ដែលមានក្នុងសទ្ទានុក្រមនេះ ត្រូវបានបោះពុម្ពផ្សាយតាមព្រឹត្តិបត្រលេខ៣ លេខ៤និងលេខ៦ រួចមកហើយ ប៉ុន្តែព្រឹត្តិបត្រទាំងនោះ ត្រូវបានចែកផ្សព្វផ្សាយតែក្នុងមជ្ឈដ្ឋានថ្នាក់ដឹកនាំ ក្រសួងនានា មន្ទីរអប់រំ ការិយាល័យអប់រំស្រុក/ក្រុង/ខណ្ឌ នាយកសាលា...។ ម្យ៉ាងទៀត ដើម្បីឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែរ (ក.ជ.ភ.ខ.) ងាយអនុម័តពាក្យទាំងនេះ គណៈកម្មការសុខាភិបាលនិងគណៈកម្មការកសិកម្ម ត្រូវផ្តល់ពាក្យគន្លឹះជាមុន ទោះពាក្យគន្លឹះនោះកើតចេញពីព្យញ្ជនៈណាក៏ដោយ ដើម្បីឱ្យងាយពន្យល់ពាក្យពាក់ព័ន្ធ។ ផ្ទុយពីពាក្យដែលចុះផ្សាយតាមព្រឹត្តិបត្រ ពាក្យដែលចុះផ្សាយក្នុងសទ្ទានុក្រមនេះ ត្រូវបានរៀបតាមលំដាប់អក្ខរក្រម ព្រមទាំងដាក់បច្ចេកសព្ទវេជ្ជសាស្ត្រនិងបច្ចេកសព្ទកសិកម្មដោយឡែកពីគ្នា (បច្ចេកសព្ទវេជ្ជសាស្ត្រមានចំនួន២២៩ពាក្យ និង បច្ចេកសព្ទកសិកម្មមានចំនួន១៦១ពាក្យ)។

សទ្ទានុក្រមជាមធ្យោបាយផ្សព្វផ្សាយទី៣របស់យើង បន្ទាប់ពីព្រឹត្តិបត្រនិងគេហទំព័រ ហើយយើងសង្ឃឹមថា មធ្យោបាយនេះអាចផ្សព្វផ្សាយបានទូលំទូលាយជាងមធ្យោបាយមុនៗ នៅក្នុងប្រទេសកម្ពុជា។

ក.ជ.ភ.ខ. មិនអាចដំណើរការបានទេ បើគ្មានការគាំទ្រជាថវិកាពីសំណាក់សម្តេច បណ្ឌិតសភាចារ្យ អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាគុ-គណនៃ ក.ជ.ភ.ខ. តាមរយៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានកិត្តិយសនៃ ក.ជ.ភ.ខ.។

អាស្រ័យហេតុនេះ ក្នុងនាម ក.ជ.ភ.ខ.ទាំងមូល ខ្ញុំបាទសូមថ្លែងអំណរគុណព្រមទាំងកតញ្ញុតាយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំខាងលើ ដែលជាអាណាព្យាបាលនៃ ក.ជ.ភ.ខ.យើង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

រាជធានីភ្នំពេញ, ថ្ងៃ សុក្រ ទី ៣១ ខែ កក្កដា ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ**

បណ្ឌិតសភាចារ្យ **ច្រាំ ម៉ល់**

# សមាជិកគណៈកម្មការបច្ចេកសព្ទ
# ជីវសាស្ត្រ វេជ្ជសាស្ត្រនិងកសិកម្ម

| | | |
|---|---|---|
| ១- | ឯកឧត្តមសាស្ត្រាចារ្យឱសថបណ្ឌិត ប៉ែន ប៊ូនពីវ | ប្រធាន |
| ២- | លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត នុត សម្បត្តិ | អនុប្រធាន |
| ៣- | ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ | សមាជិក |
| ៤- | លោកសាស្ត្រាចារ្យបណ្ឌិត ស៊ុន សូត | សមាជិក |
| ៥- | លោក រស់ ផាន្នី | សមាជិក |
| ៦- | លោក វង្ស មេង | សមាជិក |

**រៀបចំបោះពុម្ពផ្សាយដោយ ៖**

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# សមាជិក
# គណៈកម្មការសុខាភិបាល

១-ឯកឧត្តមបណ្ឌិតសភាចារ្យ សំ សោភាន់ ប្រធាន
២-ឯកឧត្តមសាស្ត្រាចារ្យមហាបរិញ្ញា ប៉ែន ប៊ូនពីវ អនុប្រធាន
៣-លោកបណ្ឌិត ឈុំ ភិតលន់ សមាជិក
៤-លោកបណ្ឌិត នុត សម្បត្តិ សមាជិក
៥-លោកបណ្ឌិត តាំង ស៊ិន សមាជិក
៦-លោក អាត ផារ៉ា សមាជិក
៧-លោកជំទាវ ឡុង ថុល សមាជិក
៨-លោក ជុំ គឹមរ៉ុង សមាជិក
៩-សាស្ត្រាចារ្យជំនួយវេជ្ជបណ្ឌិត ស្វាយ កាម៉ុល សមាជិក
១០-លោក ឃឹម វិច្ឆិកា ជំនួយខាងភាសា

## រៀបចំបោះពុម្ពផ្សាយដោយ ៖

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# សមាជិក
# គណៈកម្មការកសិកម្ម

| | |
|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ ជា ណោង | ប្រធាន |
| ២- ឯកឧត្តមបណ្ឌិត ស៊ុន សូត | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត សាបូ អូហ្សាណូ | សមាជិក |
| ៤- លោកបណ្ឌិត ម៉ុង ស៊ាងងឹម | សមាជិក |
| ៥- លោកបណ្ឌិត ម៉ែន សារ៉ុម | សមាជិក |
| ៦- លោកបណ្ឌិត សួន សុធឿន | សមាជិក |
| ៧- លោកបណ្ឌិត ខៃសត្យា | សមាជិក |
| ៨- លោកបណ្ឌិត តាំង ស៊ិន | សមាជិក |
| ៩- លោក រស់ ផាន្នី | សមាជិក |
| ១០- លោក សួន សុភា | សមាជិក |
| ១១- លោក សុខ វ៉ាន់ថន | សមាជិក |
| ១២- លោក ប៉ាង ចាន់ថា | ជំនួយខាងភាសា |
| ១៣- លោកបណ្ឌិត គី ចន្ទណារិទ្ធ | សមាជិក |
| ១៤- លោក ស្វាយ វីដា | សមាជិក |

## រៀបចំបោះពុម្ពផ្សាយដោយ ៖

ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្ដុះបណ្ដាល
នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ

# បច្ចេកសព្ទវេជ្ជសាស្ត្រ និង កសិកម្ម
# ដែលគណៈកម្មាធិការជាតិភាសាខ្មែរ / គ.ជ.ភ.ខ.
# (បច្ចុប្បន្ន ក្រុមប្រឹក្សាជាតិភាសាខ្មែរ / ក.ជ.ភ.ខ.)
# បានអនុម័ត

## ១- បច្ចេកសព្ទវេជ្ជសាស្ត្រ

| | |
|---|---|
| **១- កញ្ជ្រឹល**<br>អ. measles, morbilli, rubeola<br>បារ. rougeole (f.) | រោគឆ្លងម៉្យាង ច្រើនកើតលើកុមារ បណ្ដាលមកពីវីរុស morbilli បង្កឱ្យស្បែកមានកន្ទួលតូចៗ ពណ៌ក្រហម ក្អក ហៀរសំបោរ គ្រុនក្ដៅ ឈឺបំពង់ក។ល។<br>ឧ. កុមារនេះបានចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលរួចហើយ។ |
| **២- កន្ទាលត្រអាក**<br>អ. urticaria / hives<br>បារ. urticaire (f.) | កន្ទួលឃ្នឹលជាបន្ទះតិចឬច្រើននៅលើស្បែក មានឬគ្មានពណ៌ក្រហម បណ្ដាលឱ្យរមាស់ កើតឡើងដោយប្រតិកម្មអាឡែហ្ស៊ី( réaction allergique )។<br>ឧ១- ការប៉ះពាល់ជាមួយនឹងដើមកន្ទេចអាលឬវល្លិខ្មែរ បណ្ដាលឱ្យឡើងកន្ទាលត្រអាកលើស្បែកត្រង់កន្លែងប៉ះនោះ។<br>ឧ២- ប្រតិកម្មអាហារ ឱសថ និង រោគសញ្ញានៃជំងឺបរាសិតមួយចំនួន បណ្ដាលឱ្យចេញកន្ទាល-ត្រអាកនៅលើស្បែក។ |

| | |
|---|---|
| ៣- **កម្សោយសាច់ដុំ**<br>អ. myasthenia<br>បារ. myasthénie (f.) | អាការៈចុះខ្សោយកម្លាំងចលនាសាច់ដុំបណ្ដាលមកពីមូលហេតុច្រើនយ៉ាង។ |
| ៤- **ការកកឈាម**<br>អ. blood coagu-lation / blood-clotting<br>បារ. coagulation sanguine (f.) | បម្រែបម្រួលឈាមពីរាវទៅពាក់កណ្ដាលរឹងដែលអាចកើតមាននៅក្នុងឬក្រៅសរសៃឈាម។ |
| ៥- **ការកន្ត្រាក់សាច់ដុំ**<br>អ. muscle contraction<br>បារ. contraction musculaire (f.) | អាការៈទាញកញ្ជក់នៃសាច់ដុំដែលរំញោចដោយប្រព័ន្ធប្រសាទ ឬ ដោយមូលហេតុផ្សេងៗ។ |
| ៦- **ការក្អែ**<br>អ. regurgitation<br>បារ. régurgitation (f.) | ដំណើរវិលត្រឡប់នៃអាហារពីក្រពះឬបំពង់អាហារមកតាមមាត់ តែ មិនមែនជាការក្អួតទេ។<br>ឧ. ការក្អែច្រើនកើតលើទារកនិងកុមារតូចៗក្រោយពេលបៅរួច។ |
| ៧- **ការខ្ទាំ / កុងទុយស្យុង**<br>អ. contusion<br>បារ. contusion (f.) | របួសម្យ៉ាងដែលបណ្ដាលមកពីគ្រោះថ្នាក់ធ្ងន់ធ្ងរធ្វើឱ្យខ្ទេចជាលិកាក្នុងសរីរាង្គណាមួយ ប៉ុន្តែ មិនមានរហែកស្បែកឬស្រោមពទ្ធជុំវិញ។ |

| | |
|---|---|
| ៨- **ការចាក់ម្ជុលវិទ្យាសាស្ត្រ / អាគុយពង់ទួរ**<br>អ. acupuncture<br>បារ. acupuncture (f.) | វិធីចាក់ម្ជុលឆ្មារចូលតាមស្បែកចំខ្សែម៉េរីឌីយាង (méridien)នៃសរីរាង្គដែលឈឺ ក្នុងគោលបំណងរករោគវិនិច្ឆ័យឬធ្វើការព្យាបាលជំងឺពុំរ៉ៃមួយចំនួនតាមក្បួនវេជ្ជសាស្ត្របុរាណចិន។ |
| ៩- **ការចាល់ / រ៉េតង់ស្យុង**<br>អ. retention<br>បារ. rétention (f.) | អាការៈនៃសរីរាង្គដែលមិនអាចមានលទ្ធភាពបញ្ចេញចោលឱ្យអស់នូវសារធាតុផ្ទុក(រឹង រាវ ឬ ឧស្ម័ន) របស់វា។<br>ឧ. រ៉េតង់ស្យុងទឹកមូត្រនៅក្នុងប្លោកនោម ដែលបណ្តាលមកពីការចាល់នៅត្រង់បង្ហួរនោម អាចបង្កឱ្យមានគ្រោះថ្នាក់។ |
| ១០- **ការចុករវក្កំ / ការចុកតម្រងនោម**<br>អ. renal colic<br>បារ. colique rénale colique néphré-tique (f.) | អាការៈឈឺចុកចាប់យ៉ាងស្រួចស្រាល់នៅចង្កេះផ្នែកខាងឆ្វេងឬស្តាំ ដែលមានលក្ខណៈឈឺចាក់ចុះក្រោមទៅរកប្រដាប់បន្តពូជខាងក្រៅឬផ្ទៃខាងក្នុងនៃភ្លៅ ដោយសារការស្ទះផ្លូវទឹកមូត្រ ដែលភាគ-ច្រើនបណ្តាលមកពីមានគ្រួស។<br>ឧ. ការចុកតម្រងនោមខាងស្តាំអាចច្រឡំជាមួយនឹងការចុកថ្លើម(colique hépatique) ប៉ុន្តែការចុកថ្លើមមានអាការៈឈឺចាក់មករកស្មាស្តាំ។ |
| ១១- **ការចុកពោះ / កូលិក**<br>អ. colic<br>បារ. colique (f.) | អាការៈឈឺចុកចាប់ក្នុងធិទ្ធដ្ឋានពោះ (calvité abdominale)។<br>ឧ.ក្នុងករណីស្ទះពោះវៀនធំ អ្នកជំងឺមានការចុកពោះយ៉ាងខ្លាំងក្លា។ |

| | |
|---|---|
| ១២-**ការឈឺសន្លាក់**<br>អ. arthralgia<br>បារ. arthralgie (f.) | ការឈឺចុកចាប់ក្នុងសន្លាក់ដែលបង្កដោយជំងឺច្រើនយ៉ាង។<br>ឧ. ជំងឺគ្រុនសន្លាក់ (rhumatisme) បង្កឱ្យមានការឈឺសន្លាក់ច្រើនកន្លែង។ |
| ១៣- **ការឈឺសាច់ដុំ**<br>អ. myalgia / myodynia<br>បារ. myalgie / myodynie (f.) | អាការៈឈឺចុកចាប់នៅក្នុងសាច់ដុំដោយសារមូលហេតុច្រើនយ៉ាង ដូចជា ការឈឺសាច់ដុំពេលមានជំងឺផ្ដាសាយធំ (grippe)។ |
| ១៤- **ការញៀន**<br>អ. addiction<br>បារ. addiction / pharmaco-dépendance (f.) | អាការៈដែលមនុស្សឬសត្វមិនងាយបោះបង់បាននូវសារធាតុញៀន (drogue) ដែលធ្លាប់បានប្រើរួចហើយ។<br>ឧ. អាភៀននិងកញ្ឆាធ្វើឱ្យមានការញៀនដែលមិនងាយបោះបង់បាន ក្រោយពេលប្រើវាយូរមកហើយ។ |
| ១៥- **ការគ្អើក**<br>អ. hiccough<br>បារ. hoquet (m.) | ដំណើរកន្ត្រាក់នៃសាច់ដុំរបាំងទ្រូង (diaphragme) ដោយអចេតនា បង្កឱ្យមានការបញ្ចេញខ្យល់និងសំឡេងតាមមាត់ជាសូរអឹកៗ។<br>ឧ. ជំងឺមហារីកបំពង់អាហារបង្កឱ្យមានការគ្អើកជាប្រចាំ។ |

| | |
|---|---|
| ១៦- **ការធ្លាក់ស / ឡឺកូរ៉េ**<br>អ. leukorrhea<br>បារ. leucorrhée (f.) / pertes blanches (f. pl.) | អាការៈធ្លាក់រំអិលពណ៌សតាមផ្លូវបន្តពូជរបស់ស្ត្រី ក្នុងចន្លោះពេលមានរដូវ ពេលមានគភ៌ ពេលបំបៅកូន និង ក្រោយពេលអស់រដូវ។<br>ឧ. ការធ្លាក់សមានពណ៌ផ្សេងក្រៅពីពណ៌ស និង ក្លិនខុសធម្មតា ព្រមទាំងមានរមាស់ទ្វារមាស ជាអាការៈបញ្ជាក់ពីការរលាក ឬ មានជំងឺប្រដាប់បន្តពូជស្ត្រី។ |
| ១៧- **ការបង្កកំណើត / កំណកំណើត**<br>អ. fertilization<br>បារ. fécondation (f.) | ជំនួបរវាងស្ពែម៉ាតូសូអ៊ីត (spermatizoïde) និងអូវុល (ovule) ចំពោះមនុស្សឬសត្វ, រវាងអង់តេរ៉ូសូអ៊ីត (antérozoïde) និងអូអូស្វ៊ែ (oosphère) ចំពោះរុក្ខជាតិ បង្កើតបានជាកោសិកាថ្មីមួយ ហៅថា ស៊ីហ្គូត (zygote)។<br>ឧ. ការបង្កកំណើតអាចប្រព្រឹត្តទៅបានលុះត្រាតែមានការជួបគ្នារវាងកាម៉េតឈ្មោលនិងកាម៉េតញី។ |
| ១៨- **ការបាក់ឆ្អឹង / បំណាក់ឆ្អឹង**<br>អ. fracture<br>បារ. fracture (f.) | ការបាក់ដាច់ឬបែកបាក់ដោយអន្លើឬដោយផ្នែកទាំងអស់របស់ឆ្អឹង។<br>ឧ. ក្រោយពីអស់រដូវ ស្ត្រីដែលពុំបានទទួលសារធាតុកាល់ស្យូម និង ផូស្វ័រ ឱ្យបានគ្រប់គ្រាន់ ងាយទទួលរងការបាក់ឆ្អឹង។ |
| ១៩- **ការផ្តាច់គភ៌**<br>អ. conceptus interruption<br>បារ. interruption de conception (f.) | ការបញ្ចប់ការអភិវឌ្ឍគភ៌នៅក្នុងផ្ទៃដោយចេតនា។<br>ឧ. ការរំលូតកូនជាវិធីមួយក្នុងការផ្តាច់គភ៌។ |

| | |
|---|---|
| ២០- **ការពន្យារកំ-ណើត / កុងត្រាសិបស្យុង**<br>អ. contraception<br>បារ. contraception (f.) | វិធីបង្ការមិនឱ្យមានកំណាត់ក៏នៅក្នុងផ្ទៃម្ដាយ។<br>ឧ. ការប្រើស្រោមអនាម័យជាវិធីមួយក្នុងចំណោមវិធីជាច្រើននៃការពន្យារកំណើត។ |
| ២១- **ការភ្លាត់ឆ្អឹង**<br>អ. luxation<br>បារ. luxation (f.) | ដំណើរឃ្លាតឬភ្លាត់ឬក៏របូតក្បាលឆ្អឹងពីទីតាំងដើម បណ្ដាលមកពីការដួលឬការប៉ះទង្គិច។<br>ឧ. កីឡាករបាល់ទាត់ច្រើនរងគ្រោះថ្នាក់ដោយការភ្លាត់ឆ្អឹង។ |
| ២២- **ការមិនស្រេកទឹក / អឌីបស៊ី**<br>អ. adipsia<br>បារ. adipsie (f.) | លក្ខណៈធម្មជាតិរបស់មនុស្សមួយចំនួនតូចដែលមិនចង់ផឹកទឹកក្នុងរយៈពេលខ្លីឬវែង (ថ្ងៃឬសប្ដាហ៍) ប៉ុន្តែ មិនមែនជាជំងឺទេ។ |
| ២៣- **ការរមួលសន្លាក់**<br>អ. distortion<br>បារ. distorsion (f.) | របួសម្យ៉ាងដែលធ្វើឱ្យសន្លាក់វិលខុសប្រក្រតី បណ្ដាលឱ្យយារលីហ្កាម៉ង់ (ligament) ពទ្ធជុំវិញឱ្យឈឺចាប់ និង មិនអាចធ្វើចលនាសកម្មបាន។ ការរមួលសន្លាក់មិនទាមទារឱ្យមានការវះកាត់ទេ ប៉ុន្តែ ត្រូវធ្វើការព្យាបាលដោយអបសន្លាក់ និង ផ្ដល់ឱសថបំបាត់ការឈឺចាប់។ |
| ២៤- **ការរលាកសាច់ដុំ**<br>អ. myositis<br>បារ. myosite (f.) | អាការៈរលាកជាលិកាសាច់ដុំដែលបណ្ដាលមកពីអាំងហ្វិចស្យុង (infection) ផ្សេងៗ ដូចជាអាំងហ្វិចស្យុងដោយសារបាក់តេរីស្ដាហ្វីឡូកូក (staphylocoque)។ |

| | |
|---|---|
| ២៥- **ការរលូតកូន**<br>អ. abortion<br>បារ. avortement (m.) | ការរបូតគភ៌ចេញពីផ្ទៃម្ដាយ មុន១៨០ថ្ងៃ។<br>ឧ. ស្ត្រីមានគភ៌ដែលបានទៅពិនិត្យផ្ទៃពោះត្រឹមត្រូវអាចចៀសផុតពីការរលូតកូន។ |
| ២៦- **ការរលូតកូនឯកឯង**<br>អ. spontaneous abortion<br>បារ. avortement spontané (m.) | ការរបូតគភ៌ចេញពីផ្ទៃម្ដាយដោយចៃដន្យនិងគ្មានការបង្ខំ។<br>ឧ. ការរលូតកូនឯកឯងអាចបង្កឡើងដោយសារការវិវត្តមិនត្រឹមត្រូវនៃ គភ៌ សុក ឬ បង្កដោយជំងឺ ឬ គ្រោះថ្នាក់របស់ម្ដាយ។ |
| ២៧- **ការរាកនោមយប់ / ណុកតួរី**<br>អ. nocturia / enuresis<br>បារ. énurèse / énurésie (f.) / nocturie (f.) | អាការៈហៀរទឹកនោមដោយមិនដឹងខ្លួន ភាគច្រើនពេលដេកលក់នៅពេលយប់។ |
| ២៨- **ការរំលូតកូន**<br>អ. induced abortion<br>បារ. avortement | ការធ្វើឱ្យរបូតគភ៌ចេញពីផ្ទៃម្ដាយដោយចេតនា ដូចជា ការប្រើឱសថ ការបូម ឬ ការកោសគភ៌ចេញពីស្បូន។<br>ឧ. ក្នុងករណីស្ត្រីមានគភ៌មានជំងឺធ្ងន់ធ្ងរ ឬ អំប្រីយ៉ុងក្នុងផ្ទៃមានលក្ខណៈមិនប្រក្រតីដែលអាចប៉ះពាល់ដល់ជីវិតម្ដាយ គេត្រូវបង្ខំចិត្តធ្វើការរំលូតកូន។ |

| | |
|---|---|
| ២៩- **ការរាំងរដូវ**<br>អ. amenorrhea<br>បារ. aménorrhée (f.) | ការបាត់រដូវរបស់ស្ត្រីក្នុងវ័យបន្តពូជដែលមានលក្ខណៈមិនប្រក្រតី។<br>ឧ. ការមានវិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ ការមានជំងឺធ្ងន់ធ្ងរប្រចាំកាយ ឬ ការមានគភ៌ បង្កឱ្យស្ត្រីមានការរាំងរដូវ។ |
| ៣០- **ការហើមពោះ**<br>អ. meteorism<br>បារ. ballonnement/ météorisme (m.) | អាការៈប៉ោងពោះដោយសារស្ទះឧស្ម័ននៅក្នុងក្រពះ ពោះវៀន។<br>ឧ. ជំងឺគ្រុនពោះវៀនបង្កឱ្យមានអាការៈគ្រុនក្តៅខ្លាំង ការហើមពោះ និង រោគសញ្ញាផ្លូវរំលាយអាហារផ្សេងៗទៀត។ |
| ៣១- **ការអស់រដូវ/ មេណូប៉ូស**<br>អ. menopause<br>បារ. ménopause (f.) | ដំណើរឈប់ធ្លាក់ឈាមរដូវរបស់ស្ត្រី ដែលជាទូទៅអាចចាប់ផ្តើមពីអាយុ៤៥ដល់៥៥ឆ្នាំ។<br>ឧ. ការអស់រដូវរបស់ស្ត្រីបញ្ជាក់ថា ស្ត្រីនោះពុំអាចមានលទ្ធភាពបន្តពូជបានទៀតឡើយ។ |
| ៣២- **កាស៊ីណូម**<br>អ. carcinoma<br>បារ. carcinome (m.) | មហារីកជាលិកាភ្នាស (épithélium) ដែលគ្របលើសរីរាង្គណាមួយ ប៉ុន្តែ មិនកាចសាហាវដូចមីញ៉ូសាកូម (mysarcome) ទេ។ |
| ៣៣- **កុងត្រាក់ទួរសាច់ដុំ**<br>អ. muscle contracture<br>បារ. contracture musculaire (f.) | អាការៈកន្ត្រាក់សាច់ដុំយ៉ាងរឹងជាអចិន្ត្រៃយ៍ ដោយមូលហេតុសាច់ដុំទទួលការឈឺចាប់ ឬ រំញោចយ៉ាងខ្លាំងក្លា។ |

| | |
|---|---|
| ៣៤- **កូរីយ៉ុង**<br>អ. chorion<br>បារ. chorion<br>( m. ) | ស្រទាប់ក្រៅនៃភ្នាសទារកដែលអភិវឌ្ឍទៅតាមការរីកធំធាត់របស់ទារកនៅក្នុងផ្ទៃម្ដាយ។<br>ឧ. អាម្ញូស( amios )និងកូរីយ៉ុងបង្កើតបានជាភ្នាសទារកនៅក្នុងផ្ទៃម្ដាយ។ |
| ៣៥- **កោសិកា**<br>អ. cell<br>បារ. cellule ( f. ) | ឯកតាទម្រង់គ្រឹះនៃជីវិតដែលជាផ្នែកតូចបំផុតរបស់ភាវៈរស់ ហើយ ដែលអាចដំណើរជីវិតបានដោយខ្លួនឯង។ ធាតុផ្សំនៃកោសិកាមានស៊ីតូប្លាស ( cytoplasme ) ណ្វៃយ៉ូ ( noyau )...។ |
| ៣៦- **ក្រិស ( ជំងឺ )**<br>អ. rachitism<br>បារ. rachitisme<br>( m. ) | ជំងឺបណ្ដាលមកពីឆ្អឹងមិនលូតលាស់ទៅតាមដំណាក់នៃសរីរាង្គមនុស្សនិងសត្វ ដែលបណ្ដាលមកពីកត្តាផ្សេងៗជាច្រើន ជាពិសេសកង្វះវីតាមីន/ជីវជាតិដេ( vitamine D )។<br>ឧ. ការឱ្យទារកឬសត្វទទួលបានពន្លឺព្រះអាទិត្យនៅពេលព្រឹកព្រលឹម អាចជួយកាត់បន្ថយជំងឺក្រិស។ |
| ៣៧- **ក្រួស**<br>**( វេជ្ជសាស្ត្រ )**<br>អ. stone/calculus<br>បារ. calcul ( m. ) | ដុំកំណកសារធាតុកំបោរកកើតក្នុងសរីរាង្គមនុស្សសត្វ។<br>ឧ. ការចុកតម្រងនោមភាគច្រើនបង្កឡើងដោយ-សារការស្ទះក្រួសក្នុងតម្រងនោមឬបំពង់ទឹកនោម ( uretère )។ |

| | |
|---|---|
| ៣៨- **ក្រួសវក្កំ / ក្រួសតម្រងនោម**<br>អ. renal stone / kidney stone / renal lithiasis<br>បារ. calcul rénal (m.) / lithiase rénal (m.) | ដុំកំណកសារធាតុកំបោរកកើតក្នុងតម្រងនោម ដែលអាចបង្កឱ្យស្ទះប្រព័ន្ធទឹកមូត្រ និង អាចបង្កឱ្យមានអាការៈឈឺចុកចាប់។ |
| ៣៩- **ក្អក**<br>អ. cough<br>បារ. toux (f.) | សញ្ញា/អាការៈបញ្ចេញខ្យល់ដោយបង្ខំរហ័សភ្លាមៗ របៀបជាកន្ត្រាក់ឬកញ្ចក់ និង មានសូរសំឡេងចេញពីបំពង់ក ជួនកាលកើតឡើងដោយចេតនា ឬ អចេតនា និង រេផ្លិច(réflexe)។<br>ជាទូទៅ ក្អកបណ្ដាលមកពីការរលាកផ្លូវដង្ហើម និង ផ្លូវរំលាយអាហារ។<br>ឧ. ក្មេងដែលមានជំងឺរលាកផ្លូវដង្ហើម បណ្ដាលឱ្យមានអាការៈក្អកជាញឹកញាប់។ |
| ៤០- **ខ្ទុះតម្រងនោម / ខ្ទុះវក្កំ/ ព្យោណេប្រហ្វូស**<br>អ. pyonephrosis / renal empyema<br>បារ. pyonéphrose (f.) / empyème rénal (m.) | អាការៈរលាកដោយមានខ្ទុះដក់ក្នុងវក្កំ (តម្រងនោម) ដែលបង្កឱ្យមានការចុកចាប់នៅចង្កេះ និង មានខ្ទុះក្នុងទឹកមូត្រ។ |

| | |
|---|---|
| ៤១- **ខ្ទុះបង្ហូរនោម /ប្លេណូរ៉េ**<br>អ. blennorrhea<br>បារ. blennorrhée (f.) | អាការៈមានខ្ទុះហូរតាមបង្ហូរនោម(urètre)ដែលជារោគសញ្ញាមួយបណ្ដាលមកពីការរលាកនៅផ្លូវទឹកមូត្រ។ |
| ៤២- **គភ៌**<br>អ. gestation / pregnancy<br>បារ. gestation / grossesse (f.) | កូនក្នុងផ្ទៃដែលវិវត្តពីស៊ីហ្គូត(zygote) រហូតដល់គ្រប់ខែកើត។<br>ឧ. ស្ត្រីរូបនេះមានគភ៌ចំនួន៥ខែមកហើយ។ |
| ៤៣- **គភ៌ក្រៅស្បូន**<br>អ. ectopic pregnancy<br>បារ. grossesse ectopique/ grossesse extra-utérine (f.) | គភ៌ដែលតាំងទីនៅក្នុងដៃស្បូន(trompe de fallope) កន្សោមស្បូន(ovaire) ឬ ធិទ្ធដ្ឋានពោះ(cavité péritonéale)។<br>ឧ. ស្ត្រីមានគភ៌ត្រូវទៅពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់តាមកាលកំណត់របស់គ្រូពេទ្យឯកទេសសម្ភព ដើម្បីចៀសវាងគ្រោះថ្នាក់ ក្នុងករណីមានគភ៌ក្រៅស្បូន។ |
| ៤៤- **គភ៌គ្រប់ខែ**<br>អ. pregnancy in term<br>បារ. grossesse à terme (f.) | គភ៌ដែលមានអាយុជាមធ្យម៩ខែ១០ថ្ងៃ រាប់ចាប់ពីថ្ងៃបាត់រដូវរហូតដល់ថ្ងៃសម្រាល។<br>ឧ. គភ៌គ្រប់ខែអាចលើសឬខ្វះ២សប្ដាហ៍នៃអាយុរបស់គភ៌។ |

| | |
|---|---|
| ៤៥- **គភ៌ចាស់ខែ**<br>អ. prolonged pregnancy / postterm pregnancy<br>បារ. grossesse prolongée (f.) | គភ៌ដែលមានអាយុលើសពី៤២សប្ដាហ៍ គឺមានរយៈពេលវែងជាងគភ៌គ្រប់ខែធម្មតា។<br>ឧ. ស្ត្រីមានគភ៌ចាស់ខែចាំបាច់ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេសសម្ភព ដើម្បីចៀសវាងគ្រោះថ្នាក់នៅពេលសម្រាល។ |
| ៤៦- **គីមីព្យាបាល**<br>អ. chemotherapy<br>បារ. chimiothé-rapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយការប្រើសារធាតុគីមី។ |
| ៤៧- **គីស្ត**<br>អ. cyst<br>បារ. kyste (m.) | ដុំពកបេនីញ (tumeur bénigne) ជាសារធាតុរាវរុំពទ្ធជុំវិញដោយស្រោមដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។<br>ឧ. គីស្តអាចកើតមាននៅគ្រប់សរីរាង្គទាំងអស់ ដែលទាមទារឱ្យអ្នកជំងឺត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យវះកាត់។ |
| ៤៨- **គ្រុន**<br>អ . fever / pyrexia<br>បារ. fièvre / pyrexie (f.) | អាការៈបណ្ដាលឱ្យកម្ដៅក្នុងខ្លួនកើនឡើងហួសប្រក្រតី។<br>ឧ. ក្មេងដែលម្ដាយនាំទៅមន្ទីរពេទ្យបង្អែកនេះកំពុងមានជំងឺគ្រុនក្ដៅ។ |

| | |
|---|---|
| ៤៩- **គ្រោងឆ្អឹង / អដ្ឋិសង្ខលិក**<br>អ. skeleton<br>បារ. squelette (m.) | សំណុំឆ្អឹងទាំងអស់នៃសព៌ាង្គកាយដែលបង្កើតបានជារចនាសម្ព័ន្ធនិងរាងពៅរបស់មនុស្សនិងសត្វ។<br>ឧ. អដ្ឋិសង្ខលិករបស់មនុស្សមានឆ្អឹងចំនួន ២០៦ ដែលរួមមាន ឆ្អឹងវែង ឆ្អឹងសំប៉ែត និង ឆ្អឹងខ្លី។ |
| ៥០- **គ្រោះថ្នាក់**<br>អ. accident<br>បារ. accident (m.) | ហេតុការណ៍ជាវិបត្តិដែលកើតឡើងបន្ទាន់ឬដោយចៃដន្យ។<br>ឧ. ក្នុងករណីសម្ពាធឈាមឡើងខ្ពស់ អ្នកជំងឺអាចមានគ្រោះថ្នាក់សរសៃឈាមក្នុងខួរក្បាល (accident vasulaire cérébral : AVC)។ |
| ៥១- **គ្លុយស៊ីដ**<br>អ. glucid<br>បារ. glucide (m.) | សារធាតុស្ករ ជាកាបោនអ៊ីដ្រាត (hydrate de carbone) ដែលក្នុងនោះមាន ស្ករទោល (ose = sucre simple) និង ស្ករកុំផ្លិច (oside = sucre complexe)។ |
| ៥២- **ចលនាព្យាបាល / គីណេព្យាបាល**<br>អ. kinesitherapy<br>បារ. kinésitherapie (f.) / cinésithérapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយហត្ថចលនាដើម្បីរំញោចសរីរាង្គ ដូចជា ការច្របាច់ ការចុច... ឬប្រើឧបករណ៍ផ្សេងៗ។ កន្លងមក គេធ្លាប់ប្រើពាក្យនេះថា *ការព្យាបាលដោយចលនា*។ |

| | |
|---|---|
| ៥៣- **ចិត្តព្យាបាល**<br>អ. psychotherapy<br>បារ. psychothé-rapie (f.) / traitement psychique (m.) | វិធីសាស្ត្រព្យាបាលជំងឺដោយការអប់រំសម្រួលផ្លូវចិត្ត ក្នុងគោលបំណងបន្ធូរអារម្មណ៍អ្នកជំងឺ។ |
| ៥៤- **ជាលិកា**<br>អ. tissue<br>បារ. tissu (m.) | សំណុំកោសិកាដែលមានទម្រង់រចនាសម្ព័ន្ធនិងមុខងារដូចគ្នា បង្កើតបានជាសរីរាង្គមួយ ឬផ្នែកមួយនៃសរីរាង្គ។ |
| ៥៥- **ជីវវិទ្យា**<br>អ. biology<br>បារ. biologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីភាវៈមានជីវិត (មនុស្ស សត្វ និង រុក្ខជាតិ)។ |
| ៥៦- **ជីវគីមីវិទ្យា**<br>អ. biochemistry<br>បារ. biochimie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសមាសធាតុនិងប្រតិកម្មគីមី ក្នុងភាវៈមានជីវិត។<br>ឧ. ការសិក្សាលម្អិតពីការរំលាយអាហារនៅក្នុងខ្លួនមនុស្ស សត្វ ជាផ្នែកមួយនៃជីវគីមីវិទ្យា។ |
| ៥៧- **ជំងឺក្រិន**<br>អ. sclerosis<br>បារ. sclérose (f.) | សភាពរឹងឬក្រាស់នៃជាលិកាឬសរីរាង្គណាមួយដែលបណ្ដាលឱ្យបាត់បង់មុខងាររបស់វា។<br>ឧ. ការពិសាស្រាជាកត្តាមួយជំរុញឱ្យជំងឺរលាកថ្លើមវិវត្តទៅជាជំងឺក្រិនថ្លើម។ |

| | |
|---|---|
| ៥៨- **ជំងឺក្រិនថ្លើម (សៀរ៉ូសថ្លើម)**<br>អ. hepatic cirrhosis<br>បារ. cirrhose du foie / cirrhose hépatique (f.) | ជំងឺថ្លើមម្យ៉ាងបណ្ដាលមកពីការរលាកកោសិកា (cellule) ថ្លើម ធ្វើឱ្យជាលិកា (tissu) ថ្លើមរឹងក្រិន លែងបំពេញមុខងារបាន។<br>ឧ. ការព្យាបាលជំងឺរលាកថ្លើមទាន់ពេលវេលាអាចទប់ស្កាត់ការវិវត្តទៅជាជំងឺក្រិនថ្លើមបាន។ |
| ៥៩- **ជំងឺខ្វាក់មាន់**<br>អ. hemeralopia / night blindness<br>បារ. héméralopie (f.) | ជំងឺមួយប្រភេទច្រើនកើតលើកុមារ ដែលភ្នែកមើលមិនឃើញខុសប្រក្រតីនៅទីងងឹតនៅពេលយប់ឬនៅពេលមានពន្លឺខ្សោយ។ ជាទូទៅ ជំងឺនេះកើតឡើងដោយសារកង្វះវីតាមីនអា / ជីវជាតិអា (vitamine A)។<br>ឧ. ជំងឺខ្វាក់មាន់អាចបង្ការនិងព្យាបាលដោយឱសថឬអាហារដែលសម្បូរជីវជាតិអា។ |
| ៦០- **ជំងឺជ្រាំង**<br>អ. thrush<br>បារ. muguet (m.) | ជំងឺមួយប្រភេទដែលកើតឡើងជាផ្លាកស្នាម (taches) ពណ៌សស្រអាប់ ទំហំតូចឬធំនៅលើភ្នាសក្នុងមាត់ និង ជួនកាល រលាកដល់ដើមបំពង់កដែលបង្កឡើងដោយផ្សិតកង់ឌីដាអាប៊ីកង់(candida albicans)។ ជំងឺនេះច្រើនកើតនៅលើកុមារ។<br>ឧ. ផលវិបាកនៃជំងឺជ្រាំងបណ្ដាលឱ្យខ្វះអាហារូបត្ថម្ភ។ |

| | |
|---|---|
| ៦១- **ជំងឺប្រគ្រីវ/ ហ្គុត**<br>អ . gout<br>បារ. goutte (f.) | ជំងឺបង្កឱ្យឈឺចុកចាប់ ជាពិសេសនៅពេលយប់ ពេលសម្រាក ឬ គ្មានសកម្មភាពនៅត្រង់សន្លាក់ ម្រាមដៃ ម្រាមជើង និង បណ្តាសន្លាក់ដទៃទៀត។ ជំងឺនេះច្រើនបណ្តាលមកពីសារជាតុអាស៊ីតអ៊ុយ-រិក(acide urique) មានកម្រិតខ្ពស់ហួសប្រក្រតី។<br>ឧ. គ្រូពេទ្យបានឱ្យដំបូន្មានដល់អ្នកជំងឺប្រគ្រីវនេះ ឱ្យតមចំណីអាហារណាដែលបង្កឱ្យកើនសារជាតុ អាស៊ីតអ៊ុយរិក ដូចជា សាច់អាំង គ្រឿងសមុទ្រ គ្រឿងក្នុងជ្រូកមាន់ទា,...។ |
| ៦២- **ជំងឺពកក**<br>អ. goiter / goitre<br>បារ. goitre (f.) | ជំងឺដែលសម្គាល់ដោយការរីកធំឬមានដុំពកនៃ ក្រពេញទីរ៉ូអ៊ីត (la glande thyroïde) នៅនឹងក ដោយសារក្រពេញនេះផលិតអ័រម៉ូនតិចពេកឬច្រើន ពេក។ ជំងឺពកក ជាធម្មតា ច្រើនតែបណ្តាល មកពីកង្វះជាតិអ៊ីយ៉ូតនៅក្នុងចំណីអាហារ។ គេ សង្កេតឃើញជំងឺពកកមានច្រើនសណ្ឋាន។<br>ឧ. អ្នកបរិភោគអំបិលមានសារជាតុអ៊ីយ៉ូត អាច ការពារមិនឱ្យកើតជំងឺពកកបាន។ |
| ៦៣- **ជំងឺពកឆ្អឹង/ អូស្តេអូម**<br>អ. osteoma<br>បារ. ostéome (f.) | ជំងឺមួយប្រភេទដែលមានអាការៈពីរយ៉ាង គឺ<br>១- អាការៈរីកលូតលាស់ខុសប្រក្រតីរបស់ជាលិកា ឆ្អឹងពេញវ័យដែលវិវត្តយឺតៗនៅនឹងកន្លែង បង្ក បានជាកំពកនៃឆ្អឹង។<br>២- អាការៈជាដុំពកមានលក្ខណៈជាឆ្អឹងដែលកកើត |

| | |
|---|---|
| | ឡើងនៅកន្លែងប៉ះទង្គិចញឹកញាប់នៃដាលិកាទន់របស់សរីរាង្គកាយ។<br>ឧ. ជំងឺពកឆ្អឹងត្រូវតែព្យាបាលដោយការវះកាត់។ |
| ៦៤- **ជំងឺពុកឆ្អឹង / អូស្តេអូប៉ូរ៉ូស**<br>អ. osteoporosis<br>បារ. ostéoporose (f.) | ជំងឺមួយប្រភេទដែលកើតឡើងដោយសារកង្វះសារជាតុរ៉ែ និង ការថយចុះនៃបណ្តាញប្រព័ន្ធប្រូតេអ៊ីនរបស់ឆ្អឹង។ ជំងឺនេះបណ្តាលឱ្យមានការឈឺចុកចាប់ ការខូចទម្រង់ដើមនៃឆ្អឹង និង ធ្វើឱ្យឆ្អឹងងាយបាក់។<br>ឧ. ជំងឺពុកឆ្អឹងជាជំងឺដែលច្រើនកើតលើស្ត្រីវ័យចាស់។ |
| ៦៥- **ជំងឺភ្នែកក្រហម**<br>អ. conjunctivitis<br>បារ. conjonctivite (f.) | ជំងឺមួយប្រភេទដែលបង្កឱ្យរលាកភ្នាសក្នុងត្របកភ្នែកនិងគ្រាប់ភ្នែក លើកលែងតែកែវភ្នែក(គ័រណេ = cornée)។ មូលហេតុបណ្តាលមកពីការបង្ករោគដោយមីក្រុប ចំណាំងពន្លឺខ្លាំង ឬ អង្គធាតុក្រៅ (corps étranger) ចូលក្នុងភ្នែក។<br>ឧ. ការលាងដៃដោយសាប៊ូជាប្រចាំ កាត់បន្ថយការកើតជំងឺភ្នែកក្រហម។ |
| ៦៦- **ជំងឺមហារីក**<br>អ. cancer<br>បារ. cancer (m.) | ជំងឺកើតឡើងជាដុំពក ជាដំបៅមិនប្រក្រតី នៅតាមសរីរាង្គណាមួយរបស់មនុស្សឬសត្វ បង្កឡើងដោយកោសិកាដែលដុះរីកលូតលាស់ខុសធម្មតា និងរាលដាលបង្កជាជំងឺស្រួចស្រាល់ឬរ៉ាំរ៉ៃបណ្តាលឱ្យស្លាប់ បើមិនមានការព្យាបាលឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត ជំនាញ ឱ្យទាន់ពេលវេលាទេនោះ។<br>ឧ. អ្នកជំងឺនេះស្លាប់ដោយជំងឺមហារីកថ្លើម។ |

| | |
|---|---|
| ៦៧- **ជំងឺរលាកសន្លាក់**<br>អ. arthritis<br>បារ. arthrite (f.) | ជំងឺរលាកនៅត្រង់សន្លាក់បណ្ដាលឱ្យឡើងក្រ-ហម ក្ដៅ ឈឺចាប់ និង ហើម ដែលមានលក្ខណៈស្រួចស្រាវឬរ៉ាំរ៉ៃ។<br>ឧ. អ្នកជំងឺរលាកសន្លាក់គប្បីទៅពិនិត្យព្យាបាលតាមការណែនាំរបស់គ្រូពេទ្យឯកទេស។ |
| ៦៨- **ជំងឺរលាកអណ្ដាត**<br>អ. glossitis<br>បារ. glossite (f.) | ជំងឺមួយប្រភេទដែលបង្កឱ្យរលាកភ្នាសអណ្ដាតសើៗឬជ្រៅ និង មានលក្ខណៈស្រួចស្រាវឬរ៉ាំរ៉ៃ។<br>ឧ. អ្នកជំងឺរលាកអណ្ដាតមានអាការៈហៀរទឹកមាត់ជាប្រចាំ។ |
| ៦៩- **ជំងឺរលាកខួរឆ្អឹង / អូស្តេអូមីយេ-លីត**<br>អ. osteomyelitis<br>បារ. ostéomyélite (f.) | ជំងឺមួយប្រភេទដែលកើតឡើងដោយការរលាកព្រមគ្នាទាំងតួឆ្អឹង ទាំងខួរឆ្អឹង ដោយមូលហេតុច្រើនយ៉ាង។<br>ឧ. ជាទូទៅ ជំងឺរលាកខួរឆ្អឹងស្រួចស្រាវកើតមាននៅលើកុមារ។ |
| ៧០- **ជំងឺរលាកពហុសន្លាក់ / ប៉ូលីអាទ្រីត**<br>អ. polyarthritis<br>បារ. polyarthrite (f.) | ជំងឺមួយប្រភេទដែលកើតឡើងពីការរលាកស្រួចស្រាវឬរ៉ាំរ៉ៃក្នុងសន្លាក់ជាច្រើនព្រមៗគ្នា។<br>ឧ. ជំងឺរលាកពហុសន្លាក់ជារោគសញ្ញានៃជំងឺគ្រុនសន្លាក់ (Rhumatisme) ស្រួចស្រាវនិងរ៉ាំរ៉ៃ។ |

| | |
|---|---|
| ៧១- **ជំងឺរលាកឆ្អឹង / អូស្តេអ៊ីត**<br>អ. osteitis<br>បារ. ostéite (f.) | ជំងឺមួយប្រភេទដែលកើតពីការរលាកតួឆ្អឹង។<br>ឧ. ជាទូទៅ មូលហេតុដែលបង្កឱ្យរលាកឆ្អឹងបណ្តាលមកពីបាក់តេរី។ |
| ៧២- **ជំងឺរលាកទឹកសន្លាក់ / ស៊ីណូវីត**<br>អ. synovitis<br>បារ. synovite (f.) | ជំងឺរលាកទឹកសន្លាក់មានសភាពស្រួចស្រាល់ ឬរ៉ាំរ៉ៃដែលធ្វើឱ្យស្គួត ឬ មានសារធាតុរាវមិនប្រក្រតីដូចជា ឈាម ទឹករងៃ ឬ អាចមានខ្ទុះ។<br>ឧ. បើអ្នកជំងឺសង្ស័យថាខ្លួនមានជំងឺរលាកទឹកសន្លាក់ ត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យឯកទេស ចៀសវាងការប្រើថ្នាំដោយខ្លួនឯង។ |
| ៧៣- **ជំងឺរលាកមាត់**<br>អ. stomatitis<br>បារ. stomatite (f.) | ជំងឺរលាកភ្នាសសើមក្នុងមាត់បង្កដោយបាក់តេរី វីរុស ពពួកផ្សិត,...។<br>ឧ. កង្វះអនាម័យមាត់ធ្មេញជាកត្តាបណ្តាលឱ្យកើតជំងឺរលាកមាត់។ |
| ៧៤- **ជំងឺរលាកសរសៃពួរសាច់ដុំ / ជំងឺរលាកតង់ដុង**<br>អ. tendinitis<br>បារ. tendinite/ ténosite (f.) | ជំងឺបណ្តាលមកពីរលាកសរសៃពួរដែលភ្ជាប់សាច់ដុំទៅនឹងឆ្អឹង។ |
| ៧៥- **ជំងឺរាក**<br>អ. diarrhea / diarrhoea<br>បារ. diarrhée (f.) | ជំងឺដែលបណ្តាលឱ្យមានការបន្ទោបង់លាមកមានសភាពរាវនិងញឹកញាប់។<br>ឧ. នៅមន្ទីរពិសោធន៍បាក់តេរីសាស្ត្រ (laboratoire bactériologique)នេះ គេកំពុងវិភាគលាមករបស់អ្នកជំងឺរាកដើម្បីរកមូលហេតុរកមេរោគដែលបង្កឱ្យរាក។ |

| | |
|---|---|
| ៧៦- **ជំងឺវិទ្យា / ប៉ាតូវិទ្យា**<br>អ. pathology<br>បារ. pathologie ( f. ) | វិទ្យាសាស្រ្តសិក្សាអំពីជំងឺគ្រប់ប្រភេទ ដើម្បីរកមូលហេតុ រោគវិនិច្ឆ័យ និង វិធីព្យាបាល។ |
| ៧៧- **ជំងឺសន្លាក់**<br>អ. arthropathy<br>បារ. arthropathie ( f. ) | ជំងឺគ្រប់ប្រភេទដែលកើតឡើងនៅក្នុងសន្លាក់។<br>ឧ. អាការៈគាំងសន្លាក់ជាផលវិបាកនៃជំងឺសន្លាក់។ |
| ៧៨- **ជំងឺហឺត**<br>អ. asthma<br>បារ. asthme ( m. ) | អាការៈជំងឺកើតឡើងនៅផ្លូវដង្ហើមបណ្តាលឱ្យអ្នកជំងឺមានការលំបាកក្នុងការដកដង្ហើម ហត់ ដង្ហក់។ ជំងឺនេះបណ្តាលមកពីមូលហេតុច្រើនយ៉ាង។ អ្នកជំងឺអាចស្លាប់ បើពុំមានការព្យាបាលត្រឹមត្រូវទាន់ពេលវេលានោះទេ។<br>ឧ. ដើម្បីចៀសវាងជំងឺហឺត គួររស់នៅក្នុងបរិយាកាសល្អ អនាម័យល្អ និង ចៀសវាងការប្រើថ្នាំដោយគ្មានវេជ្ជបញ្ជា។ |
| ៨០- **ជំនាប់ស្អិត / អាដេរ៉ង់**<br>អ. adhesion<br>បារ. adhérence ( f. ) | អាការៈស្អិតជាប់គ្នារវាងសរីរាង្គពីរឬច្រើននៅក្នុងកន្លែងណាមួយនៃសព៌ាង្គកាយ ដោយមូលហេតុផ្សេងៗ។<br>ឧ. អស់រយៈពេលយូរ ក្រោយពីការវះកាត់ក្នុងពោះករណីខ្លះអាចកើតមានជំនាប់ស្អិតនៃពោះវៀន។ |

| | |
|---|---|
| ៨១- **ឈាមខន់ / កំណកឈាម**<br>អ. blood<br>បារ. caillot sanguin (m.) | ដុំឈាមដែលបានមកពីការកក សម្រាប់បិទសរសៃឈាមដាច់ឬរបួស និង បញ្ឈប់លំហូរឈាម។ |
| ៨២- **ឈឺក្បាល**<br>អ. cephalalgia / cephalgia / cephalodynia / headache<br>បារ. céphalalgie / céphalée (f) / mal de tête | អាការៈដែលឈឺចាប់ក្នុងក្បាល បណ្តាលមកពីមូលហេតុច្រើនយ៉ាង ពេលខ្លះមិនអាចរកមូល-ហេតុឃើញឡើយ ។<br>ឧ. ការសម្រាកគ្រប់គ្រាន់និងទៀងទាត់ពេលវេលាអាចជួយបន្ថយអាការៈឈឺក្បាល។ |
| ៨៣- **ដំណួចស្បែក**<br>អ. skin rash<br>បារ. rash cutané (m.) | កន្ទួលតូចៗនៅលើស្បែកដែលមិនស្ថិតស្ថេរជួនកាលរមាស់និង/ឬដែលបណ្តាលឱ្យមានអាការៈគ្រុនក្តៅ។<br>ឧ. ប្រតិកម្មឱសថមួយចំនួនអាចបណ្តាលឱ្យមានដំណួចស្បែក។ |
| ៨៤- **ដំណុះធ្មេញ**<br>អ. eruption of tooth<br>បារ. éruption dentaire (f.) | ការដុះធ្មេញដែលពកចេញពីអញ្ចាញ។<br>ឧ. កុមារមានដំណុះធ្មេញពីរលើក គឺ ធ្មេញទឹក-ដោះ (dent de lait) និង ធ្មេញអចិន្ត្រៃយ៍ (dent parmanante)។ |

| | |
|---|---|
| ៨៥- **ដំបៅងា**<br>អ. yaws<br>បារ. pian / buba / boubas (m.) | ជំងឺឆ្លងមួយប្រភេទរាតត្បាតនៅតំបន់ត្រូពិក ដោយសារមេរោគស្ពៀរ៉ូកែត (spirochète) ឈ្មោះ ត្រេប៉ូណេម៉ា ពែតឺនុយ (treponema pertenue)។ អ្នកជំងឺមានអាការៈក្តៅខ្លួន ឈឺចុកចាប់អវយវៈ បន្ទាប់មក មានចេញជាដំបៅពងបែក រលួយរហូតដល់ជាលិកាក្រោមស្បែក ជាពិសេស នៅលើមុខ ដៃ និង ជើង។<br>ឧ. ដំបៅងាអាចឆ្លងតាមរយៈការប៉ះពាល់ដោយផ្ទាល់លើដំបៅរបស់អ្នកជំងឺ។ |
| ៨៦- **ដុំពក/ទុយម័រ**<br>អ. tumor<br>បារ. tumeur (f.), néoplasme (m.) | ការដុះសាច់មិនប្រក្រតីនៃជាលិកាផ្សេងៗរបស់សរីរាង្គ។<br>ឧ. អ្នកជំងឺដែលមានដុំពក ត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យសល្យសាស្ត្រ (chirurgien)។ |
| ៨៧- **ដុំពកក្រពេញ / អាដេណូម**<br>អ. adenoma<br>បារ. adénome (m.) | ដុំពកបេនីញនៃក្រពេញណាមួយដែលមានរចនាសម្ព័ន្ធដូចក្រពេញនោះ និង មានស្រោមរុំពទ្ធយ៉ាងមាំ ហើយ មានសកម្មភាពសេក្រេស្យុង (sécré tion) ខ្លាំងក្លាជាងធម្មតា។<br>ឧ. អាដេណូមក្រពេញទីរ៉ូអ៊ីដ (thyroïde) ដែលមានសេក្រេស្យុងអ័រម៉ូនទីរ៉ុកស៊ីន (thyroxine) ច្រើនលើសធម្មតា តម្រូវឱ្យមានការវះកាត់យកចេញ។ |

| | |
|---|---|
| ៨៨- **ដុំពកខ្លាញ់/ លីប៉ូម**<br>អ. lipoma<br>បារ. lipome (m.) | ដុំពកបេនីញនៃជាលិកាខ្លាញ់មានស្រោមរុំពទ្ធជុំវិញ ដែលគ្មានទំនាក់ទំនងនឹងជាលិកាខាងក្រៅ។<br>ឧ. លីប៉ូមជាដុំពកដែលងាយស្រួលធ្វើរោគវិនិច្ឆ័យ និងព្យាបាល ប៉ុន្តែ វាអាចវិវត្តទៅជាជំងឺមហារីកដុំខ្លាញ់។ |
| ៨៩- **ដុំពកបេនីញ**/ ទុយម័របេនីញ<br>អ. benign tumor<br>បារ.tumeur bénigne (f.) | ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកស្លូត ដែលពុំទាន់មានលក្ខណៈកាចសាហាវ។<br>ឧ. ដុំពកខ្លាញ់ធម្មតាអាចជាដុំពកបេនីញ ប៉ុន្តែ ដើម្បីសុវត្ថិភាព អ្នកជំងឺត្រូវទៅពិគ្រោះជាមួយនឹងគ្រូពេទ្យវះកាត់។ |
| ៩០- **ដុំពកម៉ាលីញ / ទុយម័រម៉ាលីញ**<br>អ. malign tumor<br>បារ. tumeur maligne (f.) | ការដុះសាច់មិនប្រក្រតីនៃជាលិកាជាដុំពកកាច ដែលមានលក្ខណៈកាចសាហាវ ដែលបង្កជាជំងឺមហារីក(cancer)។<br>ដុំពកម៉ាលីញអាចកើតនៅគ្រប់សរីរាង្គទាំងអស់នៃសព៌ាង្គកាយ។ |
| ៩១- **ដុំពកសរសៃឡាំហ្វ៍ / ឡាំហ្វង់ហ្ស៊ីយ៉ូម**<br>អ. lymphangioma<br>បារ. lymphangiome (m.) | អង់ហ្ស៊ីយ៉ូម (angiome) នៃសរសៃឡាំហ្វ៍ (vaisseau lymphatique) មានលក្ខណៈហើមទន់ជ្រាយ ដែលច្រើនកើតនៅថ្នក់ខាងលើឆ្អឹងដងកាំបិត។ |

| | |
|---|---|
| ៩២- **ណូឌុល**<br>អ. nodule<br>បារ. nodule ( m. ) | ដុំពកបេនីញនៃជាលិកាដែលមានរាងមូលតូចៗ ក្រឡាច់ចុះឡើងនៅពេលយើងស្ទាប ជាពិសេស ដុំពកបេនីញនៃជាលិកាក្រពេញឡាំហ្វ (glande lymphatique )។ |
| ៩៣- **តុកស៊ីន / វិសធាតុ**<br>អ. toxin<br>បារ. toxine ( f. ) | សារធាតុដែលកកើតឡើងពីមីក្រូសារពាង្គកាយ ហើយបណ្តាលឱ្យមានជំងឺ។ តុកស៊ីនមានដើម-កំណើតចេញពីប្រភពពីរ :<br>- ចេញពីជីវ៉ាណូ ឬ ខ្មែរោគមួយ( germe )ដែល បង្កឱ្យមានជំងឺ។<br>- ចេញពីពួកផ្សិតពុលឬពីពិសរបស់សត្វល្អិត និង សត្វពស់ដែលមិនមែនជាមីក្រុប។ |
| ៩៤- **តុកស៊ីកូវិទ្យា / វិសវិទ្យា**<br>អ. toxicology<br>បារ. toxicologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីជាតុពុល។<br>ឧ. តុកស៊ីកូវិទ្យា / វិសវិទ្យាជាមុខវិជ្ជាមួយ នៅក្នុងកម្មវិធីសិក្សាផ្នែកវេជ្ជសាស្ត្រ។ |
| ៩៥- **ត្រូម៉ា**<br>អ. trauma<br>បារ. trauma ( m. ) | របួសធ្ងន់ធ្ងរខាងផ្លូវកាយឬផ្លូវចិត្តដែលបង្កដោយ គ្រោះថ្នាក់ឬវិបត្តិផ្សេងៗ។ |
| ៩៦- **ត្រូម៉ាតូវិទ្យា**<br>អ. traumatology<br>បារ. traumatologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពី មូលហេតុ រោគវិនិច្ឆ័យ និង វិធីព្យាបាលរបួសផ្លូវកាយឬផ្លូវចិត្តគ្រប់ប្រភេទ។ |

| | |
|---|---|
| ៩៧- **ត្រូម៉ាទីស**<br>អ. traumatism<br>បារ. traumatisme (m.) | ភាពគ្រាំគ្រាផ្លូវកាយឬផ្លូវចិត្តដែលបង្កឡើងដោយគ្រោះថ្នាក់ឬវិបត្តិធ្ងន់ធ្ងរពុំរ៉ៃផ្សេងៗ។ |
| ៩៨- **ទងសុក/ ទងផ្ចិត**<br>អ. umbilical cord<br>បារ. cordon ombilical (m.) | អន្តរសេរីរាង្គមានសណ្ឋានប្រហាក់ប្រហែលខ្សែពួរ ដែលតភ្ជាប់ពីផ្ចិតទារកទៅសុក។ នៅក្នុងទងសុក មានសរសៃឈាមពីរបែប មួយជាអាកទែ (artère)នាំឈាមពីសុកទៅទារក និង មួយទៀតជាវ៉ែន(veine)នាំឈាមពីទារកទៅសុកវិញ។ នៅក្រោយពេលទារកប្រសូតចេញពីផ្ទៃម្ដាយ ឆ្មបត្រូវកាត់ផ្ដាច់ទងសុកជាចាំបាច់។ |
| ៩៩- **ទល់លាមក**<br>អ. constipation / costiveness<br>បារ. constipation (f.) | ដំណើរបន្ទោបង់លាមកមិនប្រក្រតី គឺមានការយឺតការជុះមិនចេញ លាមកមានសភាពរឹង បណ្ដាលមកពីមូលហេតុផ្សេងៗបង្កឡើង។<br>ឧ. ដើម្បីចៀសវាងទល់លាមក គួរគប្បីបរិភោគបន្លែ ផ្លែឈើ និង ទឹក ឱ្យបានច្រើន។ |
| ១០០- **ទារកក្នុងផ្ទៃ**<br>អ. fetus<br>បារ. fœtus (m.) | គភ៌ដែលមានអាយុក្នុងរយៈពេលចាប់ពីខែទី៤រហូតដល់ពេលសម្រាល។<br>ឧ. ចំពោះស្ត្រីដែលមានគភ៌ចាប់ពីអាយុ៤ខែឡើងទៅ ទារកក្នុងផ្ទៃចាប់ផ្ដើមកម្រើក។ |
| ១០១- **ទារកមិនគ្រប់ខែ** | ទារកមានជីវិតធម្មតាដែលកើតមុនរយៈពេល៣៧សប្ដាហ៍ ហើយ មានទម្ងន់ក្រោម២២០០ក្រាម។ |

| | |
|---|---|
| អ. premature infant<br>បារ. enfant prématuré ( m. ) | ទារកមិនគ្រប់ខែ ត្រូវតែទទួលការចិញ្ចឹមដោយសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យឯកទេស។ |
| ១០២- **ទឹកកាម**<br>អ. sperm / semen<br>បារ. sperme ( m. ) | សារធាតុខាប់ពណ៌សដែលផលិតចេញពីសរីរាង្គបន្តពូជរបស់មនុស្សប្រុសឬសត្វឈ្មោល។ សារធាតុនេះមាន សេរ៉ូម ប្លាស្មា និង ស្ពែម៉ាតូសូអ៊ីត ( spermatozoïde )។ |
| ១០៣- **ទឹកដោះដំបូង**<br>អ. colostrum / neogala / protogala<br>បារ. colostrum ( m. ) | ទឹកដោះចេញក្រោយពីការសម្រាលកូនរួចរយៈពេលតែពីរឬបីថ្ងៃប៉ុណ្ណោះចំពោះមនុស្ស តែ ចំពោះសត្វ រយៈពេលអាចខ្លីឬវែងជាងនេះ។ ទឹកដោះនេះមានពណ៌លឿង សម្បូរដោយសារជាតិប្រូតេ-អ៊ីន ជាពិសេស អាល់ប៊ុយមីនដែលមានតួនាទីទប់ស្កាត់ជំងឺរលាកក្រពះ ពោះវៀន បន្សាត់អាចម៍ព្រៃ និង នាំអង់ទីករ( anticorps )ពីម្ដាយទៅកូន។<br>ឧ. ម្ដាយក្រោយពីការសម្រាលកូនចាំបាច់ត្រូវបំបៅកូនភ្លាមដោយទឹកដោះដំបូង។ |
| ១០៤- **ទឹកភ្លោះ**<br>អ. amniotic fluid<br>បារ. liquide amniotique ( m. ) | សារធាតុរាវដែលនៅជុំវិញទារកក្នុងផ្ទៃម្ដាយ។ ទឹកភ្លោះមានមុខងារជួយឱ្យទារកមានការធំធាត់ និងការពារពីការប៉ះទង្គិចផ្សេងៗ។<br>ឧ. ការបែកទឹកភ្លោះជាសញ្ញាមួយនៃការត្រៀមប្រសូត។ |

| | |
|---|---|
| ១០៥- **ទុរាហា-រូបត្ថម្ភ**<br>អ. malnutrition<br>បារ. malnutrition (f.) | អាការៈកើតឡើងចំពោះមនុស្សឬសត្វនៅពេលទទួលទានអាហារមិនត្រឹមត្រូវតាមនិយាមនៃតម្រូវការ។<br>ឧ. មនុស្សឬសត្វត្រូវទទួលអាហារឱ្យបានគ្រប់គ្រាន់ ដូចជា ប្រូទីដ លីពីដ គ្លុយស៊ីដ ជីវជាតិ (vitamine) និង សារជាតុរ៉ែខនិជ... ដើម្បីជៀសវាងទុរាហារូបត្ថម្ភ។ |
| ១០៦- **នីដាស្បុង**<br>អ. nidation<br>បារ. nidation (f.) | ការតាំងទីរបស់អណ្ឌៈ (œuf fécondé) ទំនៅភ្នាសក្នុងនៃស្បូន ដែលជាទូទៅ មានរយៈពេលពី៧ទៅ១០ថ្ងៃ ក្រោយពីកំណកំណើត។<br>ឧ. ក្នុងករណីមិនប្រក្រតី នីដាស្បុងអាចកើតមាននៅដៃស្បូនឬក្នុងធិទ្ធដ្ឋានពោះ (cavité abdominale) ដែលបង្កឱ្យទៅជាគភ៌ក្រៅស្បូន។ |
| ១០៧- **នោមខ្ទុះ**<br>អ. pyuria<br>បារ. pyurie (f.) | វត្តមានខ្ទុះក្នុងទឹកមូត្រដែលបង្កឱ្យទឹកមូត្រនោះល្អក់ ដែលជាអាការៈបញ្ជាក់អំពីអាំងហ្វិចស្យុង (infection) ប្រព័ន្ធទឹកមូត្រ។ |
| ១០៨- **នោមច្រើន/ប៉ូលីយូរី**<br>អ. polyuria<br>បារ. polyurie (f.) | អាការៈកើនបរិមាណទឹកនោមដែលបញ្ចេញមកក្រៅលើសពី៣លីត្រ ក្នុងរយៈពេល២៤ម៉ោង។ |

| | |
|---|---|
| ១០៩- **នោមឈាម**<br>អ. hematuria<br>បារ. hématurie ( f. ) | វត្តមានគុលិកាឈាមក្រហមក្នុងទឹកនោមដែលជាការបញ្ជាក់អំពីជំងឺប្រព័ន្ធទឹកមូត្រ។ |
| ១១០- **នោមញឹក/ ប៉ូឡាគ្យូរី**<br>អ. pollakiuria<br>បារ. pollakiurie ( f. ) | អាការៈនោមញឹកញាប់ ប៉ុន្តែ នោមម្តងៗមានបរិមាណតិច ដែលជារោគសញ្ញានៃជំងឺប្រូស្តាត ( prostate ) និង ការរលាកប្លោកនោម ( vessie )។ |
| ១១១- **នោមតិច/ អូលីគ្យូរី**<br>អ. oliguria<br>បារ. oligurie ( m. ) | អាការៈថយចុះបរិមាណទឹកនោមដែលបញ្ចេញមកក្រៅ ក្រោម៥០០មិល្លីលីត្រ ក្នុងរយៈពេល ២៤ម៉ោង ដែលជារោគសញ្ញានៃជំងឺតម្រងនោម ជំងឺហើម និង ការបាត់បង់លំនឹងអេឡិចត្រូលីត ( électrolyte )ក្នុងចរន្តឈាម។ |
| ១១២- **នោមទាស់ / ឌីស្យូរី**<br>អ. dysuria<br>បារ. dysurie ( f. ) | អាការៈឈឺចាប់និងពិបាកនៅពេលនោមដោយមូលហេតុរលាកបង្ហួរឬប្លោកនោម ដែលបណ្តាលមកពីកង្វះអនាម័យនៃប្រព័ន្ធទឹកមូត្រនិងប្រដាប់បន្តពូជខាងក្រៅ។ |
| ១១៣- **បន្ទុះស្បែក**<br>អ. skin eruption<br>បារ. éruption cutanée ( f. ) | កន្ទួលនៅលើស្បែកពណ៌ក្រហម ជួនកាលមានសណ្ឋានជាផ្លាក( taches ) ជួនកាលមានសណ្ឋានជាពងទឹក ( vésicules )។ អាការៈនេះអាចមានឬគ្មានគ្រុនក្តៅ។<br>ឧ. ជំងឺកញ្ជ្រឹលបង្កឱ្យមានបន្ទុះស្បែកពណ៌ក្រ-ក្រហមស្ទើរពាសពេញសព៌ាង្គកាយ។ |

| | |
|---|---|
| ១១៤- **បាក់តេរី**<br>អ. bacterium<br>បារ. bactérie (f.) | អតិសុខុមប្រាណមានលក្ខណៈជាឯកកោសិកា រស់នៅក្នុងដី ទឹក និង ខ្យល់ ដែលមានផលប្រយោជន៍ ឬ បង្កជំងឺដល់មនុស្ស សត្វ និង រុក្ខជាតិ។ បាក់តេរីមានសណ្ឋានច្រើនប្រភេទ និង មានសកម្មភាពខុសប្លែកៗពីគ្នា។<br>ឧ.១- បាក់តេរីស្តាហ្វីឡូកូក (staphylocoque) ជាភ្នាក់ងារបង្កឱ្យកើតបូស។<br>ឧ.២- បាក់តេរីនៅក្នុងយ៉ាអួ (yaourt) ជាបាក់តេរីមានប្រយោជន៍។ |
| ១១៥- **បាក់តេរីវិទ្យា**<br>អ. bacteriology<br>បារ. bactériologie (f.) | វិទ្យាសាស្ត្រមូលដ្ឋានជាផ្នែកមួយនៃជីវមីក្រុបវិទ្យា (microbiologie) ដែលសិក្សាអំពីលក្ខណៈសណ្ឋាន ការលូតលាស់វដ្តជីវិត និង សកម្មភាពរបស់បាក់តេរី ទៅលើសព៌ាង្គកាយមនុស្ស សត្វ និង រុក្ខជាតិ។<br>ឧ. បាក់តេរីវិទ្យាជាមុខវិជ្ជាមូលដ្ឋានមួយដែលសិក្សាស្រាវជ្រាវទូលំទូលាយអំពីបាក់តេរី ក្នុងវិស័យជីវសាស្ត្រ វេជ្ជសាស្ត្រ និង កសិកម្ម។ |
| ១១៦- **បាក់តេរីស៊ីដ/បាក់តេរីឃាត**<br>អ. bactericide<br>បារ. bactéricide (m.) | សារធាតុដែលសម្លាប់ជាស្ថាពរនូវពពួកបាក់តេរី។<br>ឧ. ដាហ្សេណង់ (dagénan) ជាបាក់តេរីស៊ីដដែលគេប្រើនៅក្រោយសង្គ្រាមលោកលើកទី២។ |

| | |
|---|---|
| ១១៧- **បាក់តេរី-យោស្តាទិក**<br>អ. bacteriostatic/ bacteriostasis<br>បារ.bactériostatique (m.) | សារធាតុដែលអាចបញ្ឈប់ឬទប់ស្កាត់ការរីកលូតលាស់របស់បាក់តេរី។<br>ឧ.អង់ទីប្យូទិកនិងអង់ទីសិបទិកមួយចំនួនជាបាក់តេរីយោស្តាទិក។ |
| ១១៨- **បាក់តេរី-យោតេរ៉ាពី / បាក់-តេរីព្យាបាល**<br>អ. bacteriotherapy<br>បារ.bactériothérapie (f.) | ការប្រើបាក់តេរីរស់ឬរំងាប់សម្រាប់ព្យាបាលជំងឺដែលបង្កដោយបាក់តេរីចម្លែ។<br>ឧ. ការប្រើសេរ៉ូមអង់ទីតេតានិក (sérum antitétanique) ជាវិធីមួយក្នុងចំណោមបាក់តេរីព្យាបាល។ |
| ១១៩- **បាក់តេរ៉េមី / បាក់តេរីក្នុងឈាម**<br>អ. bacteremia<br>បារ. bactériémie (f.) | វត្តមានបាក់តេរីនៅក្នុងចរន្តឈាម។<br>ឧ. អាំងហ្វិចស្យុង (infection) ដែលបណ្តាលឱ្យឡើងកម្តៅ (គ្រុន) ជារោគសញ្ញានៃបាក់តេរ៉េមី។ |
| ១២០- **បាក់តេរីយ៉ូរី**<br>អ. bacteriuria<br>បារ. bactériurie (f.) | វត្តមានបាក់តេរីដ៏ច្រើនលើសលប់នៅក្នុងទឹកនោមថ្មីៗ។<br>ឧ. សិបទីសេមី (septicémie) បង្កឱ្យមានបាក់តេរីយ៉ូរី។ |

| | |
|---|---|
| ១២១- **បំណាក់ឆ្អឹងចំហ**<br>អ. open fracture<br>បារ. fracture ouverte (f.) | បំណាក់ឆ្អឹងដោយមានរបេះសាច់និងធ្លាយស្បែកនៅចំកន្លែងបាក់នោះ ដែលបង្កឱ្យមានការហូរឈាមចេញមកក្រៅ។ |
| ១២២- **បំណាក់ឆ្អឹងបិទ**<br>អ. closed fracture<br>បារ. fracture fermée (f.) | បំណាក់ឆ្អឹងដោយគ្មានរបួសឬធ្លាយស្បែកដែលអាចបង្កឱ្យមានកំណកឈាម(hématome) នៅត្រង់កន្លែងនោះ។ |
| ១២៣- **បំណាក់ឆ្អឹងឯកឯង**<br>អ. spontaneous fracture<br>បារ. fracture spontanée (f.) | បំណាក់ឆ្អឹងបណ្តាលមកពីគ្រោះថ្នាក់តិចតួចមិននឹកស្មានដល់ដែលគេជួបប្រទះភាគច្រើននៅលើស្ត្រីវ័យចំណាស់ និង ឆ្អឹងផុយស្រួយ (astéopé-nie)។ |
| ១២៤- **បំណាក់ឆ្អឹងមានជំងឺ**<br>អ. pathologic fracture<br>បារ. fracture pathologique (f.) | បំណាក់ឆ្អឹងចំពោះឆ្អឹងដែលកំពុងមានជំងឺរ៉ាំរ៉ៃ ដូចជា របេងឆ្អឹង មហារីកឆ្អឹង ឬ ទុយម័រផ្សេងៗរបស់ឆ្អឹង។<br>ឧ. បំណាក់ឆ្អឹងមានជំងឺរបេងឆ្អឹងខ្នង(mal de pott) អាចធ្វើឱ្យជើងអ្នកជំងឺទាំងសងខាងស្លាប់ស្តូក(paraplégie)។ |

| | |
|---|---|
| ១២៥- **ប្រមេះ-ទឹកបាយ**<br>អ. blennorrhagia/ gonorrhea<br>បារ. blennorragie / gonorrhée (f.) | ជំងឺម្យ៉ាងដែលមានអាការៈហូរខ្ទុះយ៉ាងច្រើនតាមបង្ហួរនោម ដោយសារអាំងហ្វិចស្យុងនៃបាក់តេរីហ្គោណូកូក(gonocoque)។<br>ឱ. ជំងឺប្រមេះទឹកបាយភាគច្រើនឆ្លងតាមការរួម-ភេទដោយពុំបានប្រុងប្រយត្ន។ |
| ១២៦- **ប្រសូតិកម្ម**<br>អ. child birth / delivery/parturition<br>បារ. accouchement (m.) / parturition (f.) | ការសម្រាលទារកនិងឧបសម្ព័ន្ធចេញពីផ្ទៃម្ដាយដែលមហាជននិយមហៅថាការសម្រាលកូនឬការឆ្លងទន្លេ។<br>ឱ. ជាទូទៅ ថ្ងៃទី២៨០នៃគភ៌ជាថ្ងៃកំណត់នៃប្រសូតិកម្ម។ |
| ១២៧- **ប្រសូតិកម្មមិនគ្រប់ខែ**<br>អ. premature birth / premature delivery / premature parturition<br>បារ. accouchement prématuré / accouchement avant terme (m.) | ការសម្រាលទារកដែលនៅមានជីវិតនិងឧបសម្ព័ន្ធចេញពីផ្ទៃម្ដាយមុនកាលកំណត់។<br>ឱ.ប្រសូតិកម្មមិនគ្រប់ខែច្រើនកើតឡើងនៅចន្លោះសប្ដាហ៍ទី៣៥ និង ៣៦នៃគភ៌ ដែលវិទ្យាសាស្ត្របច្ចុប្បន្នអាចសង្គ្រោះជីវិតទារកបាន១០០%។ |
| ១២៨- **ប្រសូតិកម្ម-ពិបាក** | ការសម្រាលទារករបស់ស្ត្រីមានគភ៌តាមផ្លូវធម្មជាតិដោយពិបាកឬមិនរួច បណ្ដាលមកពីត្រគាកម្ដាយ |

| | |
|---|---|
| អ. dystocic delivery<br>បារ. accouchement dystocique ( m. ) | ចង្អៀតឬមកពីទារកមានក្បាលធំពេកដែលចាំបាច់ទាមទារឱ្យគ្រូពេទ្យដោះស្រាយតាមបច្ចេកទេសជំនាញ។ |
| ១២៩- **ប្រសូតិ-វិទ្យា / សម្ភពវិទ្យា**<br>អ. obstetrics<br>បារ. obstétrique ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីគភ៌និងការបង្កើតទារក។<br>ឧ. ធ្នូបមានមុខងារសំខាន់ក្នុងការបម្រើផ្នែករោគស្ត្រីនិងប្រសូតិវិទ្យា។ |
| ១៣០- **ប្រូទីដ**<br>អ. protid<br>បារ. protide( m. ) | សារធាតុផ្សំឡើងដោយកាបោន(C), អ៊ីដ្រូហ្សែន(H), អុកស៊ីហ្សែន(O) និង អាសូត(N) ដែលឯកតាដំបូងគឺជាអាស៊ីដអាមីណេ( acide aminé ) ជាច្រើនតភ្ជាប់គ្នាដោយសម្ព័ន្ធប៉ិបទីដ ( peptide )។<br>ឧ. សារធាតុប្រូទីដមានច្រើននៅក្នុងគ្រាប់ធញ្ញជាតិ ជាពិសេស គ្រាប់សណ្តែកសៀង ក្នុងសាច់សត្វ ក្នុងបន្លែ...។ |
| ១៣១- **ផែនការ-គ្រួសារ**<br>អ. family planning<br>បារ. planning familial ( m. ) / planification familiale ( f. ) | គម្រោងឱ្យមានកូនតាមគោលបំណង ដូចជា ការពន្យារកំណើត ការអប់រំសុខភាព ការទប់កំណើត ជាដើម ដើម្បីកាត់បន្ថយការប៉ះពាល់ដល់សុខភាពម្តាយនិងកូន ព្រមទាំងសេដ្ឋកិច្ចគ្រួសារ។ |

| | |
|---|---|
| ១៣២- **ពងស្វាស**<br>អ. testes/<br>testicle/ testis<br>បារ. testicule<br>( m. ) | ក្រពេញភេទរបស់មនុស្សប្រុសឬសត្វឈ្មោល។ នៅពេលពេញវ័យ ក្រពេញភេទនេះអាចផលិតស្ពែ-ម៉ាតូសូអ៊ីត ( spermatozoïde ) និងអ័រម៉ូនតេស្តូស្តេ-រ៉ូន ( hormone testotérone )/អង់ដ្រូហ្សែន។<br>ឳ. ការចងបំពង់ទឹកកាមដែលចេញពីពងស្វាស ជាវិធីពន្យារកំណើតមួយបែប។ |
| ១៣៣- **ពេញវ័យ / មជ្ឈិមវ័យ**<br>អ. adult<br>បារ. adulte<br>( m. ) / ( f. ) | វ័យរបស់មនុស្សចាប់ពីវ័យជំទង់រហូតដល់វ័យចាស់។ |
| ១៣៤- **ពោះ**<br>អ. abdomen<br>បារ.abdomen ( f. ) | ផ្នែកនៃដងខ្លួនស្ថិតនៅចន្លោះទ្រូងនិងឆ្អឹងត្រគាក ដែលក្នុងនោះ មានប្រព័ន្ធរំលាយអាហារ ប្រព័ន្ធទឹកមូត្រ និង សរីរាង្គដទៃទៀត។ |
| ១៣៥- **ព្យាបាល-វិទ្យា / វិទ្យាសាស្ត្រព្យាបាល**<br>អ. therapeutics<br>បារ. thérapeutique<br>( f. ) | វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលនិងថែទាំ ដើម្បីឱ្យអ្នកជំងឺជាសះស្បើយ។ |

| | |
|---|---|
| ១៣៦- **ព្រូនចង្កឹះ**<br>អ. ascarid<br>បារ. ascaris/ ascaride (m.) | បរាសិតណេម៉ាតូដ(nématodes)ដែលមានរាងបំពង់វែង(cylindre) ពណ៌ប្រផេះ ឬ ពណ៌ក្រហមមានប្រវែងពី២០ទៅ៤០សង់ទីម៉ែត្រ ដែលរស់នៅក្នុងសព៌ាង្គកាយមនុស្សឬសត្វ។<br>ឧ. ក្មេងហូបចុកគ្មានអនាម័យនាំឱ្យកើតព្រូនចង្កឹះ។ |
| ១៣៧- **ព្រូនតម្កក់**<br>អ. hookworm<br>បារ. ankylostome (m.) / necator americanus | បរាសិតណេម៉ាតូដ (nématodes) មានប្រវែងពី៨ទៅ១៥មីល្លីម៉ែត្រ។ បរាសិតនេះរស់នៅនិងជញ្ជក់ឈាមនៅត្រង់គល់ពោះវៀន(duodénum)បណ្តាលឱ្យមានជំងឺស្លេកស្លាំង។ ជាទូទៅ វាឆ្លងតាមមាត់ ឬស្បែក។ |
| ១៣៨- **ព្រូនសំប៉ែត / ព្រូនវែង**(តេនញ៉ា)<br>អ. tapeworm<br>បារ. taenia (m.) | បរាសិតសេស្តូដ(cestodes) មានច្រើនប្រភេទរស់នៅក្នុងពោះវៀនមនុស្សនិងសត្វមានឆ្អឹងកង (vertébré) មានប្រវែងពី១៣មីល្លីម៉ែត្ររហូតដល់៩ម៉ែត្រ មានសណ្ឋានជាកង់ៗ ហើយ មានឈ្នប់នៅនឹងក្បាលសម្រាប់ថ្កក់ជាប់ទៅនឹងស្រទាប់ខាងក្នុងនៃពោះវៀន។ |
| ១៣៩- **ព្រូនអន្ទង់**<br>អ. eelworm<br>បារ. anguillule (f.) | បរាសិតណេម៉ាតូដ (nématodes) មានប្រវែង២មីល្លីម៉ែត្រ ឆ្លងតាមស្បែក បង្កឱ្យកើតជាកន្ទាលត្រអាក រមាស់។ នៅពេលដែលបរាសិតនេះចូល |

| | |
|---|---|
| | ទៅដល់សួត វាបង្កឱ្យមានជំងឺសួត ឱ្យមានជំងឺក្អកចុកទ្រូងជាដើម។ បន្ទាប់មកទៀត វាអាចបង្កឱ្យមានជំងឺផ្លូវរំលាយអាហារ ដូចជា ការឈឺចុកចាប់ក្នុងពោះ ទល់លាមក រាករូស និង បង្កឱ្យមានជំងឺស្លេកស្លាំង។ |
| ១៤០- **ភាពជាំ**<br>អ. ecchymosis<br>បារ. ecchymose (f.) | អាការៈមានគុលិកាឈាមជ្រាបចូលក្នុងជាលិកាគ្របដណ្ដប់ ដែលបង្កឡើងដោយត្រូម៉ា ឬ ដោយការជ្រាបឈាមចេញពីសរសៃប្លូ/សរសៃកាពីលែ (capillaires)។ |
| ១៤១- **ភាពមានគភ៌**<br>អ. pregnancy<br>បារ. grossesse (f.) | ភាពស្ត្រីមានផ្ទៃពោះចាប់ពីថ្ងៃបង្កកំណើត (ថ្ងៃបាត់រដូវ) រហូតដល់ថ្ងៃសម្រាល។<br>ប្រជាជនខ្មែរនិយមប្រើពាក្យៈទ្រង់គភ៌(រាជសព្ទ) ការមានគភ៌ ការមានផ្ទៃពោះ ការមានទម្ងន់ ការពពោះ ស្ត្រីផើម។<br>ឧ. ជាធម្មតា ស្ត្រីមានគភ៌មានរយៈពេល២៨០ថ្ងៃ។ |
| ១៤២- **ភាពស៊ាំ**<br>អ. immunity<br>បារ. immunité (f.) | ដំណើរនៃសរីរាង្គដែលអាចទប់ស្កាត់មិនឱ្យឆ្លងជំងឺពីខាងក្រៅដែលបង្កឡើងដោយភ្នាក់ងារបង្កជំងឺណាមួយ។<br>ឧ. ការចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ(B) បង្កឱ្យមានភាពស៊ាំនឹងជំងឺនេះបាន។ |

| | |
|---|---|
| ១៤៣- **ភាពឡើងខ្លាញ់**<br>អ. adiposis<br>បារ. adipose / adiposité ( f. ) | កំណើននៃសារធាតុខ្លាញ់ឡើងខ្ពស់នៅក្នុងជាលិកា ដែលជាទូទៅ បង្កឱ្យធាត់។ |
| ១៤៤- **ភាពអារ**<br>អ. sterility<br>បារ. stérilité ( f. ) | ការមិនអាចបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។<br>ឧ. ចំហាយវិទ្យុសកម្មបង្កឱ្យមានភាពអារឪពុកម្ដាយ ឬ វិរូបភាពទារក។ |
| ១៤៥- **ភាពឥតអារ / ហ្វែទីលីតេ**<br>អ. fertility<br>បារ. fertilité ( f. ) | លទ្ធភាព/សម្បទារបស់មនុស្ស សត្វ និង រុក្ខជាតិ ដែលអាចបន្តពូជបានចំពោះមនុស្ស គឺចាប់ពីពេលពេញក្រមុំរហូតដល់ពេលអស់រដូវ។ |
| ១៤៦- **ភើ**<br>អ. eructation/ belching<br>បារ. éructation ( f. ) | ដំណើរចេញឧស្ម័នពីក្រពះមកតាមមាត់។<br>ឧ. អ្នកឈឺក្រពះច្រើនមានភើជាញឹកញាប់។ |
| ១៤៧- **ភើជូរ**<br>អ.acid regurgitation<br>បារ. régurgitation acide ( f. ) | ដំណើរចេញឧស្ម័នពីក្រពះមកតាមមាត់ដោយមានជាតិជូរ។<br>ឧ. ការភើជូរជារោគសញ្ញាមួយនៃជំងឺក្រពះ។ |

| | |
|---|---|
| ១៤៨- **ភ្នាសក្នុងស្បូន/អង់ដូម៉ែត្រ** អ. endometrium បារ. endomètre (m.) | ស្រទាប់ជាលិកាដែលពាសផ្ទៃខាងក្នុងបំផុតនៃស្បូននិងដៃស្បូន (trompe de fallope)។ ২. អង់ដូម៉ែត្រជាទីតាំងនីដាស្យុង (nidation) នៃគភ៌ដែលទំនៅក្នុងស្បូន។ |
| ១៤៩- **ភ្នាសទារកក្នុងផ្ទៃ** អ. fetal membrane បារ. membrane fœtale (f.) | អន្តរសរីរាង្គមួយផ្នែកនៃគភ៌ក្នុងស្បូន មានសណ្ឋានជាស្រោមស្តើង ស្រោបទារក ដែលមានពីរស្រទាប់ គឺ អាម៉្ញូស (amnios) និង កូរីយ៉ុង (chorion)។ ২. ក្នុងករណីមានទឹកភ្លោះច្រើន/អ៊ីដ្រាម៉្ញូស (hydramnios) គ្រូពេទ្យត្រូវចោះភ្នាសទារកក្នុងផ្ទៃ ដើម្បីពន្លឿនប្រសូតិកម្មតាមផ្លូវធម្មជាតិ។ |
| ១៥០- **មីញ៉ូតូនី** អ. myotonia បារ. myotonie (f.) | ការកន្ត្រាក់សាច់ដុំឬប្រព័ន្ធសាច់ដុំដោយកម្លាំងសាច់ដុំផ្ទាល់ ឬ ដោយរំញោចពីខាងក្រៅ បណ្តាលឱ្យសាច់ដុំនោះឡើងរឹងមួយរយៈពេលខ្លី។ |
| ១៥១- **មីញ៉ូសាកូម** អ. myosarcoma បារ. myosarcome (m.) | មហារីកសាច់ដុំទាំងពីរប្រភេទ គឺ សាច់ដុំឆ្នូត (mucle strié) និង សាច់ដុំរលីង (muscle lisse) ដែលមានលក្ខណៈកាចសាហាវដោយសារការរីករាលដាលកោសិកាមហារីកលឿនតាមរយៈចរន្តឈាមនិងចរន្តឡាំហ្វ៍។ |
| ១៥២- **មុខរបួស** អ. wound បារ. plaie (f.) | អាការៈដាច់រហែកឬបាត់បង់ជាលិកាគ្របដណ្តប់សព៌ាង្គកាយឬសរីរាង្គដែលបង្កឡើងដោយការប៉ះទង្គិច។ |

| | |
|---|---|
| ១៥៣- **មុន**<br>អ. acne<br>បារ. acné (f.) | ជំងឺស្បែកមានលក្ខណៈរលាកនិងមានខ្ទុះនៅក្នុងក្រពេញញើស (glande sébacée) ឬក្រពេញគល់រោម (glande pilosébacée) ជាពិសេស នៅស្បែកមុខនិងខ្នង ប៉ុន្តែ បាតដៃឬបាតជើងពុំមានកើតមុនទេ។ |
| ១៥៤- **មូត្រវិទ្យា**<br>អ. urology<br>បារ. urologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីប្រព័ន្ធទឹកនោម ជំងឺ និង វិធីព្យាបាល។ |
| ១៥៥- **មេតាស្តាស**<br>អ. metastasis<br>បារ. métastase (f.) | ការរីករាលដាលកោសិកាមហារីក បាក់តេរី វីរុស ឬ បរាសិត តាមចរន្តឈាមឬចរន្តឡាំហ្វ៍ ចេញពីចំណុចដើមទៅសរីរាង្គដទៃទៀត។ |
| ១៥៦- **រដូវច្រើន/ មេណូរ៉ាហ្ស៊ី**<br>អ. menorrhagia / hypermenorrhea<br>បារ. ménorragie/ hyperménorrhée (f.) | អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណច្រើន និងជួនកាលមានរយៈពេលវែងខុសធម្មតា ដែលអាចបណ្តាលមកពីវិបត្តិកំណកឈាម វិបត្តិលំនឹងអ័រម៉ូន ឬ ទុយម័របេនីញរបស់ស្បូន។ ស្ត្រីធ្លាក់រដូវច្រើន បង្កឱ្យមានអាការៈស្លេកស្លាំង អស់កម្លាំងជាប្រចាំ ដែលតម្រូវឱ្យអ្នកជំងឺនោះទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស។ |
| ១៥៧- **រដូវលំបាក**<br>អ. dysmenorrhea<br>បារ. dysménorrhée (f.) | ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ ក្នុងរយៈពេលដែលស្ត្រីមានរដូវ។<br>ឧ. នៅពេលមានរដូវលំបាក ស្ត្រីអាចប្រើឱសថបន្ថយការឈឺចាប់បាន។ |

| | |
|---|---|
| ១៥៨- **រដូវស្ត្រី**<br>អ. menses<br>បារ. règles / men-struation (f.) | ការធ្លាក់ឈាមពីស្បូនប្រចាំខែរបស់ស្ត្រីក្នុងវ័យបន្តពូជ ក្រៅពីពេលមានគភ៌ ដែលជាធម្មតា មានរយៈពេលពី ៣ទៅ៧ថ្ងៃ។<br>ឧ. ក្មេងស្រីដែលមានរដូវស្ត្រីជាលើកដំបូងបញ្ជាក់ថាក្មេងស្រីនោះពេញក្រមុំ។ |
| ១៥៩- **រដូវដំបូង / មេណាក**<br>អ. menarche<br>បារ.ménarche (m.)/ ménarchie (f.) | ដំណើរធ្លាក់រដូវដំបូងរបស់ស្ត្រីក្រមុំ។<br>ឧ. ស្ត្រីក្រមុំអាចមានរដូវដំបូង ចាប់ពីអាយុ៩ទៅ១៦ឆ្នាំ។ |
| ១៦០- **រដូវតិច / អូលីហ្គោមេណូរ៉េ**<br>អ. oligomenor-rhea<br>បារ. oligoménor-rhée (f.) | អាការៈធ្លាក់ឈាមរដូវស្ត្រីក្នុងបរិមាណតិចតួចខុសធម្មតា។ មូលហេតុដែលបង្កឱ្យមានរដូវតិច គឺ វិបត្តិលំនឹងអ័រម៉ូន វិបត្តិផ្លូវចិត្ត កង្វះអាហារូបត្ថម្ភ និងជំងឺមួយចំនួនទៀត។ |
| ១៦១- **រលាកភ្នាសក្នុងនៃស្បូន / អង់ដូមេទ្រីត**<br>អ. endometritis<br>បារ. endométrite (f.) | អាំងហ្វិចស្យុងស្រទាប់ក្នុងនៃស្បូន (endomètre) ដៃស្បូន (trompe de fallope) ដែលមានលក្ខណៈស្រួចស្រាវឬរ៉ាំរ៉ៃ ជាពិសេស អាចកើតមានក្រោយពេលសម្រាល ក្រោយពេលរលូតកូន ឬ ក្រោយពេលដាក់កងក្នុងស្បូន។<br>ឧ. អង់ដូមេទ្រីតទាមទារឱ្យមានការព្យាបាលត្រឹម |

| | |
|---|---|
| | ត្រូវ ដើម្បីជៀសវាងនូវផលវិបាកច្រើនយ៉ាង ដូចជាការស្ទះបំពង់ដៃស្បូន ការបង្កឱ្យមានភាពអារ ឬការមានគភ៌ក្រៅស្បូន។ |
| ១៦២- **រលាកមាត់ស្បូន / សែវីស៊ីត**<br>អ. cervicitis<br>បារ. cervicite (f.) | អាការៈអាំងហ្វិចស្យុងនៃមាត់ស្បូនដែលបណ្ដាលមកពីផ្សិត, បាក់តេរី,... មានលក្ខណៈរលាក ក្រហម ធ្លាក់ស ជួនកាលបង្កឱ្យរមាស់និងឈឺផ្សាផ្នែកខាងក្រៅនៃប្រដាប់បន្តពូជ និង អាចបង្កឱ្យធ្លាក់ឈាមតិចៗនៅពេលរួមសង្វាស។ |
| ១៦៣- **រលាកស្បូន / មេទ្រីត**<br>អ. metritis<br>បារ. métrite (f.) | អាការៈរលាកជាទូទៅនៃជាលិកាស្បូនចាប់ពីភ្នាសក្នុងនៃស្បូន (muqueuse utérine) រហូតដល់សាច់ដុំនៃស្បូន (muscle utérin)។<br>ន. មេទ្រីតជាអាំងហ្វិចស្យុងធ្ងន់ធ្ងរតម្រូវជាចាំបាច់ឱ្យអ្នកជំងឺទៅជួបនឹងគ្រូពេទ្យឯកទេសរោគស្ត្រីដើម្បីពិនិត្យនិងព្យាបាល។ |
| ១៦៤- **រោគក្អកមាន់**<br>អ. pertussis/ whooping cough<br>បារ. coqueluche (f.) | ជំងឺរាតត្បាតម៉្យាងបង្កឡើងដោយមេរោគឈ្មោះបាស៊ី Bardetella pertussis / hæmophilus pertussis ឬ bacillus pertussis។ ជាទូទៅរោគនេះកើតនៅលើទារក ឬ កុមារ ដោយការក្អកកន្ត្រាក់យ៉ាងខ្លាំងជាប់ៗគ្នានិងមានរយៈពេលយូរ។ នៅពេលដកដង្ហើមចូល ក្រោយការក្អកម្ដងៗ មាន |

| | |
|---|---|
| | ឮសូរដូចសំឡេងមាន់ ជួនកាលទារក ឬ កុមារ ហូរទឹកភ្នែក ទឹកសំបោរ និង ទឹកមាត់ទៀតផង។<br>ឧ. រោគក្អកមាន់អាចការពារបានដោយការចាក់ថ្នាំបង្ការ( vaccin )។ |
| ១៦៥- **រោគគ្រុនឈាម**<br>អ . dengue / hemorrhagic fever/ dengue fever<br>បារ. dengue hémorragique / dengue ( f. ) | រោគឆ្លងតាមមូសខ្លា ឈ្មោះ Aédes oegypti មកមនុស្ស ហើយ ច្រើនកើតនៅតំបន់ត្រូពិក។ រោគនេះកើតឡើងដោយសារវីរុសឈ្មោះdengueដែលស្ថិតនៅក្នុងក្រុម flaviviridae។<br>ឧ. នៅរដូវភ្លៀង យើងត្រូវកម្ចាត់មូសខ្លាដើម្បីកុំឱ្យកើតជំងឺគ្រុនឈាម។ |
| ១៦៦- **រោគគ្រុនពោះវៀន**<br>អ . typhoid fever<br>បារ. fièvre typhoïde ( f. ) | រោគឆ្លងដោយមេរោគឈ្មោះ សាលម៉ូណេឡាទីហ្វី ( Salmonella typhi ) ឬ មេរោគឈ្មោះ បាស៊ីអេប៊ែរ ( bacille d´Eberth )។<br>ឧ. អ្នកស្រាវជ្រាវបានចុះទៅពិនិត្យតំបន់ជនបទមួយកន្លែងដែលមានកើតរោគគ្រុនពោះវៀនដោយមូលហេតុប្រើទឹកមិនស្អាត។ |
| ១៦៧- **រោគរបេង**<br>អ . tuberculosis<br>បារ. tuberculose ( f. ) | រោគឆ្លងតាមផ្លូវដង្ហើមបង្កឡើងដោយមេរោគឈ្មោះ បាស៊ីកុក ( bacille de Koch BK : Mycobacterium tuberculosis ) ដែលកើតឡើងនៅលើសរីរាង្គណា |

| | |
|---|---|
| | មួយរបស់មនុស្សឬសត្វ ដូចជា សួត ឆ្អឹង ពោះវៀន តម្រងនោម ស្រោមខួរ កូនកណ្ដុរ។ ល។<br>ឧ.១- អ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនេះមានរោគរបេងសួត។<br>ឧ.២- កុមារនេះមានរោគរបេងកូនកណ្ដុរ (ប្រជាជនខ្មែរនិយមហៅថា កើតម្រេញ)។ |
| ១៦៨- **រោគស្វាយ**<br>អ. syphilis<br>បារ. syphilis (f.) | កាមរោគម៉្យាងដែលបង្កឡើងដោយមេរោគឈ្មោះ Spirochète treponema pallidum de schaudinn។ ជំងឺនេះឆ្លងតាមការរួមភេទ និង ពីម្ដាយទៅទារកក្នុងផ្ទៃដែលមានរោគសញ្ញាច្រើនបែប។ ជំងឺនេះអាចវិវត្តពីស្រាលទៅធ្ងន់តាមបីដំណាក់កាល។ បើគ្មានការព្យាបាលត្រឹមត្រូវនិងទាន់ពេលវេលានោះទេ វាអាចបណ្ដាលឱ្យខូចសរីរាង្គផ្សេងៗជាច្រើន និង អាចឱ្យស្លាប់បាន។<br>ឧ. ការប្រើប្រាស់ស្រោមអនាម័យធ្វើឱ្យអត្រានៃការឆ្លងរោគស្វាយមានការថយចុះ។ |
| ១៦៩- **លីពីដ**<br>អ. lipid<br>បារ. lipide (m.) | សារធាតុប្រេង ខ្លាញ់ ដែលមិនរលាយក្នុងទឹក តែរលាយក្នុងធាតុរំលាយសរីរាង្គ (solvant organique) ហើយដែលមានម៉ូលេគុលអាស៊ីដ ប្រេង ខ្លាញ់ (acide gras)។ |

| | |
|---|---|
| ១៧០- **លំហូរឈាម**<br>អ. hemorrhage / bleeding<br>បារ. hémorragie (f.) | អាការៈមានឈាមហូរចេញពីសរសៃឈាមដាច់ ឬរបួស។ |
| ១៧១- **លំហូរឈាមពីស្បូន/មេត្រូរ៉ាហ្ស៊ី**<br>អ. metrorragia<br>បារ. métrorragie (f.) | អាការៈធ្លាក់ឈាមពីក្នុងស្បូនក្រៅពីពេលមានរដូវ។<br>ឧ. ជំងឺស្បូនភាគច្រើនបង្កឱ្យមានមេត្រូរ៉ាហ្ស៊ី។ |
| ១៧២- **វក្កំ/តម្រងនោម**<br>អ. kidney<br>បារ. rein (m.) | សរីរាង្គរបស់មនុស្សឬសត្វមានសណ្ឋានស្រដៀងនឹងគ្រាប់សណ្តែកដែលមានមុខងារច្រោះយកជាតិអាសូតចេញពីឈាម បង្កើតជាទឹកនោម ធ្វើឱ្យមានលំនឹងសារធាតុផ្សេងៗក្នុងឈាម។<br>ឧ. ជំងឺរលាកវក្កំ ឬ ជំងឺរលាកតម្រងនោម។ |
| ១៧៣- **វក្កំវិទ្យា**<br>អ. nephrology<br>បារ. néphrologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីជំងឺនិងវិធីព្យាបាលវក្កំ។ |
| ១៧៤- **វដ្តរដូវ**<br>អ. menstrual cycle<br>បារ. cycle menstruel (m.) | ខួបរដូវរបស់ស្ត្រីចាប់ផ្តើមពីស្ត្រីពេញក្រមុំ (puberté) រហូតដល់វ័យអស់រដូវ (ménopause)។ មួយខួបរដូវមានរយៈពេល២៨ថ្ងៃ រាប់ចាប់ពីថ្ងៃ |

| | |
|---|---|
| | ទី១នៃរដូវរហូតដល់ថ្ងៃទី២៨នៃខួបនីមួយៗ។<br>៤. អវត្តមានរបស់វដ្តរដូវជារោគសញ្ញាមួយបញ្ជាក់ថា ស្ត្រីនោះមានបញ្ហាសុខភាព។ |
| ១៧៥- **វ័យកុមារ / បឋមវ័យ**<br>អ. childhood<br>បារ. enfance (f.) | វ័យរបស់មនុស្សចាប់ពីថ្ងៃកើតរហូតដល់វ័យជំទង់។ |
| ១៧៦- **វ័យចាស់ / បច្ឆិមវ័យ**<br>អ. old age<br>បារ. vieillesse (f.) | វ័យរបស់មនុស្សចាប់ពីពេញវ័យឡើងទៅ។ |
| ១៧៧- **វ័យជំទង់**<br>អ. adolescence<br>បារ. adolescence (f.) | វ័យរបស់មនុស្សចាប់ពីវ័យកុមាររហូតដល់ពេញវ័យ។ |
| ១៧៨- **វយាហា-រូបត្ថម្ភ**<br>អ. denutrition<br>បារ. dénutrition (f.) | ភាពទទួលជាតិអាហារជ្រួតជ្រាបតិចជាងជាតិអាហារដែលបញ្ចេញចោល។ |

| | |
|---|---|
| ១៧៩- **វ៉ាក់សាំង**<br>អ. vaccine<br>បារ. vaccin (m.) | សារធាតុដែលចាក់បញ្ចូលទៅក្នុងសរីរាង្គកាយមនុស្សឬសត្វ បង្កបង្កើតបានជាអង់ទីករ (anti-corps) អាចទប់ទល់បង្ការឬបង្កើតភាពស៊ាំនឹងជំងឺណាមួយ។<br>ឧ. ក្រសួងសុខាភិបាលមានកម្មវិធីជាតិចាក់វ៉ាក់-សាំងដល់ទារកដែលទើបនឹងកើត។ |
| ១៨០- **វិទ្យុព្យាបាល**<br>អ. radiotherapy<br>បារ. radiothérapie (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយប្រើកាំរស្មីវិទ្យុសកម្ម។<br>ឧ. ការព្យាបាលដោយប្រើកាំរស្មីកូបាល់(cobalt) ជាផ្នែកមួយនៃវិទ្យុព្យាបាលជំងឺមហារីក។ |
| ១៨១- **វិលមុខ**<br>អ. dizziness / vertigo<br>បារ. vertige (m.) | អាការវង់ងឹតមុខស្លុប ងេងងោង ធេងធោង ដែលអ្នកជំងឺមានអារម្មណ៍ថា ខ្លួនឯងកំពុងតែវិល ឬមើលឃើញវត្ថុជុំវិញខ្លួនកំពុងវិល ឬ យោលចុះយោលឡើង។ |
| ១៨២- **សន្លាក់**<br>អ. joint / articulation<br>បារ. articulation (f.) | កន្លែងភ្ជាប់ឬតំណរវាងឆ្អឹងនិងឆ្អឹង ដែលអាចឬមិនអាចធ្វើចលនាបាន។<br>ឧ១. សន្លាក់ជង្គង់ជាសន្លាក់តពីឆ្អឹងភ្លៅទៅឆ្អឹងស្មងដែលអាចធ្វើចលនាបាន។<br>ឧ២. សន្លាក់ថ្ងាសឆ្អឹងត្រគាកជាសន្លាក់មិនអាចធ្វើចលនាបាន។ |

| | |
|---|---|
| ១៨៣- **សន្លាក់វិទ្យា**<br>អ. arthrology<br>បារ. arthrologie<br>(f.) | វិទ្យាសាស្ត្រសិក្សាជាមូលដ្ឋានអំពីសន្លាក់ដែលជាផ្នែកមួយនៃកាយវិភាគវិទ្យា / អាណាតូមី (anato-mie)។ |
| ១៨៤- **សម្រូប**<br>អ. absorption<br>បារ. absorption<br>(f.) | ក្នុងសរីរវិទ្យា សម្រូបគឺជាការចូលសារធាតុពីខាងក្រៅទៅក្នុងសរីរាង្គណាមួយដោយពុំបង្កឱ្យមាន-ត្រូម៉ា។<br>ឧ. សម្រូបអុកស៊ីហ្សែនចូលក្នុងថង់សួត (alvéole)។ |
| ១៨៥- **សរីរព្យាបាល / ហ្វីស្យូព្យាបាល**<br>អ. physiotherapy / physical therapy<br>បារ. physiothéra-pie / physicothé-rapie) (f.) | វិធីសាស្ត្រព្យាបាលជំងឺដោយប្រើភ្នាក់ងាររូប (agents physiques) ធម្មជាតិ ឬ សិប្បនិម្មិត។<br>ឧ. ការស្អំក្បាលនឹងទឹកកកជាសរីរព្យាបាលមួយបែបក្នុងការព្យាបាលអាការៈឈឺក្បាល។ |
| ១៨៦- **សរីរវិទ្យា**<br>អ. physiology<br>បារ. physiologie<br>(f.) | វិទ្យាសាស្ត្រសិក្សាអំពីមុខងារ សកម្មភាពនៃជាលិកា និង សរីរាង្គរបស់ភាវៈមានជីវិត។ |
| ១៨៧- **សល្យព្យា-បាល** | វិធីសាស្ត្រព្យាបាលជំងឺដោយការវះកាត់ ការចាក់នឹងម្ជុល ឬ ការទាញតម្រង់ដោយដៃ។ |

| | |
|---|---|
| អ. surgical operation<br>បារ. opération chirurgicale (f.) | |
| ១៨៨- **សល្យវិទ្យា**<br>អ. surgery<br>បារ. chirurgie (f.) | វិទ្យាសាស្ត្រសិក្សាអំពីវិធីព្យាបាលជំងឺដោយវះកាត់ ចាក់នឹងម្ជុល ឬ ទាញតម្រង់។ |
| ១៨៩- **សារធាតុរំលូត**<br>អ. abortifacient<br>បារ. abortif (m.) | សារធាតុដែលបង្កឱ្យមានការរលូតកូន។<br>ឧ.ការប្រើសារធាតុរំលូតមិនតាមវេជ្ជបញ្ជាអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតម្តាយ។ |
| ១៩០- **សិបទីសេមី**<br>អ. septicemia<br>បារ. septicémie (f.) | អាំងហ្វិចស្យុង (infection) ធ្ងន់ធ្ងរដោយសារបាក់តេរ៉េមី (bactérémie)ខ្ពស់បណ្តាលឱ្យមានរោគសញ្ញាគ្រុនក្តៅញាក់និងអស់កម្លាំងខ្លាំងរហូតដល់ស្តុក(choc)។<br>ឧ. អ្នកជំងឺសិបទីសេមីដែលពុំបានព្យាបាលទាន់ពេលវេលា អាចបណ្តាលឱ្យស្លាប់ដោយសារស្តុកសិបទីសេមីក(choc septicémique)។ |
| ១៩១- **សុក**<br>អ. placenta<br>បារ. placenta (m.) | អន្តរសរីរាង្គមានទីតាំងនៅក្នុងស្បូនភាគខាងលើដែលភ្ជាប់ពីម្តាយទៅទារកក្នុងផ្ទៃតាមរយៈទងផ្ចិត។ សុកមានមុខងារបញ្ជូនអុកស៊ីហ្សែន សារជាតិអាហារ និង សារធាតុដទៃទៀត ទៅចិញ្ចឹមទារក ហើយ |

| | |
|---|---|
| | បញ្ចេញពីទារកមកម្ដាយវិញនូវឧស្ម័នកាបូនិកនិងកាកសំណល់ផ្សេងៗ។<br>ឧ. ជាទូទៅ សុកដែលធ្លាក់ចេញពីស្បូនម្ដាយក្រោយពេលសម្រាល មានទម្ងន់១/៦នៃទម្ងន់ទារក។ |
| ១៩២- **សុកពាំងមាត់ស្បូន/ផ្លាសង់-តា ប្រេវីយ៉ា**<br>អ. placenta prœvia<br>បារ. placenta prœvia ( m. ) | សុកតាំងទីខុសប្រក្រតីនៅផ្នែកខាងក្រោមនៃស្បូន។<br>ឧ. សុកពាំងមាត់ស្បូនជាករណីមានគ្រោះថ្នាក់ដល់ជីវិត ដោយសារការធ្លាក់ឈាមយ៉ាងខ្លាំង នៅក្នុងត្រីមាសទីបីនៃគភ៌។ |
| ១៩៣- **ស្តេរីលកម្ម/**<br>អ. sterilization<br>បារ. stérilisation ( f. ) | វិធីសម្លាប់មីក្រូសរីរាង្គដោយកម្ដៅ កាំរស្មី ឬ សារ-ធាតុគីមី...។<br>ឧ. សម្ភារៈវះកាត់ត្រូវធ្វើស្តេរីលកម្មឱ្យបានស្អាតទើបជៀសវាងអាំងហ្វិចស្យុង ( infection )។ |
| ១៩៤- **ស្បូន**<br>អ. uterus<br>បារ. utérus ( m. ) | សរីរាង្គបន្តពូជរបស់ស្ត្រី ដែលគភ៌មកតាំងទីនិងលូតលាស់។<br>ឧ. ការសម្រាលកូននៅក្នុងគ្រឹះស្ថានសុខាភិបាលអាចកាត់បន្ថយអត្រានៃការស្រុតស្បូន។ |
| ១៩៥- **ស្ប៉ាស់**<br>អ. spasm<br>បារ. spasme ( m. ) | អាការៈឈឺចុកចាប់ភ្លាមៗដោយសារការកន្ត្រាក់សាច់ដុំដោយឯកឯង។<br>ឧ. ស្ប៉ាស់បំពង់ខ្យល់អាចបង្កឱ្យស្ទះដង្ហើម។ |

| | |
|---|---|
| ១៩៦- **ហ្វីប្រូម**<br>អ. fibroma<br>បារ. fibrome ( m. ) | ដុំពកបេនីញនៃជាលិកាសន្ទាន ( tissu conjonctif ) ដែលអាចកើតមាននៅគ្រប់សរីរាង្គនៃសព៌ាង្គកាយ។ |
| ១៩៧- **ហ្វីប្រូមស្បូន**<br>អ. uterus fibroma<br>បារ. fibrome utérin ( m. ) | ដុំពកបេនីញនៃជាលិកាសន្ទានរបស់ស្បូន។<br>ឧ. ហ្វីប្រូមស្បូនជាជំងឺដែលតម្រូវឱ្យវះកាត់យកចេញជាចាំបាច់  ដើម្បីជៀសវាងការវិវត្តទៅជាមហារីកស្បូន។ |
| ១៩៨- **ហ្ស៊ីណេ-កូវិទ្យា / រោគស្ត្រី-វិទ្យា**<br>អ. gynecology<br>បារ. gynécologie ( f. ) | វេជ្ជវិទ្យាដែលសិក្សាអំពីសរីរាង្គបន្តពូជរបស់ស្ត្រី និង វិធីសាស្ត្រព្យាបាល។<br>ឧ. រោគស្ត្រីវិទ្យាបច្ចុប្បន្នកំពុងផ្តោតការយកចិត្ត-ទុកដាក់កាត់បន្ថយជំងឺមហារីកមាត់ស្បូន។ |
| ១៩៩- **អង់ទីករ** / **អង្គបដិបក្ខ**<br>អ. antibody<br>បារ. anticorps ( m. ) | សារធាតុប្រូតេអ៊ីនដែលផលិតដោយសរីរាង្គ ដើម្បីប្រឆាំងនឹងជំងឺទៅតាមប្រភេទពិសេសរបស់វា។<br>ឧ. ក្រោយពីចាក់វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹលកុមារនឹងមានអង់ទីករទប់ទល់នឹងជំងឺកញ្ជ្រឹលបាន។ |
| ២០០- **អង់ទីតុក-ស៊ីន / បដិវិសធាតុ**<br>អ. antitoxin<br>បារ. antitoxine ( f. ) | សារធាតុដែលអាចបន្សាបសកម្មភាពពុលរបស់តុកស៊ីន។ |

| | |
|---|---|
| ២០១- **អង់ទីប្យូទិក**<br>អ. antibiotic<br>បារ. antibiotique<br>(m.) | សារធាតុឱសថមានប្រភពពីធម្មជាតិឬពីសារធាតុគីមី ឬ ការធ្វើសំយោគ ដែលមានសកម្មភាពអាចទប់ស្កាត់ការលូតលាស់ឬបំផ្លាញពពួកបាក់តេរីឬផ្សិត។<br>ឧ. គ្រូពេទ្យបានជ្រើសរើសឱសថអង់ទីប្យូទិកមួយប្រភេទមកព្យាបាលជំងឺរលាកបំពង់ក។ |
| ២០២- **អង់ហ្ស៊ីយ៉ូម**<br>អ. angioma<br>បារ. angiome<br>(m.) | ដុំពកបេនីញនៃសរសៃឈាម(vaisseau sanguin) និង សរសៃឡាំហ្វ៍ (vaisseau lymphatique)ពីកំណើត មានលក្ខណៈរីករវាម ជួនកាល ដុះលយចេញក្រៅសរីរាង្គ។ |
| ២០៣- **អដ្ឋិវិទ្យា**<br>អ. osteology<br>បារ. ostéologie<br>(f.) | វិទ្យាសាស្ត្រសិក្សាជាមូលដ្ឋានអំពីឆ្អឹងរបស់មនុស្សនិងសត្វ។<br>ឧ. អដ្ឋិវិទ្យាជាផ្នែកមួយរបស់កាយវិភាគវិទ្យា / អាណាតូមី (anatomie)។ |
| ២០៤-**អត្រាមរណៈ**<br>អ. mortality rate<br>បារ. taux (m.) de mortalité (f.) | ចំនួនមនុស្សស្លាប់ក្នុងចំណោមប្រជាពលរដ្ឋនៃប្រទេសឬតំបន់ណាមួយ តាមឯកតាភាគរយ ភាគពាន់ ឬ ភាគលាន ក្នុងរយៈពេលណាមួយ។<br>ឧ. អត្រាមរណៈជាស្តង់ដាសម្រាប់វាស់កម្រិតបច្ចេកទេសសុខាភិបាលនៃប្រទេសឬតំបន់ណាមួយ។ |

| | |
|---|---|
| ២០៤- **អត្រាមរ-ណៈទារកពេលកើត**<br>អ. perpartum mortality rate<br>បារ. taux (m.) de mortalité (f.) per-partum | អត្រានៃទារកដែលស្លាប់នៅពេលកំពុងសម្រាល។<br>ឧ. បច្ចុប្បន្ននេះ បច្ចេកទេសសង្គ្រោះទារកពេលសម្រាល មានការរីកចម្រើនខ្លាំង ធ្វើឱ្យអត្រាមរណៈទារកពេលកើត ថយចុះ។ |
| ២០៥- **អត្រាមរណៈទារកក្រោយកើត**<br>អ. postpartum mortality rate<br>បារ. taux(m.) de mortalité (f.) post-partum / taux (m.) de mortalité (f.) postnatale | អត្រានៃទារកដែលស្លាប់នៅក្រោយពេលសម្រាល។<br>ឧ. ឆ្មបដែលមានវិជ្ជាជីវៈច្បាស់លាស់ អាចកាត់បន្ថយអត្រាមរណៈទារកក្រោយកើត។ |
| ២០៦- **អត្រាមរណៈមាតា**<br>អ. mother mortality rate<br>បារ. taux (m.) de mortalité (f.) maternelle | អត្រានៃស្ត្រីមានគភ៌ដែលស្លាប់ក្នុងអំលុងពេលសម្រាល។<br>ឧ. ដើម្បីកាត់បន្ថយអត្រាមរណៈមាតា ស្ត្រីមានគភ៌ត្រូវពិគ្រោះជាមួយគ្រូពេទ្យតាមការកំណត់ ជាពិសេស ស្ត្រីដែលមានជំងឺប្រចាំកាយធ្ងន់ធ្ងរ ដូចជា ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺឡើងសម្ពាធឈាម ជំងឺសួត ជាដើម។ |

| | |
|---|---|
| ២០៧- **អត្រាមរណៈទារកមុនកើត**<br>អ. prenatal mortality rate<br>បារ. taux (m.) de mortalité (f.) prénatale | អត្រានៃទារកដែលស្លាប់ក្នុងផ្ទៃម្ដាយមុនពេលសម្រាល។<br>ឧ. ស្ត្រីមានគភ៌ត្រូវទៅពិនិត្យផ្ទៃពោះជាមួយគ្រូពេទ្យជំនាញ ដើម្បីកាត់បន្ថយអត្រាមរណៈទារកមុនកើត។ |
| ២០៨- **ឥតអារ / ហ្វែទីល**<br>អ. fertile<br>បារ. fertile (adj.) | ដែលបង្កកំណើតបាន (មនុស្ស សត្វ និង រុក្ខជាតិ)។<br>ឧ. ស្ត្រីឥតអារអាចបង្កកំណើតបានចាប់ពីវ័យពេញក្រមុំរហូតដល់ពេលអស់រដូវ។ |
| ២១០- **អាកទែ / រោហិណី**<br>អ. artery<br>បារ. artère (f.) | សរសៃឈាមដែលនាំឈាមចេញពីបេះដូងទៅសរីរាង្គកាយ។<br>ឧ. សាព៌ាង្គកាយមនុស្សឬសត្វមានបណ្ដាញអាកទែឬរោហិណីជាច្រើនប្រភេទ។ |
| ២១១- **អាគូទុយម៉ង់**<br>អ. acquired tolerance<br>បារ. accoutumance (f.) | បាតុភូតនៃសរីរាង្គមិនឆ្លើយតបនឹងការប្រើឱសថ គ្រឿងពុល ឬ គ្រឿងញៀន ដែលតម្រូវឱ្យប្រើពីកម្រិតទាបទៅខ្ពស់ ដើម្បីទទួលបាននូវប្រសិទ្ធភាព។<br>ឧ. អាគូទុយម៉ង់ថ្នាំងុយដេកតម្រូវឱ្យដំឡើងបរិមាណឱសថទើបទទួលបានប្រសិទ្ធភាព។ |

| | |
|---|---|
| ២១២- **អាដ្រេណាលីន**<br>អ. adrenaline<br>បារ. adrénaline (f.) | អ័រម៉ូនម្យ៉ាងដែលបញ្ចេញដោយក្រពេញសួរ៉េ-ណាល់ (glande surrénale)។ គេអាចផលិតអាដ្រេណាលីនសិប្បនិម្មិតបានដើម្បីប្រើក្នុងផ្នែកវេជ្ជសាស្ត្រ។ |
| ២១៣- **អាប់សែ**<br>អ. abscess<br>បារ. abcès (m.) | ការបង្កខ្ទុះនៅក្នុងជាលិកាដែលរលួយខូចដោយ-សារមេរោគ។<br>ឧ. អាប់សែថ្លើមបណ្ដាលមកពីបរាសិតដែលជាអាមីបឈ្មោះ អង់តាមីបា អ៊ីស្តូលីទីកា (entamœba histolytica)។ |
| ២១៤- **អាម៉្វូស**<br>អ. amnion / amnios<br>បារ. amnios (m.) | ស្រទាប់ក្នុងនៃភ្នាសទារកដែលអភិវឌ្ឍទៅតាមការរីកធំធាត់របស់ទារកនៅក្នុងផ្ទៃម្ដាយ។<br>ឧ. នៅពេលប្រសូត អាម៉្វូសកើតចេញមកជាមួយនឹងទារក។ |
| ២១៥- **អារ**<br>អ. sterile<br>បារ. stérile (adj.) | ដែលមិនអាចបង្កកំណើតបាន (មនុស្ស សត្វ និងរុក្ខជាតិ)។<br>ឧ. គូស្វាមីភរិយាដែលរៀបការយូរពេលហើយមិនមានកូន អាចបណ្ដាលមកពីប្ដីនិង/ឬប្រពន្ធអារ។ |
| ២១៦- **អារនីយកម្ម**<br>អ. sterilization<br>បារ. stérilisation (f.) | វិធីសាស្ត្រធ្វើឱ្យមានភាពអារដល់បុរសឬស្ត្រី។<br>ឧ. វិធីវះកាត់ចងដៃស្បូនជាអារនីយកម្មមួយបែបដល់ស្ត្រី។ |

| | |
|---|---|
| ២១៧- **អាសន្នរោគ**<br>អ . cholera<br>បារ. choléra<br>(m.) | រោគបង្កឡើងដោយមេរោគឈ្មោះ Vibrio cholerae ដែលរកឃើញដោយលោក Robert Koch នៅ គ.ស.១៨៨៣។ ជំងឺនេះឆ្លងតាមផ្លូវអាហារ ជា-ពិសេស ទឹកមិនស្អាត និង ឆ្លងតាមដៃ បណ្តាលឱ្យមានការចុះរាកយ៉ាងខ្លាំងជាច្រើនដងមិនឈប់ និងមានការក្អួតយ៉ាងខ្លាំងផងដែរ ជាហេតុបណ្តាលឱ្យខ្វះជាតិទឹកឬខ្សោះជាតិទឹកពីក្នុងខ្លួនអ្នកជំងឺ អាចបណ្តាលឱ្យស្លាប់ប្រសិនបើមិនបានព្យាបាលទាន់ពេលវេលាតាមក្បួនតាមជំនាញនោះទេ។<br>ឧ. មណ្ឌលសុខភាពបានអប់រំប្រជាពលរដ្ឋឱ្យរស់នៅស្អាត ហូបស្អាត ផឹកស្អាត មានអនាម័យ ដើម្បីជៀសវាងការកើតជំងឺអាសន្នរោគ។ |
| ២១៨- **អាស៊ីត / ទាចទឹក**<br>អ. ascites<br>បារ. ascite (f.) | វត្តមានទឹកនិងអេឡិចត្រូលីតនៅក្នុងភ្នាសពោះ បណ្តាលមកពីមូលហេតុច្រើនយ៉ាង ដូចជា ក្រិន-ថ្លើម របេងភ្នាសពោះ ជំងឺបេះដូង...។ |
| ២១៩- **អ៊ីដ្រូណេ-ហ្វ្រូស**<br>អ. hydronephro-sis<br>បារ. hydroné-phrose (f.) | អាការៈចាល់ទឹកនោមក្នុងវក្កំ(តម្រងនោម) ដែលគ្មានអាំងហ្វិចស្យុង ដោយសារការស្ទះបំពង់ទឹក-នោម (uretère) ដូចជា ក្នុងករណីមានក្រួស ឬ ទុយម័រ។ |

| | |
|---|---|
| ២២០- **ឱនារូបត្ថម្ភ / កង្វះអាហារូបត្ថម្ភ**<br>អ. starvation<br>បារ. sous alimen-tation / sous-nutrition ( f. ) | ភាពទទួលអាហារមិនគ្រប់គ្រាន់។ |
| ២២១- **អូវុល**<br>អ. ovule<br>បារ. ovule ( m. ) | កោសិកាបន្តពូជញីដែលផលិតចេញពីសរីរាង្គបន្តពូជ ( អូវែ : ovaire ) របស់មនុស្សស្រី សត្វញី ឬ រុក្ខជាតិញី។<br>ឧ. ការបង្កកំណើតរបស់មនុស្ស សត្វ ឬ រុក្ខជាតិ កើតឡើងដោយការរួមផ្សំគ្នារវាងស្ពែម៉ាតូសូអ៊ីត ( spermatozoïde ) ឬ អង់តេរ៉ូសូអ៊ីត ( anthéro-zoïde ) និង អូវុល។ |
| ២២២- **អូវែ**<br>អ. ovary<br>បារ. ovaire ( m. ) | ក្រពេញភេទរបស់មនុស្សស្រី សត្វញី ឬ រុក្ខជាតិញី។ នៅពេលពេញវ័យ ក្រពេញភេទនេះអាចផលិតអូវុលនិងអ័រម៉ូន អ៊ីស្ត្រូហ្សែន និង ប្រូហ្សេសស្តេរ៉ូន។<br>ឧ. អូវែរបស់មនុស្សស្រីចាប់ផ្តើមបញ្ចេញអូវុល នៅពេលស្ត្រីពេញវ័យ។ |
| ២២៣- **អៀន**<br>អ. pinworm<br>បារ. oxyure ( m. ) | បរាសិតណេម៉ាតូដ ( nématodes ) មានប្រវែងពី៤ ទៅ ៩មីល្លីម៉ែត្រ រស់នៅក្នុងបំពង់អាហារ ជា-ពិសេសនៅចុងពោះវៀនធំនិងទ្វារលាមកដែលបង្កឱ្យរមាស់។<br>ឧ. ក្មេងកើតអៀនច្រើនរមាស់ទ្វារធំនៅពេលយប់។ |

| | |
|---|---|
| ២២៤- **អេម៉ង់ហ្ស៊ី-យ៉ូម**<br>អ. hemangioma<br>បារ. hémangiome (m.) | អង់ហ្ស៊ីយ៉ូមនៃសរសៃឈាម (vaisseau sanguin)។ ប្រជាជនខ្មែរនិយមហៅ អេម៉ង់ហ្ស៊ីយ៉ូម នៅលើស្បែកដែលមានលក្ខណៈពកតូចៗថាជាខ្នៅដុះពណ៌ក្រហម។ |
| ២២៥- **អេម៉ាតូម**<br>អ. hematoma<br>បារ. hématome (m.) | កំណកឈាមជាដុំៗនៅក្នុងជាលិកាឬក្នុងសរីរាង្គដោយមិនមានរហែកស្បែក បណ្ដាលមកពីរបួសសរសៃឈាមឬការប៉ះទង្គិចធ្ងន់ធ្ងរ។ |
| ២២៦- **អេរីតែម/ស្បែកឡើងក្រហម**<br>អ. erythema / erythro derma<br>បារ. érythème (m.) | អាការៈស្បែកប្រែជាក្រហមតិចឬច្រើនដោយសារកម្ដៅថ្ងៃ ឬ ប្រតិកម្មអាឡែហ្ស៊ី (réaction allergique)។<br>ឧ. ដើម្បីបញ្ជាក់ថាជាអេរីតែម គេអាចធ្វើតេស្ដដោយសង្កត់ចំកន្លែងស្បែកពណ៌ក្រហមនោះ វាឡើងសស្លេក ប៉ុន្តែ វាត្រឡប់មកសភាពដើមវិញនៅពេលគេដកដៃចេញ។ |
| ២២៧- **ឱសថពន្យារកំណើត/កុងត្រាសិបទីហ្វ**<br>អ. contraceptive<br>បារ. contraceptif (m.) | ឱសថដែលមានប្រសិទ្ធភាពទប់ស្កាត់ការមានកំណកកំនៅក្នុងផ្ទៃម្ដាយ។<br>ឧ. មុននឹងប្រើឱសថពន្យារកំណើត ស្ត្រីត្រូវទៅពិគ្រោះជាមួយគ្រូពេទ្យឯកទេស ដើម្បីបញ្ចៀសផលវិបាកទាំងឡាយពីការប្រើប្រាស់ឱសថនោះ។ |

| | |
|---|---|
| ២២៨- **អំបៅអំបែក**<br>អ. otitis media<br>បារ. otite moyenne (f.) | ដំងឺម៉្យាងដែលកើតក្នុងរន្ធត្រចៀក បង្កឡើងដោយមីក្រូសរីរាង្គកាយ។ រោគសញ្ញាមានដូចជា ក្ដៅខ្លួន ឈឺក្នុងរន្ធត្រចៀក ហៀរទឹករងៃ ឬ ខ្ទុះ ដែលមានក្លិនស្អុយ។ |
| ២២៩- **អំប្រ៊ីយ៉ុង / ភ្រូណា**<br>អ. embryo<br>បារ. embryon (m.) | គភ៌ដែលមានអាយុក្នុងរយៈពេលបីខែដំបូង។<br>ឧ.ដើម្បីបញ្ចៀសការរលូត ស្ត្រីដែលមានគភ៌ជាអំប្រ៊ីយ៉ុង ត្រូវប្រុងប្រយ័ត្នចំពោះការប្រើឱសថមិនបានត្រឹមត្រូវឬជៀសវាងគ្រោះថ្នាក់ចៃដន្យផ្សេងៗ។ |

## ២- បច្ចេកសព្ទកសិកម្ម

| | |
|---|---|
| ១- **កសិកម្ម**<br>អ. agriculture<br>បារ. agriculture (f.) | ការដាំដុះនិងការចិញ្ចឹមសត្វ។ |
| ២- **ការក្លូន**<br>អ. cloning<br>បារ. clonage (m.) | វិធីឬដំណើរការបន្តពូជអភេទរបស់ក្រុមកោសិកាដែលកើតចេញពីការបំបែកជាបន្តបន្ទាប់នៃកោសិកាមួយបានជាឯកត្តៈដូចបេះបិទនឹងឯកត្តៈដើម។ |
| ៣- **ការបង្កកំណើត**<br>អ. fertilization<br>បារ. fécondation (f.) | ជំនួបឬការលាយចូលគ្នារវាងហ្គាម៉ែតឈ្មោល (អង់តេរ៉ូសូអ៊ីត anthérozoïde រុក្ខជាតិ ឬ ស្ពែម៉ាតូសូអ៊ីត spermatzoïde សត្វ) និង ហ្គាម៉ែតញី (អូអូស្វ៊ែរ oosphère រុក្ខជាតិ ឬ អូវុល ovule សត្វ) ដើម្បីបង្កើតស៊ីកូត (zygote)។ |

| | |
|---|---|
| ៤- **ការបង្កាត់ពូជ**<br>អ. crossbreeding<br>បារ. croisement (m.) | ដំណើរការនៃការធ្វើឱ្យកាន់តែប្រសើរឡើងនូវការបង្កើតជំនាន់ក្រោយរបស់សត្វឬរុក្ខជាតិក្នុងប្រភេទតែមួយឬផ្សេងគ្នា ដោយការជ្រើសរើសមេបាឬពូជតាមបំណង។ |
| ៥- **ការបង្កាត់ពូជដោយសិប្បនិម្មិត**<br>អ. artificial insemination<br>បារ. insémination artificielle | ការបញ្ចូលទឹកកាមដែលគេរៀបចំតាមបច្ចេកទេសទៅក្នុងប្រដាប់បន្តពូជញីតាមរយៈឧបករណ៍មេកានិកឬអេឡិកត្រូនិកផ្សេងៗ ក្នុងគោលបំណងធ្វើឱ្យមានការបង្កកំណើត។<br>ឧ. បច្ចុប្បន្ននេះ កសិដ្ឋានចិញ្ចឹមសត្វនានានិយមការបង្កាត់ពូជដោយសិប្បនិម្មិត។ |
| ៦- **ការបង្កាត់ពូជតាមធម្មជាតិ**<br>អ. natural insemination<br>បារ. saillie naturelle (f.) | ការបង្កាត់ពូជតាមរយៈបានិងមេផ្ទាល់។<br>ឧ. ក្នុងចំណោមប្រជាកសិករខ្មែរ គេនៅតែអនុវត្តការបង្កាត់ពូជតាមធម្មជាតិចំពោះគោ ក្របី ជ្រូក មាន់ ទា នៅឡើយ។ |
| ៧- **ការបន្តពូជ**<br>អ. reproduction/ breeding<br>បារ. reproduction (f.) | ដំណើរការបង្កើតជំនាន់ក្រោយរបស់ភាវៈរស់នៅក្នុងប្រភេទដូចគ្នា។ ការបន្តពូជប្រព្រឹត្តទៅដោយភេទឬអភេទតាមវិធីផ្សេងៗ។ |

| | |
|---|---|
| ៨- **ការបន្តពូជភេទ**<br>អ. sexual reproduction<br>បារ. reproduction (f.) sexuée (amphimicie / mixie) | ដំណើរការបង្កើតជំនាន់ក្រោយរបស់រុក្ខជាតិឬសត្វ ដោយមានការបង្កកំណើតនិងបណ្តុំហ្សែន (gènes) ដែលភ្ជាប់មកតាមឯកត្តៈផ្សេងៗគ្នា។ |
| ៩- **ការបន្តពូជអភេទ**<br>អ. asexual reproduction<br>បារ. reproduction asexuée (f.) | ដំណើរការបង្កើតជំនាន់ក្រោយរបស់រុក្ខជាតិឬសត្វដែលប្រព្រឹត្តទៅពីឯកត្តៈតែមួយ ជួនកាលតាមរយៈការបំបែកខ្លួនពីកំណើតឬធម្មជាតិឬព្រឹត្តិការណ៍ចៃដន្យ ជួនកាល តាមរយៈការដុះពន្លក ការបែកខ្នែងដែលបង្កើតឯកត្តៈជាច្រើន ដូចគ្នាសុទ្ធសាធនឹងឯកត្តៈដើម។<br>វិធីបន្តពូជនេះកើតមានចំពោះបាក់តេរី រុក្ខជាតិ សត្វឥតឆ្អឹងកងប្រភេទតូចនិងសត្វប្រភេទធំខ្លះៗ ដែលកើតមានក្នុងករណីតិចតួចនៃពហុអំប្រីយ៉ុង ។ |
| ១០- **កោសេយ្យវប្បកម្ម**<br>អ. sericulture<br>បារ. séricículture (f.) | ការចិញ្ចឹមដង្កូវនាង។ |
| ១១- **ក្លូន**<br>អ. clone<br>បារ. clone (m.) | ក្រុមកោសិកាដែលបង្កើតចេញពីការបំបែកជាបន្តបន្ទាប់នៃកោសិកាមួយ បានជាឯកត្តៈដូចបេះបិទនឹងឯកត្តៈដើម។ |

| | |
|---|---|
| ១២- **ក្សេត្រសាស្ត្រ**<br>អ. agronomy<br>បារ. agronomie<br>(f.) | ផ្នែកមួយនៃកសិកម្មដែលសិក្សាពីទំនាក់ទំនងរវាងដំណាំ ដី អាកាសធាតុ និង បច្ចេកទេសនៃការដាំដុះ។ |
| ១៣- **ខ្ចាយ**<br>អ. lesser ginger<br>បារ. petits doigts<br>(m.) | តិណជាតិប្រើជាគ្រឿងទេស មើមពណ៌លឿងខ្ចីមានក្លិនប្រហើរ។ មើម ស្លឹក គេប្រើជាគ្រឿងផ្សំក្នុងម្ហូបនិងប្រើជាឱសថ។<br>ឧ. គេយកមើមខ្ចាយធ្វើជាគ្រឿងផ្សំក្នុងសម្លប្រហើរ។ វាជួយបន្ថយការឈឺមាត់ ការឈឺបំពង់ក។ |
| ១៤- **ខ្ញី**<br>អ. ginger<br>បារ. gingembre<br>(m.) | តិណជាតិប្រើជាគ្រឿងទេសមានរសជាតិហឹរ និងមានក្លិនពិសេស ដុះនៅតំបន់ក្តៅ។ មើមវា គេប្រើធ្វើជាម្ហូប បង្អែម តំណាប់ផ្សេងៗ និង ប្រើជារុក្ខជាតិឱសថ ព្រមទាំងជារូបធាតុដើមឱសថផងដែរ។ វាអាចជួយឱ្យដើរខ្យល់ ជួយរំលាយអាហារ និង ព្យាបាលរោគធ្លល់ហើមពោះ តឹងច្រមុះ ឈឺបំពង់ក ជាដើម។ |
| ១៥- **ខ្ទឹមក្រហម**<br>អ. shallot<br>បារ. échalote<br>(f.) | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ី។ ស្លឹកពណ៌បៃតង រាងជាបំពង់ ស្រួចចុង ។ មើមផ្តុំឡើងដោយកំពឹសពណ៌ក្រហមស្វាយឬមើមផ្តុំឡើងជាស្រទាប់ មានក្លិនឆ្អួលស្រាលជាងខ្ទឹមស ប្រើជាគ្រឿងទេស។<br>ឧ. ខ្ទឹមក្រហមស្រស់មានក្លិនឆ្អួល ប៉ុន្តែនៅពេលឆ្អិន មានរសជាតិឈ្ងុយឆ្ងាញ់។ |

| | |
|---|---|
| ១៦- **ខ្ទឹមគល់/ ស្រឹង**<br>អ. leek<br>បារ. poireau (m.) | តិណជាតិអម្បូរខ្ទឹមមានគល់ពណ៌សវែងៗ ហើយស្លឹកពណ៌បៃតង រាងសំប៉ែត រៀវចុងៗ គល់ប្រើជាបន្លែមានរសជាតិស្រដៀងខ្ទឹមបារាំងៗ<br>ឳ. គេនិយមយកខ្ទឹមគល់មកឆាជាមួយនឹងគ្រឿងក្នុងជ្រូកឬស្ងោរស៊ុបៗ វាជួយរំលាយអាហារៗ<br>អ្នកខ្លះហៅ ខ្ទឹមគល់ ស្រឹង ខ្ទឹមខ្យល់ ខ្ទឹមល័ក្តៗ |
| ១៧- **ខ្ទឹមបារាំង**<br>អ. onion<br>បារ. oignon (m.) | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅមជ្ឈិមបូព៌ាប្រទេសមានមើមរាងមូលធំជាងខ្ទឹមស ប្រើជាបន្លែ គ្រឿងទេស និង ឱសថៗ |
| ១៨- **ខ្ទឹមស**<br>អ. garlic<br>បារ. ail (m.) | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ីៗ ស្លឹករាងសំប៉ែត ពណ៌បៃតងៗ មើមផ្តុំឡើងដោយកំពឹសពណ៌ស មានក្លិនឆួល ប្រើជាគ្រឿងទេស និងជាឱសថៗ<br>ឳ. ប្រជាជនខ្មែរនិយមប្រើខ្ទឹមសយកទៅបុកលាបឬបិទកន្លែងដែលខ្ទួយទិចឬក៏ក្អែបខាំ ហើយ វាអាចជួយបន្ថយសម្ពាធឈាម ក្រិនសរសៃឈាម និង រំងាប់មេរោគតាមសរសៃឈាមៗ គេអាចប្រើវាទប់ទល់ផ្សែងនៃគ្រាប់បែកផ្សែង ដោយបុក ឬបំបែក ហិត ឬ លាបភ្នែក កុំឱ្យចេញទឹកភ្នែកៗ |
| ១៩- **ខ្ទឹមស្លឹក/ ខ្ទឹមខ្យល់**<br>អ. welsh onion<br>បារ. ciboule (f.) | តិណជាតិអម្បូរខ្ទឹមមានគល់ពណ៌សរាងមូល ស្លឹកពណ៌បៃតង រាងជាបំពង់ៗ គេប្រើជាគ្រឿងទេស ក្នុងម្ហូបអាហារ និង ប្រើជាឱសថ អាចជួយសម្រួលផ្លូវដង្ហើម ធ្វើឱ្យដើរខ្យល់ និង សម្រួលសរសៃឈាមៗ |

| | |
|---|---|
| ២០- **គូឆាយ**<br>អ. chinese chives<br>បារ. ciboule de chine (f.) | តិណជាតិអម្បូរខ្ទឹមមានប្រភពដុះនៅតំបន់អាស៊ី។ ស្លឹក គេប្រើធ្វើជា ម្ហូប បន្លែ និង នំ។ ស្លឹកនិងគ្រាប់វា គេអាចយកទៅប្រើជាឱសថ។<br>ឱ. ស្លឹកនិងគល់គូឆាយគេនិយមប្រើជាម្ហូបអាហារសម្រាប់ឱ្យដើរខ្យល់ អាចជួយសម្រួលផ្លូវដង្ហើម សម្រួលការរំលាយអាហារ និង ព្យាបាលការហើមពោះ។ គ្រាប់ហាលឱ្យស្ងួត កិនផឹកបំបាត់ជំងឺហូរទឹកកាម។ អ្នកខ្លះហៅ ជីឆាយ ឬ ស្លឹកឆាយ ឬ កាឆាយ។ |
| ២១- **ឃ្លោក**<br>អ. white gourd<br>បារ. courge (f.) | ប្រភេទលតាជាតិវារលើដីឬឡើងទ្រើង ដុះនៅតំបន់ត្រូពិក។ ផ្លែមានរាងមូលទ្រវែង ស្រដៀងនឹងផ្លែត្រឡាច។ ផ្លែខ្ចីប្រើជាបន្លែ សម្បូរដោយជីវជាតិ។ គេអាចយកសាច់និងគ្រាប់ប្រើជាឱសថសម្រាប់ជួយរំលាយអាហារ។ |
| ២២- **ឃ្លោកដប**<br>អ. bottle gourd<br>បារ. gourde / courge bouteille (f.) | ប្រភេទឃ្លោកម្យ៉ាងរាងដូចដប។ ផ្លែខ្ចីប្រើជាបន្លែ។ សំបកផ្លែទុំប្រើសម្រាប់ដាក់ទឹកនិងសម្ភារៈផ្សេងៗ។ |
| ២៣- **ឃ្លោកសាដៀវ**<br>អ. calabash<br>បារ. calebasse (f.) | ប្រភេទឃ្លោកម្យ៉ាងរាងដូចក្អមមួយជាន់ ឬ ពីរជាន់។ ផ្លែខ្ចី ប្រើជាបន្លែ, សំបកផ្លែទុំ ប្រើសម្រាប់ដាក់ទឹក ជាគ្រឿងលម្អ និង ធ្វើស្នូកសាដៀវ។ អ្នកខ្លះហៅ ឃ្លោកពួង។ |

| | |
|---|---|
| ២៤- **ចៃ**<br>អ. louse<br>បារ. pou (m.) | សត្វល្អិតជាបរាសិតជញ្ជក់ឈាម រស់នៅលើមនុស្សនិងថនិកសត្វមួយចំនួន។<br>ឧ. មនុស្សត្រូវធ្វើអនាម័យក្បាលឱ្យបានស្អាតដើម្បីកុំឱ្យកើតចៃ។ |
| ២៥- **ចៃលោត**<br>អ. flea / louse<br>បារ. puce (f.) | សត្វល្អិតសម្បុរត្នោត រាងសំប៉ែត ចេះរត់ឬលោតបាន។ វាជាបរាសិតរស់នៅលើមនុស្ស និង ថនិកសត្វមួយចំនួន។ សត្វល្អិតនេះរស់នៅលើស្បែកហើយពូកែជញ្ជក់ឈាម។<br>ឧ. ការមិនសម្អាតខ្លួនឱ្យផ្ដែនិងផ្ទានាំឱ្យកើតចៃលោត។ |
| ២៦- **ជលវិទ្យា**<br>អ. hydrology<br>បារ. hydrologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីទឹកនៅលើផែនដី ក្នុងបរិយាកាសនិងនៅភពដទៃ ដោយមានការសិក្សាពីកំណកំណើត ចលនាតាមរយៈវដ្តទឹក របាយលក្ខណៈរូប លក្ខណៈគីមី និង លក្ខណៈមេកានិករបស់ទឹក ព្រមទាំងអន្តរកម្មរវាងទឹកនិងភាវៈរស់។ |
| ២៧- **ជីរក្រសាំង-ទំហំ**<br>អ. persicaria odorata<br>បារ. polygone odorante (f.) | តិណជាតិមួយប្រភេទមានប្រភពនៅប្រទេសកម្ពុជា វៀតណាម ឡាវ មានស្លឹកទ្រវែងរៀវស្រួចខាងចុង ផ្ទៃស្លឹកខាងលើពណ៌បៃតង ផ្ទៃស្លឹកខាងក្រោមពណ៌ក្រហមភាវ ឬ ក្រហមស្រាល។ ស្លឹកប្រើជាបន្លែ អន្លក់ ឬ បង់ក្នុងសម្ល។<br>- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ ៖ ‹‹ជីរសាំងគ្រហ៊ុម››,<br>- អ្នកខ្លះហៅ «ជីរប្រហើរ» ឬ «ជីរសាំងគ្រហ៊ុម»។ |

| | |
|---|---|
| ២៨- **ជីរតាំងឳ**<br>អ. celery<br>បារ. céleri doux (m.) | តិណជាតិមួយប្រភេទច្រើនដុះនៅតំបន់ក្ដៅ ស្លឹកឆែកៗស្រដៀងនឹងស្លឹកស្ពៃរឿង។ គេប្រើជាបន្លែឬជាគ្រឿងទេស។<br>អ្នកខ្លះហៅថា ‹‹តាំងឳ››។ |
| ២៩- **ជីរត្រចៀកក្រាញ់**<br>ឡា. centella asiatica | តិណជាតិដុះនៅតំបន់ក្ដៅ ស្លឹករាងមូល មានទងវែងៗ រឹមស្លឹករាងជាធ្មេញរណារ  មានក្លិនក្រអូបពិសេសម្យ៉ាង។<br>គេនិយមបុកស្លឹកត្រចៀកក្រាញ់ ច្របាច់ច្រោះយកទឹកធ្វើជាភេសជ្ជៈ ឬ ជាឱសថ។ |
| ៣០- **ជីរថ្ពាល់ត្រី**<br>អ. chameleon plant<br>បារ. houttuynie (f.) | តិណជាតិស្ទើរវារ មានកម្ពស់ពី១០ទៅ៣០សង់-ទីម៉ែត ដុះនៅតំបន់ត្រូពិក ដែលមានដីសើម។ ស្លឹករាងមូល ស្រួចខាងចុងស្រដៀងនឹងស្លឹកពោធិ៍។ ស្លឹកប្រើជាបន្លែស្រស់ អន្លក់ ញាំភ្លា និងជាឱសថ។<br>អ្នកខ្លះហៅថា ‹‹ជីរយ៉ាបកា ឬ ជីរយួន››។ |
| ៣១- **ជីរនាងវង**<br>អ.  basil<br>បារ. basilic commun (m.) | តិណជាតិមួយប្រភេទ មានប្រភពដុះនៅតំបន់ក្ដៅឬត្រជាក់មធ្យម។ ស្លឹកនិង គ្រាប់ ប្រើជាបន្លែឬអន្លក់ដែលផ្ដល់ក្លិនប្រហើរ និង អាចបំបាត់ក្លិនឆ្អាប។ គ្រាប់ទុំអាចប្រើជាភេសជ្ជៈឬជាឱសថ។ |
| ៣២- **ជីរម្រះព្រៅ**<br>បារ. basilic des moines (m.) | តិណជាតិមួយប្រភេទដុះនៅតំបន់ក្ដៅ  ដើមនិងស្លឹកតូចមានរោមឆ្មារៗ។  ស្លឹកមានក្លិនហាង  ប្រ-ហើរឆ្ងួល ប្រើជាបន្លែ គ្រឿងទេសឬជាឱសថ។ |

| | |
|---|---|
| ៣៣- **ជីរណារ / ជីរបន្លា**<br>អ. fitweed<br>បារ. panicaut (m.) | តិណជាតិមួយប្រភេទមានប្រភពពីទ្វីបអាម៉េរិកនៃតំបន់អាកាសធាតុក្តៅ។ ស្លឹកមានរាងទ្រវែង រឹមស្លឹកមានរាងជាធ្មេញរណារ ដុះចេញពីគល់គ្មានមែក។ ស្លឹក ប្រើជាបន្លែ គ្រឿងទេស និង ឱសថ។<br>អ្នកខ្លះហៅថា ‹‹ ជីរបារាំង ឬ ជីរស្លឹកវែងឬក៏ ជីរក្រពើ ›› ។ |
| ៣៤- **ជីរលីងល័ខ**<br>អ. sweet basil<br>បារ. basilic de ceylan (m.) | តិណជាតិមានសណ្ឋានដូចជីរនាងវង ប៉ុន្តែ ដើមមានពណ៌ស្វាយ ក្លិនស្រដៀងនឹងជីរម្រះព្រៅ។ គេនិយមយកជីរលីងល័ខមកផ្សំធ្វើជាប្រហុកកប់ ឬ ព្រហក់ខ្ទប់។<br>អ្នកខ្លះហៅថា ‹‹ជីរនាងលាក់››។ |
| ៣៥- **ជីរវ៉ាន់ស៊ុយ**<br>អ. coriander<br>បារ. coriandre (f.) | តិណជាតិម្យ៉ាងមានដើមតូចឆ្មារនិងស្លឹកឆែកៗ ហើយមានសភាពទន់ មានក្លិនក្រអូបប្រហើរ ប្រើជាគ្រឿងទេសសម្រាប់យកក្លិនឬលម្អម្ហូបអាហារ។<br>អ្នកខ្លះហៅថា ‹‹ អ្វាន់ស៊ុយឬអ្នួនស៊ុយ››។ |
| ៣៦- **ជីរស្លឹកក្រាស់ / ជីរត្រចៀកជ្រូក**<br>អ. cuban oregano / coleus<br>បារ. coleus (m.) | តិណជាតិម្យ៉ាងមានស្លឹកមូលធំក្រាស់ រឹមស្លឹកមានរាងជាធ្មេញរណារ។ ដើមនិងស្លឹកមានរោមឆ្មារៗ គេប្រើជាគ្រឿងទេសនិងជាឱសថ។<br>អ្នកខ្លះហៅថា ‹‹ជីរក្រអូប ជីរត្រចៀកដំរី ជីរទ្រមឹង ជីរទ្រមាំង››។ |

| | |
|---|---|
| ៣៧- **ជីរអង្កាម**<br>អ. mint<br>បារ. menthe (f.) | តិណជាតិមានស្លឹករាងមូលជ្រួញៗ មានទងពណ៌ស្វាយនិងមានក្លិនប្រហើរឆ្ងួលតិចៗ។ ស្លឹកប្រើជាបន្លែនិងជាឱសថ។<br>ឱ. និស្សារណកម្មជីរអង្កាមផ្តល់នូវសារជាតិប្រេងម៉ង់ត៍ (menthe) និង ម៉ង់តូល (menthol)។<br>អ្នកខ្លះហៅថា ‹‹ជីរសង្កើច››។ |
| ៣៨- **ជីវវិទ្យា**<br>អ. biology<br>បារ. biologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីភាវៈរស់។ |
| ៣៩- **ជំងឺគោឆ្កួត**<br>អ. BSE (Bovine Spongiform Encephalopathy)<br>បារ. ESB/(Encephalopathie Spongiforme Bovine) | ជំងឺឆ្លងថ្មីកើតចំពោះគោ ដែលគេរកឃើញដំបូងនៅប្រទេសអង់គ្លេសក្នុងឆ្នាំ១៩៨៦។ ភ្នាក់ងារបង្កជំងឺនៅមិនទាន់ស្គាល់ច្បាស់ តែគេដឹងថា ស្ថិតក្នុងប្រព័ន្ធសរសៃប្រសាទនិងភ្នែក។ រោគសញ្ញាសំខាន់ៗមានដូចជា កន្ត្រាក់សាច់ដុំ ជំហរ ទ្រេតទ្រោត ដំណើរខុសប្រក្រតី ក្បាលសំយុងចុះក្រោកឈរដោយពិបាក និង មានប្រតិកម្មខ្លាំងចំពោះមជ្ឈដ្ឋាននៅជុំវិញ ដូចជា ឆាប់ភ័យខ្លាចឆាប់ផ្អើលឆ្លេឆ្លា ឬ កាចខុសធម្មតា។ កាលណាជំងឺនេះឆ្លងមកមនុស្ស គេឱ្យឈ្មោះថា ស៊ីជេឌី (CJD : Creutzfeldt-Jakob Disease) ឬ អឹមសេហ្ស៊ី (MCJ : Maladie de Creutzfeldt-Jakob). |

| | |
|---|---|
| ៤០- **ជំងឺចុងអង្ករគោក្របី**<br>អ. cysticercosis in cattle and buffalo<br>បារ. cysticercose bovine/ladrerie (f.) | ជំងឺបង្កដោយបរាសិតម្យ៉ាងជាតេញ៉ា (taenia) ស្ថិតក្នុងសន្តានតេនីអ៊ីដេ (taeniidae) ប្រភេទសាហ្ស៊ីណាតា (taenia saginata) មានសណ្ឋានជាគីស្តស្ថិតនៅក្នុងសាច់ដុំបេះដូង សាច់ដុំស្មា សាច់ដុំតាមសរីរាង្គមួយចំនួនទៀត អណ្តាតថ្លើម លំពែង។ ជំងឺនេះឆ្លងពីសត្វមកមនុស្ស តាមរយៈការបរិភោគសាច់សត្វមានគីស្ត ដែលចម្អិនមិនឆ្អិនល្អ ក្រោយមកគីស្តក៏វិវត្តទៅជាតេញ៉ាសាហ្ស៊ីណាតា រស់ក្នុងពោះវៀនមនុស្ស។ |
| ៤១- **ជំងឺចុងអង្ករជ្រូក**<br>អ. cysticercosis in swine<br>បារ. cysticercose du porc / ladrerie (f.) | ជំងឺបង្កដោយបរាសិតម្យ៉ាងជាតេញ៉ា (taenia) ស្ថិតក្នុងសន្តានតេនីអ៊ីដេ (taeniidae) ប្រភេទតេញ៉ាសូលីយោម (taenia solium) មានសណ្ឋានជាគីស្ត ស្ថិតនៅក្នុងសាច់ដុំបេះដូង សាច់ដុំសន្ទះទ្រូង អណ្តាត ថ្លាល់ និង សាច់ដុំនៃសរីរាង្គដទៃទៀត។ ជំងឺនេះកើតចំពោះជ្រូក និងមនុស្ស។ ជាទូទៅ ចំពោះជ្រូក វាមិនបង្ហាញរោគសញ្ញាទេ។ |
| ៤២- **ជំងឺឈាមខ្មៅ**<br>អ. anthrax<br>បារ. anthrax (m.), charbon bactéridien (m.) | ជំងឺបង្កឡើងដោយបាក់តេរី បាក់ស៊ីលូស អង់ត្រាក់ស៊ីស (Bacillus Anthracis) បណ្តាលឱ្យសត្វងាប់មានអត្រាខ្ពស់ ដោយអាការៈហើមពោះ មិនស៊ីស្មៅដូចប្រក្រតី និង មានចេញឈាមតាម |

| | |
|---|---|
| | មាត់ ប្រមុះ និង រន្ធគូថ ក្រោយពេលវាងាប់។ ជំងឺនេះអាចឆ្លងទៅមនុស្សបាន។<br>ឲ. ហាមបរិភោគសាច់សត្វដែលស្លាប់ដោយជំងឺឈាមខ្មៅ ព្រោះវាអាចឆ្លងមកមនុស្ស។ |
| ៤៣- **ជំងឺដង្កូវថ្លើម / ជំងឺព្រូនថ្លើម**<br>អ. fascioliasis<br>បារ. fasciolosis<br>(m.) | ជំងឺដែលបង្កឡើងដោយពពួកបរាសិតឈ្មោះហ្វាស្យូឡា ស៊ីហ្កង់ទីកា / ហ្វាស្យូឡា អេប៉ាទីកា (Fasciola gigantica / Fasciola hepatica) ដែលកើតឡើងនៅក្នុងថ្លើម ក្នុងថង់ប្រមាត់ និង នៅក្នុងបំពង់ទឹកប្រមាត់របស់គោក្របី។<br>ឲ. គោ ក្របី ស៊ីស្មៅនៅតាមមាត់ត្រពាំងឬបឹងបួ អាចស៊ីដោយខ្យងហៀនទឹកតូចៗឈ្មោះ លីមណេ (Limnée/Limnea) ដែលជាភ្នាក់ងារចម្លង នាំឱ្យឆ្លងជំងឺដង្កូវថ្លើម។ |
| ៤៤-**ជំងឺតុកហ្សូការ៉ា/ ជំងឺតុកសូការ៉ា**<br>អ. toxocariasis<br>បារ. toxocarose | ជំងឺបង្កដោយបរាសិតតុកសូការ៉ា (toxocara) ស្ថិតក្នុងសន្តានតុកសូការីដេ (toxocaridae)។ ចំពោះគោ ក្របី ចៀម បង្កដោយប្រភេទតុកសូការ៉ាវីទូឡូរ៉ូម (T. Vitulorum), ឆ្កែ បង្កដោយតុកសូការ៉ាកានីស (T. Canis) និង ឆ្មា បង្កដោយតុកសូការ៉ាកាទី (T. Cati)។ រោគសញ្ញាមានដូចជា ឡើងកម្តៅ ក្អក ចង្វាក់ដង្ហើមខ្លី ពិបាកដកដង្ហើម រលាក រមាស់ស្បែក ឈឺពោះ រាក ខ្សោយ ស្គុល |

| | |
|---|---|
| | អន់ចំណី ទល់លាមក ហើមពោះក្រោយពេលបៅទឹកដោះមេ កើ លាមកមានលាយឈាមពណ៌ក្រមៅឬខ្មៅ។ |
| ៤៥- **ជំងឺតេឡាស៊ី-យ៉ា / តេឡាស៊ីយ៉ា-ស៊ីស**<br>អ. thelaziasis | ជំងឺបង្កដោយព្រូនតេឡាស៊ីយ៉ា(thelazia) ស្ថិតក្នុងសន្តានតេឡាស៊ីអ៊ីដេ (thelaziidae) រស់នៅក្នុងរន្ធទឹកភ្នែក។ ជំងឺនេះកើតចំពោះគោ ក្របី ចៀម ពពែ សេះ។ រោគសញ្ញាសំខាន់ៗមានដូចជា ហៀរទឹកភ្នែក ភ្នែកចាញ់ពន្លឺ ភ្នែកឡើងក្រហម ភ្នែកល្អក់ ហើមត្របកភ្នែក ឈឺភ្នែក គ្រវីក្បាល ។ |
| ៤៦- **ជំងឺត្រចៀកខៀវ**<br>អ. porcine respirating and reproductive syndrome (PRRS)/ blue ear disease | ជំងឺឆ្លងបង្កដោយវីរុសអាទេវីរុស (artervirus) ស្ថិតក្នុងសន្តាន អាទែវីវីរីដេ (arteriviridae) កើតចំពោះជ្រូក ជាពិសេស មេជ្រូក មេជ្រូកធើម និងកូនជ្រូក។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្តៅ មិនស៊ីចំណី មិនផឹកទឹក ហៀរសំបោរ ពិបាកដកដង្ហើម ហើមសួត មានស្នាមជាំស្វាយលើខ្លួនជាពិសេស នៅលើត្រចៀក។ ជំងឺនេះធ្វើឱ្យមេជ្រូករលូតកូន មិនងាយរកឈ្មោល កូនកើតមុនពេលកំណត់ កូនកើតមកខ្សោយ និង អត្រាស្លាប់ខ្ពស់។ |
| ៤៧- **ជំងឺទ្រីស្ទី-ណែឡូស**<br>អ. trichinellosis<br>បារ. trichinellose | ជំងឺបង្កដោយបរាសិតទ្រីស្ទីណែឡា (trichinella) ស្ថិតក្នុងសន្តានទ្រីស្ទីណែលីដេ (trichinellidae) ប្រភេទទ្រីស្ទីណែឡាស្ពៀរ៉ាលីស (trichinella spiralis)។ ជំងឺនេះកើតចំពោះមនុស្ស ជ្រូក កណ្តុរ ខ្លាឃ្មុំ និង ថនិកសត្វដែលជាមំសា- |

| | |
|---|---|
| | ហារសត្វមួយចំនួនទៀត។ រោគសញ្ញាសំខាន់ៗ មានដូចជា ឡើងកម្តៅ គ្រុន ល្ហិតល្ហៃ រមាស់ស្បែក សាច់ដុំឡើងរឹង ឈឺនៅពេលដែលយើងប៉ះវា។ ជំងឺនេះឆ្លងពីសត្វទៅមនុស្សតាមរយៈការបរិភោគ សាច់សត្វមានផ្ទុកកូនព្រូនទ្រីស្ទីណែឡា ហើយ ដែលចម្អិនមិនឆ្អិនល្អ។ |
| ៤៨- **ជំងឺបូសខ្យល់**<br>អ. blackleg<br>បារ. charbon(m.) symptomatique | ជំងឺម្យ៉ាងដែលបង្កឡើងដោយបាក់តេរីក្លូទ្រីឌីយោម ស្វូវី (Clostridium Chauvoei)។ ជំងឺនេះច្រើន កើតចំពោះ គោ ក្របី ចៀម ពពែ និង អាចកើត ចំពោះជ្រូកផងដែរ។ ជំងឺនេះមានរោគសញ្ញាដូច-ជា មានដុំខ្យល់ពកនៅត្រង់ ក ទ្រូង ស្មា និង ត្រគាក បណ្តាលឱ្យសត្វឈឺ ពិបាកធ្វើចលនា។<br>ຊ. ជំងឺបូសខ្យល់មិនឆ្លងដល់មនុស្សដូចជំងឺឈាម ខ្មៅទេ។ |
| ៤៩- **ជំងឺប៉េស្ត**<br>អ. pest<br>បារ. peste (f.) | ជំងឺឆ្លងម្យ៉ាងដែលច្រើនកើតចំពោះសត្វបម្រើ និងឆ្លងរាលដាលយ៉ាងឆាប់រហ័សតាមផ្លូវដង្ហើម និងតាមផ្លូវរំលាយអាហារ ហើយ ក៏អាចឆ្លងជា ប្រយោលទៅដល់មនុស្សនិងសត្វដទៃទៀតផង ដែរ។<br>ຊ. ជំងឺប៉េស្តគ្មានថ្នាំព្យាបាលទេ ប៉ុន្តែ មានវ៉ាក់-សាំងការពារ។ |

| | |
|---|---|
| ៥០- **ជំងឺប៉េស្តជ្រូក**<br>អ. classical swine fever / hog cholera<br>បា peste porcine classique (f.) | ជំងឺឆ្លងបង្កដោយវីរុសស្ថិតក្នុងសន្តានផ្លាវីវីរីដេ (flaviviridae) ពួកប៉េស្តវីរុស (pest virus)។ ជំងឺនេះកើតចំពោះជ្រូកគ្រប់វ័យដែលមានអត្រាឈឺនិងស្លាប់ខ្ពស់។ រោគសញ្ញាសំខាន់ៗមានដូច-ជា ឡើងកម្ដៅ គ្រុន ទល់លាមក រាក ភ្នែកមានពពឹក ស្នាមក្រហមអុចៗនៅចុងត្រចៀក ប្រមុះ សរីរាង្គបន្តពូជ និង ពោះ។ |
| ៥១- **ជំងឺប្រ៊ុយសែ-ឡា/ប្រ៊ុយសែឡូស**<br>អ. brucellosis<br>បារ. brucellose (f.) | ជំងឺឆ្លងដែលបង្កដោយបាក់តេរីប្រ៊ុយសែឡា (bru-cella) ស្ថិតក្នុងសន្តានប្រ៊ុយសែឡាសេអា (bru-cellaceae)។ ជំងឺនេះកើតចំពោះ គោ ក្របី ជ្រូក ចៀម ពពែ ឆ្កែ និង មនុស្ស។ ចំពោះសត្វ រោគសញ្ញាសំខាន់ៗមានដូចជា រលោកសន្លាក់ រលូតកូន កូនកើតមកងាប់ ជួនកាល រស់តែមានសុខភាពខ្សោយ ពិការ ងាប់នៅពេលផ្ដាច់ដោះ។ ចំពោះសត្វមេ មានហូរខ្ទុះចេញពីសរីរាង្គបន្តពូជ ដំបៅស្បូន រលោកក្រពេញដោះ។ ចំពោះសត្វបា ហើមពងស្វាស មិនរកញី។ ជំងឺនេះឆ្លងពីសត្វមកមនុស្សតាមរយៈការប៉ះពាល់ឬបរិភោគសាច់សត្វ ឬ ផលិតផលសត្វដែលផ្ទុកមេរោគឬមានជំងឺ។ |
| ៥២- **ជំងឺផ្ដាសាយបក្សី** | ជំងឺឆ្លងបង្កដោយវីរុសអាំងភ្លុយអង់សា (influen-zavirus) ស្ថិតក្នុងសន្តាន អ័រតូមីសូវីរីដេ (ortho- |

| | |
|---|---|
| អ. highly pathogenic avian influenza(HPAI) / bird flu / avian influenza / towl plague | myxoviridae) កើតចំពោះបក្សី និង ករណីខ្លះឆ្លងមកមនុស្ស។ ចំពោះបក្សី រោគសញ្ញាសំខាន់ៗមានដូចជា ហៀរសំបោរ ហើមក្បាល ហើមមុខ ហើមសិរ ហើមណង់ ជើងមានពណ៌ខៀវឬស្វាយហើយ លាមកប្រែពីពណ៌ធម្មតាទៅសរួចទៅពណ៌បៃតង។ ករណីស្រួចស្រាល់ខ្លាំង សត្វស្លាប់ដោយមិនបង្ហាញរោគសញ្ញាច្បាស់លាស់។ |
| ៥៣- **ជំងឺមេតាស្ត្រុងហ្ស៊ីឡូស**<br>អ. metastrongylosis<br>បារ. métastrongylose (f) | ជំងឺបង្កដោយព្រូនមេតាស្ត្រុងហ្ស៊ីលូស (metastrongylus) ស្ថិតក្នុងសន្ដានមេតាស្ត្រុងហ្ស៊ីលីដេ (metastrongylidae)។ ជំងឺនេះច្រើនកើតចំពោះជ្រូក ពិសេស កូនជ្រូក និង មិនសូវកើតមានចំពោះ ចៀម ពពែ ទេ។ ព្រូនមេតាស្ត្រុងហ្ស៊ីលូសរស់នៅក្នុងទងសួត។ រោគសញ្ញាសំខាន់ៗមានដូចជា រលាកទងសួត ហើមសួត ក្អក ស្លេកស្លាំង ក្រិន ក្រជំជាត់ ក្នុងករណីធ្ងន់ធ្ងរបណ្ដាលឱ្យសត្វស្លាប់។ |
| ៥៤- **ជំងឺសាទឹក**<br>អ. pasteurellosis<br>បារ. pasteurellose (f.) | ជំងឺម៉្យាងបង្កឡើងដោយបាក់តេរីប៉ាស្ទ័រឡា (pasteurella) ច្រើនកើតចំពោះសត្វបម្រើ។ ជំងឺនេះអាចឆ្លងពីសត្វឈឺទៅសត្វជា តាមរយៈទឹកមាត់ ចំណីអាហារ និង ការរស់នៅជិតគ្នា។ ពេលសត្វឈឺមានសីតុណ្ហភាពពី៤១ទៅ៤២អង្សាសេ |

| | |
|---|---|
| | វានឹងងាប់ទាន់ហន់ក្នុងរយៈពេល២៤ម៉ោង។<br>៤. ជំងឺសាទឹកអាចទប់ស្កាត់បាន ប្រសិនបើយើងចាក់ថ្នាំការពារឱ្យបានពីរឬបីដងក្នុងមួយឆ្នាំ។ |
| ៥៥- **ជំងឺសាទឹកជ្រូក**<br>អ. swine pasteurellosis<br>បារ. pasteurellose porcine (f.) | ជំងឺឆ្លងបង្កដោយបាក់តេរីប៉ាស្ទ័ររ៉ុឡាមុលតូស៊ីដា (pasteurella multocida) កើតចំពោះជ្រូក។ រោគសញ្ញាសំខាន់ៗមានដូចជា ឡើងកម្ដៅ ហើមស្លួត ក្អក ហៀរសំបោរ និង ដកដង្ហើមញាប់។ |
| ៥៦- **ជំងឺសាល់ម៉ូណែឡា / សាល់ម៉ូណែឡូស**<br>អ. salmonellosis<br>បារ. salmonellose (f.) | ជំងឺឆ្លងបង្កដោយបាក់តេរីសាល់ម៉ូណែឡា(salmonella) ស្ថិតក្នុងសន្តានអង់តេរ៉ូបាក់តេរីយ៉ាសេអា (enterobacteriaceae)។ ជំងឺនេះកើតចំពោះសត្វស្រុកគ្រប់ប្រភេទនិងមនុស្ស ជាពិសេស សត្វជំទង់និងសត្វធំ។ រោគសញ្ញាសំខាន់ៗមានដូចជា រាករូស រលូតកូន រលាកសន្លាក់និងផ្លូវដង្ហើម។ ជំងឺនេះឆ្លងពីសត្វមកមនុស្សតាមរយៈការប៉ះពាល់ឬបរិភោគសាច់សត្វឬផលិតផលសត្វដែលផ្ទុកមេរោគឬមានជំងឺ។ |
| ៥៧- **ជំងឺស៊ីស្តូសូម**<br>អ. schistosomiasis | ជំងឺបង្កដោយព្រូនស៊ីស្តូសូម៉ា (schistosoma) ស្ថិតក្នុងសន្តាន ស៊ីស្តូសូម៉ាទីដេ (schistosomatidae)។ ជំងឺនេះកើតចំពោះគោ ក្របី ចៀម ពពែ |

| | |
|---|---|
| បារ. schistoso-<br>miase (f.) | សេះ ជ្រូក ឆ្កែ ឆ្មា និង មនុស្ស។ ព្រូនស៊ីស្តូសូម៉ា រស់នៅក្នុងសរសៃវ៉ែនធំ វ៉ែន ពោះវៀន និង វ៉ែននៃភ្នាសសើមប្រមុះ។ រោគសញ្ញាសំខាន់ៗមានដូចជា រាកមួល ខ្សោះទឹក ហើម ស្គម ស្លេកស្លាំង។ |
| ៥៨- **ជំងឺអុតក្តាម**<br>អ. foot and mouth disease<br>បារ. fièvre aphteuse (f.) | ជំងឺឆ្លងម៉្យាងដែលច្រើនកើតនៅលើសត្វមានចង្វៃកជើង ធ្វើឱ្យមានដំបៅរលួយចង្វៃកជើង ក្រចកជើង មាត់ និង កន្សោមដោះ។ វាធ្វើឱ្យសត្វឈឺពិបាកដើរនិងពិបាកស៊ីចំណី។ ជួនកាល ជំងឺនេះឆ្លងទៅមនុស្សផងដែរ។<br>ឧ. បសុពេទ្យបើកយុទ្ធនាការចាក់ថ្នាំបង្ការជំងឺអុតក្តាមដល់គោ ក្របី នៅមុនរដូវភ្លៀង។ |
| ៥៩- **ដង្កែ**<br>អ. flea<br>បារ. tique (f.) | សត្វល្អិតអារ៉ាក្នីដ (Arachnides) មានជើង៨។ វាជាបរាសិតជញ្ជក់ឈាមនៅលើស្បែកថនិកសត្វ។<br>ឧ. ដង្កែជញ្ជក់ឈាមគោនិងឆ្កែ។ |
| ៦០- **ដង្កូវទ័ពស្រូវ**<br>អ. rice army-worm | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងធញ្ញជាតិផ្សេងៗទៀត ដែលមានឈ្មោះវិទ្យាសាស្ត្រ មីធីមណា សេប៉ារ៉ាតា (mythimna separata) ស្ថិតក្នុងសន្តានណុកទ្វីដេ (noctuidae) ប្រភេទមីធីមណា សេប៉ារ៉ាតា (mythimna separata)។ ដង្កូវនេះកើតពីមេអំបៅដែលពងជាគំនរៗពី ៨០០ ទៅ ១០០០ពង។ វាស៊ីសំណាប ស្លឹកស្រូវ និង គល់ក្បួរស្រូវខ្ចី។ |

| | |
|---|---|
| ៦១- **ដង្កូវបំពង់-កាត់ស្លឹកស្រូវ**<br>អ. rice case-worm | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ នីមហ្វ៊ុយឡា ដឺពុនតាលីស (nymphula depunctalis) ស្ថិតក្នុងសន្តានពីរ៉ាលីដេ (pyralidae) ប្រភេទនីមហ្វ៊ុយឡា ដឺពុនតាលីស (nymphula depunctalis)។ នៅដំណាក់កាលលូតលាស់ដំបូង មេអំបៅពងតម្រៀបជាជួរឬជាកញ្ចុំនៅលើផ្ទៃស្លឹកស្រូវផ្នែកខាងក្រោមប៉ប្រះទឹក។ កូនដង្កូវដែលញាស់មានលក្ខណៈពិសេសអាចរស់នៅក្នុងទឹកបានដោយសារការដកដង្ហើមយកអុកស៊ីសែនពីទឹកតាមរោមដែលមាននៅលើដងខ្លួនវា។ កូនដង្កូវស៊ីកាត់បំផ្លាញស្លឹកនិងដើមស្រូវខ្ចីៗរុំជាបំពង់នៅស្រែដែលមានទឹក។ ដង្កូវនេះអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| ៦២- **ដង្កូវមូរស្លឹក-ស្រូវ**<br>អ. rice leaffolders<br>បារ. leaffolders de riz (m.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ ខ្នាហ្វាឡូក្រូស៊ីស មេឌីណាលីស (cnaphalocrocis medinalis) ស្ថិតក្នុងសន្តានក្រាមប៊ីដេ (crambidae) ប្រភេទខ្នាហ្វាឡូក្រូស៊ីស មេឌីណាលីស (cnaphalocrocis medinalis)។ កូនដង្កូវទើបញាស់ (larvae) និង ដង្កូវពេញវ័យស៊ីបំផ្លាញជាលិកាស្លឹកស្រូវ បណ្ដាលឱ្យចេញជាឆ្នូតពណ៌សថ្លាវែងៗហើយស្ងួត។ មុននឹងក្លាយទៅជាដឹកដឿ ដង្កូវនេះមូរស្លឹកស្រូវឱ្យមាន |

| | |
|---|---|
| | រាងជាបំពង់ដោយទឹកមាត់ដូចសរសៃសូត្រ។ ការវិវឌ្ឍទៅជាមេអំបៅប្រព្រឹត្តទៅនៅក្នុងស្លឹករមូរនេះ។ ដង្កូវនេះក៏អាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| ៦៣- **ដង្កូវស៊ីរូងដើម**<br>អ. rice yellow stem borer | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ សៀប៉ូហ្វាហ្គា អាំងសែទុយឡាស (scirpophaga incertulas) ស្ថិតក្នុងសន្តានក្រាមប៊ីដេ (crambidae) ប្រភេទសៀប៉ូហ្វាហ្គា អាំងសែទុយឡាស (scirpophaga incertulas)។ ដង្កូវនេះកើតពីមេអំបៅពណ៌លឿង។ វាចោះស៊ីរូងចូលទៅក្នុងដើមឬក្បូរស្រូវផើម ធ្វើឱ្យស្រូវងាប់បណ្តូលនិងស្កក។ ដង្កូវនេះបំផ្លាញដើមស្រូវខ្លាំងជាងគេក្នុងចំណោមដង្កូវស៊ីរូងដើមស្រូវដទៃទៀត។ ដង្កូវស៊ីរូងដើមអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |
| ៦៤- **ដីវិទ្យា/ធរណីវិទ្យា**<br>អ. pedology<br>បារ. pédologie (f.) | វិទ្យាសាស្ត្រដែលសិក្សាពីប្រវត្តិ កំណកំណើត ការវិវត្ត លក្ខណៈរូប-គីមី លក្ខណៈជីវសាស្ត្រ និងចំណែកថ្នាក់ដី។ |
| ៦៥- **ដំណកដាំ**<br>អ.transplantation<br>បារ. transplan-tation (f.) | ១. ការដកអំប្រ៊ីយ៉ុងឬសរីរាង្គពីភាវៈរស់មួយ ទៅដាក់នឹងភាវៈរស់មួយទៀត ដូចជាការយកអំប្រ៊ី-យ៉ុងពីសត្វញីមួយទៅដាក់ក្នុងប្រដាប់បន្តពូជសត្វញីមួយទៀត។ |

| | |
|---|---|
| | ២. ការដករុក្ខជាតិទៅដាំឡើងវិញ ចំពោះស្រូវ គេហៅថា ការស្ទូង។ |
| ៦៦- **ដំណាំចំណី-សត្វ**<br>អ. forage<br>បារ. fourrage (f.) | ស្មៅនិងបន្លែសម្រាប់ឱ្យសត្វស៊ី។ |
| ៦៧- **តិណជាតិ**<br>អ. herb<br>បារ. herbe (f.) | ប្រភេទរុក្ខជាតិដែលតួដើមគ្មានសាច់ឈើ ទងស្លឹកទន់ និង ជាទូទៅ ស្លឹកពណ៌បៃតងអាចប្រើជាចំណីអាហារ ឱសថ ឬ គ្រឿងក្រអូប។<br>ឧ. បេក ពោត ស្រូវ អំពៅ ល្ហុង ជីរ បន្លែគ្រប់មុខ ព្រមទាំងស្មៅ... ជាតិណជាតិ។ |
| ៦៨- **តិណាសី**<br>អ. herbivore<br>បារ. herbivore (m.) | សត្វស៊ីស្មៅនិង/ឬរុក្ខជាតិជាអាហារ។<br>ឧ. គោ ក្របី ពពែ ចៀម សេះ ... ជាតិណាសី។ |
| ៦៩- **ត្រឡាច**<br>អ. wax gourd<br>បារ. courge cireuse (f.) | ប្រភេទលតាជាតិវារលើដីឬឡើងទ្រើង ដុះនៅតំបន់ត្រូពិក។ សំបកផ្លែខ្ចីពណ៌បៃតងស្រាល និងមានរោមឆ្មារៗ។ សំបកផ្លែចាស់ឡើងម្សៅពណ៌ស។ ផ្លែខ្ចីប្រើជាបន្លែ ផ្លែចាស់ធ្វើនំនិងតំណាប់។ ម្យ៉ាងទៀត ឫស ផ្លែ និង គ្រាប់ ប្រើជាឱសថ។ |
| ៧០- **ត្រឡាចស្រូវ** | ប្រភេទលតាជាតិវារលើដីមានផ្លែតូចជាងត្រឡាចធម្មតា។ គេនិយមដាំនៅរដូវសម្រក ចំពោះអ្នកចម្ការ និង អ្នកស្រែដាំនៅពេលច្រូតរួច។ ត្រឡាច |

| | |
|---|---|
| | នេះ គេប្រើតែផ្លែខ្ចីប៉ុណ្ណោះ សម្រាប់ធ្វើបន្លែ។ អ្នកខ្លះគេហៅ ត្រឡាចឃ្មើន។ |
| ៧១- **ថ្នាក់**<br>អ. class<br>បារ. classe ( f. ) | ផ្នែកសំខាន់នៃវត្ថុសាស្ត្រស្ថិតនៅបន្ទាប់ពីសាខា។<br>ឧ. មនុស្សស្ថិតក្នុងថ្នាក់ ម៉ាំម៉ាលីយ៉ា ( mam-malia )។ |
| ៧២- **ថ្នាំកសិកម្ម**<br>អ. pesticide<br>បារ. pesticide ( f. ) | សារធាតុសម្រាប់ការពារដំណាំនិងភោគផល ប្រឆាំងនឹងបរាសិត ផ្សិត ស្មៅ និង សត្វល្អិតចង្រៃ។<br>ឧ. ស៊ីប៉ឺរ៉ង់ cyperan ( cypermethrin ) ជាថ្នាំកសិកម្មប្រើសម្រាប់សម្លាប់សត្វល្អិតចង្រៃ ( មមាចត្នោត មមាចខៀវ )។ |
| ៧៣- **ថ្នាំកម្ចាត់ផ្សិត**<br>អ. fungicide<br>បារ. fongicide ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ផ្សិតចង្រៃ។<br>ឧ. កាបង់ស៊ីម ( cabenzim ), ម៉ង់ហ្គោសែប ( mengozeb ) ជាថ្នាំកម្ចាត់ផ្សិតចង្រៃ។ |
| ៧៤-**ថ្នាំកម្ចាត់សត្វកកេរ**<br>អ. rodenticide<br>បារ. rongicide/ rodenticide ( m. ) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ពពួកសត្វកកេរដូចជា កណ្ដុរ កំប្រុក ជាដើម។<br>ឧ. ហ្វូសាសីទីម ( phosacetim ) ជាថ្នាំកម្ចាត់ ឬសម្លាប់សត្វកកេរ។ |

| | |
|---|---|
| ៧៥- **ថ្នាំកម្ចាត់សិប្បីសត្វ**<br>អ. molluskicide<br>បារ. molluscicide<br>(m.) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់សិប្បីសត្វចង្រៃ។<br>ឧ. នីក្លូសាមីដ (niclosamide) ជាថ្នាំសម្រាប់កម្ចាត់ឬសម្លាប់សិប្បីសត្វ ដូចជាខ្យងក្រហម (ខ្យងពណ៌ក្រហម)បំផ្លាញស្រូវ។ |
| ៧៦- **ថ្នាំកម្ចាត់ស្មៅ**<br>អ. herbicide<br>បារ. herbicide<br>(m.) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់ស្មៅចង្រៃ។<br>ឧ. ប្រេទីឡាក្លរ(pretilachlor) និង ដឺកាត់ដេ (2,4D) ជាប្រភេទថ្នាំកម្ចាត់ស្មៅក្នុងដំណាំស្រូវ។ |
| ៧៧- **ថ្នាំសម្លាប់មីក្រុប**<br>អ. disinfectant<br>បារ. désinfectant<br>(m.) | ថ្នាំកសិកម្មមួយប្រភេទសម្រាប់កម្ចាត់ឬសម្លាប់មីក្រុប។<br>ឧ. ហ្វរម៉ាល់ដឺអ៊ីដ (formaldehyde) 2% ប្រើសម្រាប់កម្ចាត់ឬសម្លាប់វីរុស បាក់តេរី និង ភ្នាក់ងារចម្លងរោគនានា។ |
| ៧៨- **ថ្នាំសម្លាប់សត្វល្អិត**<br>អ. insecticide<br>បារ. insecticide<br>(m.) | សារធាតុឬផលិតផលទាំងឡាយប្រើប្រាស់សម្រាប់សម្លាប់សត្វល្អិត។<br>ឧ. ស៊ីបពែរ អាល់ហ្វា(cyper alpha 5ND) ជាថ្នាំសម្លាប់សត្វល្អិតនៅលើបន្លែ។ |
| ៧៩- **ទ្រីបស្រូវ**<br>អ. rice thrips | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនៅដំណាក់កាលលូតលាស់ដំបូង ដែលមានឈ្មោះវិទ្យាសាស្ត្រ ស្តង់-ស្តេតូទ្រីប ប៊ីហ្វ័រមីស (stenchaetothrips bifor- |

| | |
|---|---|
| | mis) ស្ថិតក្នុងសន្តានទ្រីពីដេ (thripidae) ប្រភេទស្តង់ស្ទេតូទ្រីប ប៊ីហ្វ័រមីស (stenchaetothrips biformis)។ ទ្រីបខ្លះមានស្លាប ខ្លះទៀតគ្មានស្លាប។ ទ្រីបស្រូវពេញវ័យមានប្រវែងពី ១ ទៅ ២ មិល្លីម៉ែត្រ។ វាពងលើស្លឹកស្រូវ។ ទ្រីបមានស្លាប និងទ្រីបគ្មានស្លាប ពេលទើបញាស់ មានពណ៌សគ្មានស្លាប រួចប្រែជាពណ៌ក្រមៅនៅពេលពេញវ័យ។ វាជញ្ជក់ស្លឹកស្រូវ ធ្វើឱ្យស្លឹកស្រូវស្ងួត រួចក្លាយជាពណ៌ត្នោត។ ពេលរាំងស្ងួត វាបំផ្លាញស្រូវនិងសំណាប ដោយធ្វើឱ្យស្លឹករមូរ។ ទ្រីបស្រូវអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |
| ៨០- **ទ្រីប៉ាណូសូម**<br>អ. trypanosomosis/ trypanosomiasis<br>បារ.trypanosome / trypanosomiase | ជំងឺបង្កដោយបរាសិតប្រូតូសូអ៊ែស្ថិតក្នុងប្រភេទទ្រីប៉ាណូសូម៉ា (trypanosoma) សន្តានទ្រីប៉ាណូសូម៉ាទីដេ (trypanosomatidae) បែកជាច្រើនប្រភេទដូចជា តេ.វីវ៉ាក់ (T. vivax), តេ. កុងហ្គោឡង់ (T. congolense), តេ. អេវ៉ង់ស៊ី (T. evansi), តេ. ស៊ូីស (T. suis), តេ. អេគីពែឌូម (T. equiperdum) , តេ. ព្រុយសេអ៊ី (T. brucei)។ ទ្រីប៉ាណូសូមនៃប្រភេទនីមួយៗបង្កជំងឺចំពោះប្រភេទសត្វផ្សេងៗគ្នានិងមនុស្ស។ ជំងឺនេះឆ្លងដោយសាររុយឬរបោមខាំបឺតឈាម។ រោគ |

| | |
|---|---|
| | សញ្ញាមានដូចជា ឡើងកម្តៅខ្លួនពី ៣៩,៥°c ទៅ ៤០°c ហើមកូនកណ្តុរ ស្លេកស្លាំង ខ្សោយ អស់កម្លាំង ស្រេកទឹកខ្លាំង ទឹកនោមពណ៌ទឹកក្រូច រលូតកូន ភាពស៊ាំចុះខ្សោយ សត្វអាចងាប់ភ្លាមៗ។ |
| ៨១- **ធូបនកម្ម**<br>អ. fumigation<br>បារ. fumigation (f.) | ការបង្ហុយផ្សែងឬឧស្ម័នគីមីសម្លាប់សត្វល្អិតឬមីក្រុប។ |
| ៨២- **ធូបនោសថ**<br>អ. fumigant<br>បារ. fumigant (m.) | សារធាតុចំហាយឬផ្សែង ប្រើសម្រាប់កម្ចាត់ឬសម្លាប់សត្វល្អិតនិងមីក្រុប។<br>ឧ. ម៉េទីល ប្រូមីដ (methyl bromide) ជាធូបនោសថ។ |
| ៨៣- **ធ្នូល**<br>អ. host<br>បារ. hôte (m.) | ភាវៈរស់ដែលបរាសិតរស់នៅក្រៅឬក្នុងខ្លួនភាវៈរស់នោះ ដោយប្រើវាជាជម្រកនិង/ឬជាប្រភពអាហារ។<br>ឧ. - គោជាធ្នូលរបស់ដង្កែ។<br>- ខ្យងលីមណេ (lymnée) ជាធ្នូលរបស់ហ្វាស្យូឡា (fasciola)។ |
| ៨៤- **ននោងជ្រុង**<br>អ. ridge gourd<br>បារ. papangay (f.) | ដំណាំវល្លិ វារឡើងទ្រើងមានប្រភពដុះនៅឥណ្ឌា។ ផ្លែរាងទ្រវែងមានជ្រុងច្រើន ប្រើជាបន្លែបានច្រើនមុខ។ ស្លឹកនិងផ្លែននោងជ្រុង ប្រើជាឱសថ។ |

| | |
|---|---|
| ៨៥- **ននោងទេស/ ននោងពស់**<br>អ. snake gourd | ប្រភេទននោងម្យ៉ាងមានផ្កាពណ៌សខុសពីននោងផ្សេងទៀតដែលមានផ្កាពណ៌លឿង។ ផ្លែមានរាងមូលតូចវែងមានឆ្នូតពណ៌សពព្លាក់តាមបណ្ដោយផ្លែ។ ននោងទាំងនេះគ្មានស្រកីដូចននោងជ្រុងនិងននោងមូលទេ។ ផ្លែ ប្រើជាអន្លក់និងបន្លែ ធ្វើជាសម្លបានច្រើនមុខ។ |
| ៨៦- **ននោងមូល/ ននោងសាញ**<br>អ. sponge gourd<br>បារ. éponge végétale (f.) | ដំណាំវល្លិ វារឡើងទ្រើង មានប្រភពដុះនៅតំបន់ត្រូពិក។ ផ្លែមូលទ្រវែង មានឆ្នូតតាមបណ្ដោយផ្លែ។ ផ្លែខ្ចីប្រើជាបន្លែ ឯផ្លែទុំហាលឲ្យស្ងួតប្រើសម្រាប់ជូតផ្ទះ ដុសលាងសម្អាតសម្ភារៈប្រើប្រាស់ផ្សេងៗ។ ម្យ៉ាងទៀត ផ្លែ ស្លឹក ឫស ប្រើជាឱសថ។ អ្នកខ្លះហៅថា ‹‹ននោងប្រហើរ ››។ |
| ៨៧- **និស្សារណ៍ / ត្រណក**<br>អ. extract<br>បារ. extrait (m.) | រូបធាតុដែលបានមកពីការដកចេញពីវត្ថុអ្វីមួយ។<br>ឧ. និស្សារណ៍ម្រះព្រៅបានមកពីការចម្រាញ់ចេញពីដើមម្រះព្រៅភ្នំ។ |
| ៨៨- **និស្សារណ-កម្ម / ដំណក**<br>អ. extraction<br>បារ.extraction (f.) | ដំណើរការដករូបធាតុចេញពីវត្ថុអ្វីមួយ។<br>ឧ. និស្សារណកម្មគ្រាប់ល្ហុងខ្វងបានជារូបធាតុប្រេងល្ហុងខ្វង (huile de ricin)។ |
| ៨៩- **នេសាទ**<br>អ. fishery<br>បារ. pêcherie (f.) | មុខរបរ សកម្មភាព ដែលទាក់ទងនឹងការប្រមូលផលមច្ឆជាតិ។ |

| | |
|---|---|
| ៩០- **បក្សីវប្បកម្ម**<br>អ. aviculture<br>បារ. aviculture<br>(f.) | ការចិញ្ចឹមបក្សី។ |
| ៩១- **បរាសិត**<br>អ. parasite<br>បារ. parasite<br>(m.) | ភាវៈរស់ដែលរស់នៅដោយសារគេ ដោយបឺត-ស្រូបយកអាហារពីធ្នល។<br>ឧ. ដង្កែជាបរាសិតរបស់គោ។ បញ្ញើក្អែកជាបរា-សិតរបស់រុក្ខជាតិ។ |
| ៩២- **បរាសិតក្នុង**<br>អ. endoparasite<br>បារ. endoparasite<br>(m.) | បរាសិតដែលរស់នៅក្នុងធ្នល។<br>ឧ. ពួកដង្កូវ/ព្រូនហ្វាស្យូឡា (fasciola) ជាបរាសិតក្នុងដែលរស់នៅក្នុងថ្លើម។ |
| ៩៣- **បរាសិតក្រៅ**<br>អ. ectoparasite<br>បារ. ectoparasite<br>(m.) | បរាសិតដែលរស់នៅក្រៅធ្នល។<br>ឧ. ចៃជាបរាសិតក្រៅ។<br>បញ្ញើក្អែកជាបរាសិតក្រៅ។ |
| ៩៤- **បសុវប្បកម្ម**<br>អ. animal husbandry<br>បារ. élevage (f.) | ការចិញ្ចឹមសត្វ។ |
| ៩៥- **បាក់តេរី**<br>អ. bacteria<br>បារ. bactérie (f.) | ភាវៈរស់ឯកកោសិកា មានទំហំតូច ប្រវែងដងខ្លួនប្រែប្រួលពី០,២ ទៅ ២០មីក្រុង (µm)ដែលមើលឃើញដោយមីក្រូទស្សន៍។ វាមានរាងជាស្វ៊ែរ ដំបង |

| | |
|---|---|
| | ឬ ក្បៀស...។ ជាធម្មជាតិ រាងរបស់វាមិនប្រែ-ប្រួលទេ តែ អាចប្រែប្រួលអាស្រ័យនឹងមជ្ឈដ្ឋានដែលវារស់នៅ។ ជួនកាល បាក់តេរីមានរោម ឬ ផ្លាហ្សែល (flagelle) ដែលមានមុខងារសម្រាប់ផ្លាស់ទីក្នុងមជ្ឈដ្ឋានដែលវារស់នៅ។<br>បាក់តេរីចែកជាពីរប្រភេទ គឺ បាក់តេរីក្រាមបូក និង បាក់តេរីក្រាមដក។ |
| ៩៦- **បាក់តេរីក្រាមដក**<br>អ. gram-negative bacteria<br>បារ. bactéries gram-négatives (f.) | ក្រុមបាក់តេរីដែលមិនចាប់យកពណ៌ស្វាយក្រោយពេលប្រើវិធីសាស្ត្រដាក់ពណ៌(gram staining)។ បាក់តេរីទាំងនោះមាន សាល់ម៉ូណែឡា (salmo-nella) អ៊ី កូលី (E. coli / Escherichia coli) ប្រ៊ូសេឡា (brucella) និង កំពីឡូបាក់ទែរ (cam-pylobacter)។ល។ |
| ៩៧- **បាក់តេរីក្រាមបូក**<br>អ. gram-positive bacteria<br>បារ. bactéries gram-positives (f.) | ក្រុមបាក់តេរីដែលចាប់យកពណ៌ស្វាយ ក្រោយពេលប្រើវិធីដាក់ពណ៌ (gram staining)។ បាក់-តេរីទាំងនោះមាន ស្តាហ្វីឡូកូក (staphylococ-cus) ស្ត្រិបតូកូក (streptococcus) ក្លូសទ្រី-ដ្យូម(clostridium) បាស៊ីលូស(bacillus) ។ល។ |
| ៩៨- **បាណកសត្វ**<br>អ. insect<br>បារ. insecte (m.) | សត្វល្អិតគ្មានឆ្អឹងខ្នងមានដងខ្លួនកង់ៗចែកជាបីផ្នែក ក្បាល ទ្រូង និង ពោះ មានជើងបីគូ ពុកឬអង់តែនមួយគូ ហើយ ជាទូទៅ មានស្លាប។ |

| | |
|---|---|
| | ឧ. ស្រមោច មូស មេអំបៅ រុយ ឃ្មុំ ... ជាបាណកសត្វ។ |
| ៩៩- **បាណកវិទ្យា**<br>អ. entomology<br>បារ. entomologie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសត្វល្អិត។ |
| ១០០- **បាណកាសី**<br>អ. insectivore<br>បារ. insectivore (m.) | រុក្ខជាតិនិងសត្វទាំងឡាយណាដែលស៊ីសត្វល្អិតជាអាហារ។<br>ឧ. បំពង់ស្រមោច/ផ្កាបំពង់(népenthès) កង្កែប ត្រចៀកកាំ... ជាបាណកាសី។ |
| ១០១- **ប្រពលវប្បកម្ម**<br>អ. intensive culture<br>បារ. culture intensive (f.) | ការធ្វើកសិកម្មតាមបច្ចេកទេសដើម្បីទទួលបានទិន្នផលខ្ពស់។ |
| ១០២- **ប្រភេទ**<br>អ. species<br>បារ. espèce (f.) | ផ្នែកតូចបំផុតនៃវគ្គីសាស្ត្រ។<br>ឧ. ល្ងស្ថិតក្នុងប្រភេទ សេសាមូម អាំងឌីកូម (sesamum indicum)។ |
| ១០៣- **ផ្អកស្មៅ**<br>អ. silage<br>បារ. ensilag (m.) | ស្មៅផ្អាប់ធ្វើជាចំណីសម្រាប់ឱ្យសត្វស៊ី។ |

| | |
|---|---|
| ១០៤- **ពន្លៃ**<br>អ. cassumar<br>ginger<br>បារ. gingembre<br>cassumunar | តិណជាតិមានមើមពណ៌លឿងខ្ចីមានក្លិនប្រហើរ។ គេច្រើនដាំជិតផ្ទះសម្រាប់ប្រើជាឱសថ។<br>ឧ. នៅតាមជនបទ គេនៅនិយមបុកស្លឹកឬមើមពន្លៃសម្រាប់បិទលើបង្ហើយកូនខ្ចី។ ម្យ៉ាងទៀត គេបុកមើមពន្លៃត្រាំក្នុងស្រាសម្រាប់លាបឬបំពោកលើសន្លាក់ឆ្អឹង ឬ កន្លែងដាំសាច់ដោយសារការប៉ះទង្គិច។ តាមទម្លាប់ គេប្រើថែរក្សាស្បែក និង មើមបុកជាម្សៅអាចប្រើជាថ្នាំទម្លាក់ព្រូននិងអៀន។ |
| ១០៥- **ពួក**<br>អ. genus<br>បារ. genre (m.) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីសន្តាន។<br>ឧ. សណ្តែកបាយស្ថិតក្នុងពួក វីញ៉ា (vigna)។ |
| ១០៦- **ពោត**<br>អ. maize<br>បារ. maïs (m.) | តិណជាតិដែលមានឈ្មោះវិទ្យាសាស្ត្រ សៀម៉ា-អ៊ីស (zea mays) សន្តានហ្គ្រាមីណេអា/ប៉ូអា-សេអា (gramineae/poaceae) ស្ថិតក្នុងប្រភេទសៀម៉ាអ៊ីស(zea mays) ដុះនៅលើដីគោកដែលគេដាំនៅលើដីគោកក្នុងតំបន់ក្តៅនិងត្រជាក់បង្គួរ។ គ្រាប់វាប្រើជាអាហារសម្រាប់មនុស្សនិងសត្វ។ |
| ១០៧- **មច្ឆវប្បកម្ម**<br>អ. pisciculture<br>បារ. pisciculture<br>(f.) | ការចិញ្ចឹមត្រី។ |

| | |
|---|---|
| ១០៨- **មធុវប្បកម្ម**<br>អ. apiculture/<br>bee keeping<br>បារ. apiculture<br>(f.) | ការចិញ្ចឹមឃ្មុំ។ |
| ១០៩- **មមាចត្នោត**<br>អ. brown<br>planthopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងដំណាំផ្សេងៗទៀត ដែលមានឈ្មោះវិទ្យាសាស្ត្រ នីឡាប៉ារ៉ាតា លុយហ្សង់ (nilaparvata lugens) ស្ថិតក្នុងសន្តានដែលហ្វាស៊ីដេ (delphacidae) ប្រភេទនីឡាប៉ារ៉ាតា លុយហ្សង់ (nilaparvata lugens)។ សត្វនេះមានរាងតូច ស្តើង ប្រវែងពី៤ទៅ៥មិល្លីម៉ែត្រ សម្បុរត្នោត ហើយ មានពីរប្រភេទគឺ ប្រភេទស្លាបវែង និង ប្រភេទស្លាបខ្លី។ ពងវាពណ៌សរាងដូចផ្លែចេកប្រវែងប្រហែល១មិល្លីម៉ែត្រ។ កូនញាស់មានទំហំតូចល្អិតពណ៌លឿងខ្ចីឬត្នោតខ្ចី។ មមាចត្នោតពេញវ័យ និង កូនរបស់វាចុចជញ្ជក់យករសពីដំណាំស្រូវនិងដំណាំផ្សេងៗទៀតស្ទើរតែគ្រប់ដំណាក់កាលលូតលាស់ ជាពិសេស នៅមុនពេលចេញផ្កា។ |
| ១១០- **មមាចបៃតង**<br>អ. green leaf-<br>hopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវនិងដំណាំផ្សេងៗទៀត ស្ថិតក្នុងសន្តានស៊ីកាដែលីដេ (cicadellidae) ពួកណេហ្វូតេទិច (nephotettix)។ មេពេញវ័យមានពណ៌បៃតងភ្លឺ។ ពងរបស់វាមានរាង |

| | |
|---|---|
| | មូលទ្រវែង ពណ៌សឬលឿងខ្ចី បន្ទាប់មកប្រែជាពណ៌ត្នោតនិងស្នាមអុចពណ៌ក្រហម។ កូនមមាចបៃតងមានពណ៌លឿងខ្ចី មានបន្ទាតូចៗនៅលើខ្នងផ្នែកខាងក្រោយ។ មមាចបៃតងចុចជញ្ជក់រុក្ខ-រសស្លឹកស្រូវនៅស្ទើរគ្រប់ដំណាក់កាលលូតលាស់ ជាពិសេស នៅមុនពេលស្រូវចេញផ្កា។ (គេនិយមហៅ មមាចបៃតង ថា មមាចខៀវ)។ |
| ១១១- **មមាចពព្រុស**<br>អ. zigzag leaf-hopper | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ រ៉ីស៊ីលីយ៉ា ឌ័រសាលីស (recilia dorsalis) ស្ថិតក្នុងសន្តានស៊ីកាដែលីដេ (cicadellidae) ប្រភេទរ៉ីស៊ីលីយ៉ា ឌ័រសាលីស (recilia dorsalis)។ ស្លាបរបស់មមាចពព្រុសពេញវ័យមានរាងក្ងិកក្ងក់។ មេរបស់វាពងរាយមួយៗនៅលើស្រទបស្លឹក ហើយ កូនញាស់មានពណ៌ត្នោតលឿង។ វាចុចជញ្ជក់រុក្ខរសស្លឹកស្រូវនៅស្ទើរគ្រប់ដំណាក់កាលលូតលាស់ ជាពិសេស នៅមុនពេលស្រូវចេញផ្កា។ សត្វល្អិតចង្រៃនេះចុចជញ្ជក់រុក្ខរសស្រូវផ្ទាល់ ហើយ ធ្វើឱ្យចុងស្លឹកស្រូវស្ងួត ស្លឹកទាំង-មូលក្លាយជាពណ៌ទឹកក្រូច ឯគែមស្លឹករមូរ ធ្វើឱ្យស្រូវកើតជំងឺមួយចំនួនដែលបង្កដោយពពួកវីរុស។ មមាចពព្រុសអាចបំផ្លាញដំណាំផ្សេងៗទៀតដែរ។ |

| | |
|---|---|
| ១១២- **មីក្រុប/ មេរោគ**<br>អ. microbe<br>បារ. microbe (m.) | ភាវៈរស់តូចល្អិតដែលគេអាចមើលឃើញតែដោយ-សារមីក្រូទស្សន៍ដូចជា ពួកប្រូតូសូអ៊ែ បាក់តេរី ផ្សិតហ្វុងហ្ស៊ី(fungi) វីរុស ។ល។<br>ឧ. មីក្រុបអាបតូវីរុស (aphthovirus) បង្កជំងឺអុតក្ដាម(FMD)។ |
| ១១៣- **មីក្រុបវិទ្យា**<br>អ. microbiology<br>បារ. microbiologie (f.) | វិទ្យាសាស្ត្រសិក្សាពីមីក្រុប។ |
| ១១៤- **មុទ្ទិវប្បកម្ម**<br>អ. viticulture<br>បារ. viticulture (f.) | ការដាំទំពាំងបាយជូរ។ |
| ១១៥- **មូសប្លុង**<br>អ. gall midge/ rice gall midge<br>បារ. cécidomyie (f.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ អ័រសេអូលីយ៉ា អ័រីសេ (orseolia oryzae) ស្ថិតក្នុងសន្តានសីស៊ីដូមីអ៊ីអ៊ីដេ (ceci-domyiidae) ប្រភេទអ័រសេលីយ៉ា អ័រីសេ (orse-olia oryzae)។ មូសប្លុងឈ្មោលពេញវ័យមានពណ៌លឿងត្នោតនិងមានមាឌតូចជាងមូសប្លុងញីដែលមានពោះពណ៌ក្រហម។ មូសប្លុងញីពងបានពី ១០០ ទៅ ២០០ពង។ វាពងលើស្លឹកស្រូវនិងមានជីវិតត្រឹមតែ៤ទៅ៥ថ្ងៃប៉ុណ្ណោះ។ ដង្កូវដែល |

| | |
|---|---|
| | ទើបញាស់មានពណ៌សស្រអាប់។ ភាគច្រើន វាលាក់ខ្លួនក្នុងដើមស្រូវ និង ស៊ីបំផ្លាញបណ្ដូលដើមស្រូវដោយធ្វើឱ្យស្លឹកស្រូវរមូរហើយមានរាងដូចស្លឹកខ្ទឹមបារាំង។ មូសប្លុងអាចស៊ីបំផ្លាញដំណាំស្រូវចាប់តាំងពីដំណាក់កាលសំណាបរហូតដល់ចុងបញ្ចប់នៃដំណាក់កាលបែកគុម្ព។ មូសនេះអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| ១១៦- **មេល័ក្ត/ មេល័ខ**<br>អ. lac insect<br>បារ. cochenille (f.) | សត្វល្អិតរស់នៅលើរុក្ខជាតិ ដែលសម្បុករបស់វាមានសារធាតុជ័រខាប់ ពណ៌ក្រហម សម្រាប់ប្រើជាពណ៌ជ្រលក់សូត្រឬអំបោះ។<br>ឧ. ជំនាន់មុន ប្រជាជនខ្មែរនិយមចិញ្ចឹមមេល័ខដើម្បីយកពណ៌ជ្រលក់សូត្រឬអំបោះ។ |
| ១១៧- **មំសាសី/ មំសាហារសត្វ**<br>អ. carnivore<br>បារ. carnivore (m.) | សត្វស៊ីសាច់ជាអាហារ។<br>ឧ. ខ្លា តោ...ជាមំសាសី។ |
| ១១៨- **រជ្ជៈ**<br>អ. kingdom<br>បារ. règne (m.) | ផ្នែកធំបំផុតនៃវគ្គីសាស្ត្រ។ រជ្ជៈមានពីរប្រភេទ គឺរជ្ជៈរុក្ខជាតិ (règne végétal) និង រជ្ជៈសត្វ (règne animal)។<br>ឧ. ស្រូវស្ថិតក្នុងរជ្ជៈរុក្ខជាតិ គោស្ថិតក្នុងរជ្ជៈសត្វ។ |

| | |
|---|---|
| ១១៩- **រមៀត/ ល្មៀត**<br>អ. turmeric<br>បារ. curcuma/ safran des indes (m.) | តិណជាតិមានមើមពណ៌លឿងមានក្លិនប្រហើរ ប្រើជាគ្រឿងទេស ជាឱសថ ជាគ្រឿងសម្អាងកាយ និង ជាពណ៌ជ្រលក់ផងដែរ។<br>ឧ. នារីខ្មែរនិយមយកល្មៀតលាបមុខនិងដងខ្លួន ដើម្បីឱ្យស្បែកមានសម្រស់ល្អ។ រមៀតអាចជួយព្យាបាលជំងឺសើស្បែក, រលាកក្រពះ ពោះវៀន, សម្រួលការរំលាយអាហារ និង ជំរុញការបញ្ចេញទឹកប្រមាត់ជាដើម។ |
| ១២០- **រុក្ខរំពា**<br>អ. carnivorous plants<br>បារ. plante carnivore (f.) | រុក្ខជាតិដែលចាប់សត្វជាអាហារ។<br>ឧ. រុក្ខជាតិបំពង់ស្រមោច(népenthès) ជារុក្ខរំពា។ |
| ១២១- **រុក្ខវិទ្យា**<br>អ. botany<br>បារ. botanique (f.) | វិទ្យាសាស្ត្រសិក្សាអំពីរុក្ខជាតិ។ |
| ១២២- **រូបសាស្ត្រ/ សណ្ឋានវិទ្យា/ ទម្រង់វិទ្យា**<br>អ. morphology<br>បារ. morphologie (f.) | វិទ្យាសាស្ត្រសិក្សាពីទម្រង់ រូបរាងទូទៅ និង រចនាសម្ព័ន្ធនៃភាវៈរស់និងភាវៈគ្មានជីវិត។<br>ឧ. រូបសាស្ត្រស្រូវមាន ឫស ដើម ស្លឹក។ |

| | |
|---|---|
| ១២៣- **រំដេង**<br>អ. galangal<br>បារ. galanga (m.) | តិណជាតិមានមើមពណ៌លឿងខ្ចី មានក្លិនហឹរធួល ប្រើជាគ្រឿងទេស និង ជាឱសថ។<br>ឧ. ជនជាតិខ្មែរប្រើរំដេងសម្រាប់បង់សម្លដើម្បីកាត់ចម្អាបនិងបង្កើនរសជាតិ។ មើម ហាលឱ្យស្ងួត កិនជាម្សៅ មានប្រសិទ្ធភាពជួយរំលាយអាហារ ឬ ព្យាបាលរោគហើមពោះ ផ្តាសាយ ឈឺធ្មេញ ចុកធ្លល់ពោះ។ |
| ១២៤- **រំពា**<br>អ. prey<br>បារ. proie (f.) | សត្វដែលជាចំណីអាហាររបស់សត្វដទៃទៀត។<br>ឧ. ខ្លាចាប់ឈ្លូសស៊ីជាអាហារ។ ឈ្លូសជារំពារបស់ខ្លា។ |
| ១២៥- **លីកែន**<br>អ. lichen<br>បារ. lichen (m.) | រុក្ខជាតិសហប្រាណដែលកើតឡើងពីសារាយតូចល្អិតនិងផ្សិតសរសៃឆ្មារៗ ស្រដៀងនឹងស្លែដែលដុះនិងធ្វើរស្មីសំយោគជាមួយគ្នា។<br>ឧ. លីកែនគ្រូស្តូស (crustose lichen) ដុះនៅលើជញ្ជាំង។ |
| ១២៦- **លំដាប់**<br>អ. order<br>បារ. ordre (m.) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីថ្នាក់។<br>ឧ. សណ្តែកសៀងស្ថិតក្នុងលំដាប់ហ្វាបាល (fabales)។ |
| ១២៧- **វគ្គីសាស្ត្រ**<br>អ. taxonomy<br>បារ. taxonomie / taxinomie (f.) | វិទ្យាសាស្ត្រដែលសិក្សាអំពីចំណាត់ថ្នាក់ភាវៈរស់/សព៌ាង្គកាយរស់ ដោយផ្អែកលើចរិតលក្ខណៈរួម។ |

| | |
|---|---|
| ១២៨- **វនវិទ្យា**<br>អ. forestry<br>បារ. foresterie ( f. ) | វិទ្យាសាស្ត្រសិក្សាពីការដាំដុះ ការថែទាំ និង ការធ្វើអាជីវកម្មព្រៃឈើ។ |
| ១២៩- **វប្បកម្ម**<br>អ. culture/<br>cultivation/<br>husbandry<br>បារ. culture ( f. ) | ការដាំដុះឬការចិញ្ចឹម។ |
| ១៣០- **វប្បកម្ម កៅស៊ូ**<br>អ. heveaculture<br>បារ. hévéaculture ( f. ) | ការដាំកៅស៊ូ។ |
| ១៣១- **វប្បកម្មស្រូវ**<br>អ. rice cultivation<br>បារ. riziculture ( f. ) | ការដាំស្រូវ។ |
| ១៣២- **វារីវប្បកម្ម**<br>អ. aquaculture<br>បារ. aquaculture ( f. ) | ការដាំរុក្ខជាតិ ឬ ការចិញ្ចឹមសត្វ ក្នុងទឹក។ |
| ១៣៣- **សង្កើច**<br>អ. bedbug, housebug<br>បារ. punaise ( f. ) | សត្វល្អិតជាបរាសិតជញ្ជក់ឈាមរស់នៅក្បែរខ្លួនមនុស្សដូចជា តាមកន្ទេល ខ្នើយ គ្រែ រនាបផ្ទះជាដើម។<br>ឧ. គេនិយមយកសំបកទុរេនដាក់ក្រោមគ្រែដើម្បីដេញសង្កើច។ |

| | |
|---|---|
| ១៣៤- **សត្តវិទ្យា**<br>អ. zoology<br>បារ. zoologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីសត្វនិងអត្តចរិតរបស់សត្វ។ |
| ១៣៥- **សត្វក្រពះទោល**<br>អ. monogastic animal<br>បារ. monoga-stique ( f. ) | ពពួកសត្វដែលមានក្រពះតែមួយ។<br>ឧ. ជ្រូក ទន្សាយ សេះ ... ជាសត្វក្រពះទោល។ |
| ១៣៦- **សត្វទំពា-អៀង**<br>អ. ruminant<br>បារ. ruminant ( m. ) | ពពួកសត្វដែលមានក្រពះច្រើនថត (ថតបួនចំពោះ គោ ចៀម ពពែ និង ថតបី ចំពោះអូដ្ឋដែលគ្មានពោះស្រទាប់ ហើយ ថតទាំងអស់មានទំនាក់ទំនងនឹងគ្នា)ស៊ីនិងផ្ទុកចំណីក្នុងក្រពះមួយរយៈពេល រួចក្អែចំណីនោះមកទំពាសាឡើងវិញ។ |
| ១៣៧- **សត្វរំពា**<br>អ. predator<br>បារ. prédateur( m. ) | សត្វដែលស៊ីសាច់សត្វដទៃជាអាហារ។<br>ឧ. ឆ្មាចាប់កណ្តុរស៊ីជាអាហារ។ ឆ្មាជាសត្វរំពា។ |
| ១៣៨- **សន្តាន**<br>អ. family<br>បារ. famille ( f. ) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីលំដាប់។<br>ឧ. វីរុសជំងឺអុតក្តាមស្ថិតក្នុងសន្តានពីគ័រណាវីរីដេ ( picornaviridae )។ |
| ១៣៩- **សព្វាសី**<br>អ. omnivore<br>បារ. omnivore ( m. ) | សត្វស៊ីអាហារគ្រប់ប្រភេទមានសាច់ រុក្ខជាតិជាដើម។<br>ឧ. ជ្រូកជាសព្វាសី។ |

| | |
|---|---|
| ១៤០-**សហប្រាណ**<br>អ. symbiosis<br>បារ. symbiose<br>(f.) | ភាវៈរស់ពីរឬច្រើនប្រភេទដែលរស់នៅជាមួយគ្នាហើយទាញប្រយោជន៍ពីគ្នាទៅវិញទៅមក។<br>ឧ₁. ទំនាក់ទំនងរវាងសារាយ (coccomyxa) និងផ្សិត (omphalina) ជាសហប្រាណ។<br>ឧ₂. ទំនាក់ទំនងរវាងត្រីសមុទ្រ (clownfish) និងសារាយសមុទ្រ (sea anemone) ជាសហ-ប្រាណ។ |
| ១៤១- **សាកវប្ប-កម្ម/វប្បកម្មដំណាំសួន**<br>អ. horticulture<br>បារ. horticulture<br>(f.) | ដំណាំច្បារ(បន្លែ ផ្លែ ផ្កា)។ |
| ១៤២- **សាខា**<br>អ. phylum<br>បារ. embranche-ment (m.) | ផ្នែកសំខាន់នៃវគ្គីសាស្ត្រស្ថិតនៅបន្ទាប់ពីរជ្ជៈ។<br>ឧ. ស្រូវស្ថិតក្នុងសាខា ម៉ាញ៉ូលីយ៉ូហ្វីតា (magnoliophyta)។ |
| ១៤៣- **សាប្រូហ្វីត**<br>អ. saprophyte<br>បារ. saprophyte<br>(m.) | ភាវៈរស់ដែលរស់នៅអាស្រ័យដោយសារធាតុសរីរាង្គងាប់ឬផុយរលួយ។<br>ឧ. ផ្សិតចំបើងជាសាប្រូហ្វីតស្ថិតក្នុងប្រភេទវ៉ូលវ៉ារីយេឡា វ៉ូវ៉ាសេអា (volvariella volvacea), ពួកវ៉ូលវ៉ា រីយេឡា (volvariella), សន្តានក្លុយតេអា-សេអា (pluteaceae)។ |

| | |
|---|---|
| ១៤៤- **សារាយ**<br>អ. algae<br>បារ. algue (f.) | វារីជាតិមួយប្រភេទគ្មានឫស គ្មានដើម មានតាល់ (thalle)អាចធ្វើរស្មីសំយោគបាន។<br>ឧ. ស្ទីហ្សេអូក្លូនីញ៉ូម អេស្ទីវ៉ាល់ (stigeoclonium aestivale) ជាសារាយមួយប្រភេទ។ |
| ១៤៥-**សុខុមាកាស**<br>អ. microclimate<br>បារ. microclimate (f.) | ធាតុអាកាសកំណត់នៃទីតាំងតូចណាមួយដែលខុសពីអាកាសធាតុជុំវិញ។<br>ឧ. នៅក្នុងច្បារបន្លែស្ពៃក្ដោប សុខុមាកាសសមស្របត្រូវមានពី ២៩°C ទៅ ៣០°C។ |
| ១៤៦- **សេរ៉ូទីប**<br>អ. serotype/ serovar<br>បារ. sérotype (f.) | ការបែងចែកពពួកបាក់តេរី វីរុស ឬ មីក្រូសព៌ាង្គកាយ ដោយផ្អែកលើលក្ខណៈអង់ទីហ្សែនរបស់បាក់តេរី វីរុស ឬ មីក្រូសព៌ាង្គកាយទាំងនោះ។<br>ឧ. វីរុសជំងឺអុតក្ដាមត្រូវបានបែងចែកជា៧សេរ៉ូទីប គឺ សេរ៉ូទីបអា (A), អូ(O), អាស៊ី I (ASIA I), សេ (C), សាត I (SAT I), សាត II (SAT II), និង សាត III (SAT III)។ |
| ១៤៧- **ស្រមើល**<br>អ. tiny bug | សត្វល្អិតតូចក្រៃលែងស្ទើរមើលពុំឃើញច្រើនកើតនៅកន្លែងឬលើវត្ថុផ្សេងៗដូចជា ទ្រុង មាន់ ទ្រុងទា សម្បុកសត្វ សំបកស៊ុត ជាដើម។<br>ឧ. ស្រមើលរោមសើបសោវនាំឱ្យដេកមិនលក់។ |

| | |
|---|---|
| ១៤៨- **ស្រឹងស្រូវ**<br>អ. rice bug / rice ear bug<br>បារ. bug de riz (m.) | សត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលមានឈ្មោះវិទ្យាសាស្ត្រ ឡេបតូកូរីសា អូរ៉ាតូរីយូស (leptocorisa oratorius) ស្ថិតក្នុងសន្តានអាលីឌីដេ (alydidae) ប្រភេទឡេបតូកូរីសា អូរ៉ាតូរីយូស(leptocorisa oratorius)។ ស្រឹងពេញវ័យមានពណ៌បៃតងត្នោត មានជើងវែងៗ និង មានបណ្ដោយដងខ្លួនប្រហែល១៥មិល្លីម៉ែត្រ និង ទទឹងប្រវែង៣មិល្លីម៉ែត្រ។ ស្រឹងទើបញាស់រហូតដល់ពេញវ័យចុចជញ្ជក់បំផ្លាញគ្រាប់ស្រូវ ជាពិសេស ពីដំណាក់កាលចេញផ្ការហូតដល់ដំណាក់កាលដាក់ទឹកដោះ។ វាបំផ្លាញគ្រាប់ស្រូវនៅពេលព្រឹកព្រលឹមនិងពេលល្ងាច រួចលាក់ខ្លួននៅកន្លែងម្លប់។ អ្នកស្រុកនិយមហៅស្រឹងស្រូវថា ស្រឹងជញ្ជក់ទឹកដោះ ឬ ស្រឹង ឬ ត្រឹង។ ស្រឹងអាចបំផ្លាញដំណាំផ្សេងទៀតដែរ។ |
| ១៤៩- **ស្រូវ**<br>អ. rice<br>បារ. riz (m.) | តិណជាតិដែលមានឈ្មោះវិទ្យាសាស្ត្រ អូរីសា សាទីវ៉ា (oryza sativa) សន្តានហ្គ្រាមីណេអា/ប៉ូអាសេអា (gramineae/poaceae) ស្ថិតក្នុងប្រភេទអូរីសា សាទីវ៉ា (oryza sativa)ដុះលើដីគោកឬដីលិចទឹក ដែលគេដាំនៅតំបន់ក្ដៅសើម ហើយ គ្រាប់របស់វាប្រើជាអាហារសំខាន់សម្រាប់មនុស្សនិងសត្វ។ |

| | |
|---|---|
| ១៥០- **ស្ត្រិបតូកុក-<br>កូសជ្រូក**<br>អ. streptococcus<br>in swine<br>បារ. streptocoque<br>(m.) | ជំងឺបង្កដោយបាក់តេរីស្ថិតក្នុងសន្តានស្ត្រិបតូកុក-<br>កូកាសេអា (streptococcaceae) ពួកស្ត្រិបតូ-<br>កុកគូស (streptococcus) ប្រភេទស្ត្រិបតូកុក-<br>គូស ស៊ីស (streptococcus suis) ជាបាក់តេរី<br>ក្រាមបូក ចែកជាច្រើនសេរ៉ូទីប។ សេរ៉ូទីបដែល<br>ធ្វើឱ្យជ្រូកឈឺងាប់ មានពីរប្រភេទគឺ ស្ត្រិបតូកុក-<br>គូស ស៊ីស ប្រភេទទី១និងប្រភេទទី២។ ប្រភេទទី<br>១ កើតចំពោះកូនជ្រូកទើបកើតដល់អាយុ៨សប្តាហ៍<br>ចំណែកប្រភេទទី២ កើតចំពោះជ្រូកធំ។ រោគ<br>សញ្ញាមានដូចជា ឡើងកម្តៅខ្លួនពី ៤១°C ទៅ<br>៤២°C មិនស៊ីចំណី មិនសូវធ្វើចលនា ពិបាកដើប<br>ឈរដោយសារលោកសន្លាក់ ឈឺសន្លាក់ មានរោគ-<br>សញ្ញាសរសៃប្រសាទ ប្រកាច់ ខ្វាក់ ថ្លង់, មេផើម<br>អាចរលូតកូន រលាកស្រោមខួរ ហើមសួត រលាក<br>ភ្នាសនិងសាច់ដុំបេះដូង និង រលាកសាច់ដុំខួរ-<br>ក្បាល។ |
| ១៥១- **ស្លែ**<br>អ. moss<br>បារ. mousse (f.) | រុក្ខជាតិមួយប្រភេទតូចល្អិត គ្មានផ្កា ដុះក្នុង<br>មជ្ឈដ្ឋានសើម (លើដី លើឈើ លើថ្ម)។<br>ឧ. ស្លែព្រីយ៉ូម ឡាវីហ្វីល (bryum laevifilum)<br>ជាស្លែនៅលើដើមឈើ។ |
| ១៥២- **អង្គែ**<br>អ. dandruff<br>បារ. pellicule<br>(f.) | រោគសើស្បែកម្យ៉ាងដែលមានសណ្ឋានរបកជា<br>ស្រទាប់ស្តើងៗ បណ្តាលឱ្យស្បែកឡើងគគ្រាត<br>សម្បុរសហើយរមាស់។ វាច្រើនកើតនៅកន្លែងដុះ<br>សក់ឬរោម។<br>ឧ. ក្បាលកើតអង្គែ, ឆ្កែអង្គែស៊ី។ |

| | |
|---|---|
| ១៥៣- **អាកាស-ធាតុវិទ្យា**<br>អ. climatology<br>បារ. climatologie (f.) | វិទ្យាសាស្ត្រសិក្សាពីអាកាសធាតុនិងបាតុភូតរបស់វា។ |
| ១៥៤- **អាណាប្លា-ស្មូស**<br>អ. anaplasmosis / anaplasmiasis<br>បារ. anaplasmose (f.) | ជំងឺបង្កដោយបរាសិតស្ថិតក្នុងសន្តានអឺលីស្យាសេ-អា (ehrlichiaceae) ពួកអាណាប្លាស្មា (anapla-sma) កើតចំពោះគោ ក្របី ចៀម ពពែ ឆ្កែ សេះ បង្កង់ ក្តាន់ ឈ្លូស ប្រើស អូដ្ឋ ប៉ុន្តែ គោជាសត្វដែលរងការរាតត្បាតខ្លាំងជាងគេ ពិសេស គោពេញវ័យ។ ចំពោះគោ ជំងឺនេះបង្កដោយបរាសិត មានពីរប្រភេទ គឺ ប្រភេទអា. ម៉ារហ្សិណាល់ (A. mar-ginale) និង អា. សង់ត្រាល់ (A. centrale)។ ចំពោះចៀម បង្កដោយបរាសិតប្រភេទអា. អូវីស (A. ovis)។ បរាសិតរស់ក្នុងគោលិកាក្រហមរបស់គោនិងចម្លងទៅដង្កែតាមរយៈការខាំបឺតឈាម។ នៅក្នុងសារពាង្គកាយ ដង្កែបរាសិតបន្តពូជរីកលូតលាស់ជាច្រើនដំណាក់កាល ហើយ ចម្លងទៅសត្វដទៃទៀតដោយសារការខាំបឺតឈាមសត្វនោះ។ ក្រៅពីដង្កែ រុយបឺតឈាម របោម និង មូស ក៏ជាភ្នាក់ងារចម្លងជំងឺនេះដែរ។ រោគសញ្ញាមានដូចជាឡើងកម្ដៅខ្លួនពី ៤០°C ទៅ ៤១°C ភ្នាសសើម |

| | |
|---|---|
| | ស្លេក ឬដួនកាល ពណ៌លឿង គោលិកាក្រហមមានពណ៌ប្រឿងៗ ឈាមរាវ ចំនួនគោលិកាក្រហមចុះថយខ្លាំង មិនឃ្លានចំណីឬមិនស៊ីចំណីតែម្តង រាករូស ចុះស្គមលឿន រាងកាយទ្រុឌទ្រោមខ្លាំង និងកង្វះគោលិកាក្រហមបណ្តាលឱ្យសត្វកើតជំងឺខាន់លឿង។ |
| ១៥៥- **អ៊ីប្រ៊ីត**<br>អ. hybrid<br>បារ. hybride<br>(m.) | សត្វឬរុក្ខជាតិដែលជាលទ្ធផលនៃការបង្កាត់ពូជប្រភេទដូចគ្នាឬខុសគ្នា។<br>ឧ.ប្រភេទដូចគ្នា៖<br>១- ជ្រូកពូជឡង់ដ្រាស(landrace)បង្កាត់ជាមួយជ្រូកពូជយ៉កសៀ(yorkshire) ផ្តល់ជំនាន់ក្រោយ ឡង់យ៉ក (land york)។<br>២- ពូជស្មៅប្រាស្សារីយ៉ា រូស៊ីសៀងស៊ីស ឬ រូស៊ី(bracchiaria ruziziensis) បង្កាត់ជាមួយប្រាស្សារីយ៉ាប្រ៊ីសង់តាឬម៉ារ៉ាន់ឌូ(bracchiaria brizantha) ផ្តល់ជំនាន់ក្រោយ ប្រាស្សារីយ៉ាអ៊ីប្រ៊ីត ឬ មូឡាតូ2(bracchiaria hybrid)។<br>ឧ. ប្រភេទខុសគ្នា៖<br>លាឈ្មោលបង្កាត់ជាមួយសេះញី ផ្តល់ជំនាន់ក្រោយ មូឡេ (mulet)។ សេះឈ្មោលបង្កាត់ជាមួយលាញី ផ្តល់ជំនាន់ក្រោយបារដូ(bardot)។<br>មូឡេនិងបារដូជាអ៊ីប្រ៊ីត។ ជាទូទៅ អ៊ីប្រ៊ីត មិនអាចបន្តពូជបានទេ ឬ អារ តែ អ៊ីប្រ៊ីតញីអាចបន្តពូជ ក្នុងករណីកម្រ។ |

| | |
|---|---|
| ១៥៦- **អ៊ីប្រ៊ីតកម្ម**<br>អ. hybridization<br>បារ. hybridation ( f. ) | ដំណើរការបង្កាត់ពូជរវាងរុក្ខជាតិពីរឬសត្វពីរដែលមានប្រភេទដូចគ្នាឬខុសគ្នា។ |
| ១៥៧- **ឧតុនិយម/ ឧតុភូតវិទ្យា**<br>អ. meteorology<br>បារ. mètèoro-logie ( f. ) | វិទ្យាសាស្ត្រសិក្សាពីបាតុភូតបរិយាកាស ជាពិសេស ព្យាករណ៍អាកាសធាតុ។ |
| ១៥៨- **ឧស្សាហ-និស្សារណកម្ម**<br>អ. industrial extraction<br>បារ. extraction industrielle ( f. ) | ដំណើរការដកយកធាតុចេញពីវត្ថុអ្វីមួយជាលក្ខណៈឧស្សាហកម្ម។<br>ឧ. ខេត្តកោះកុង នាពេលបច្ចុប្បន្ននេះ មានឧស្សាហនិស្សារណកម្មស្ករសពីដើមអំពៅ។ |
| ១៥៩- **អេកូវិទ្យា / អេកូឡូស៊ី**<br>អ. ecology<br>បារ. écologie ( f. ) | វិទ្យាសាស្ត្រសិក្សាអំពីទំនាក់ទំនងរវាងភាវៈរស់ និងភាវៈរស់ក្នុងបរិស្ថាន។ |
| ១៦០- **អេគីណូ-កុកកូស**<br>អ. echinococco-sis / hydatidosis / hydatiddisease | ជំងឺបង្កដោយបរាសិតព្រូនសំប៉ែតស្ថិតក្នុងសន្តានតេនីអ៊ីដេ ( taeniidae ) ពួកអេគីណូកុកគូស ( echinococcus )។ ជំងឺនេះកើតចំពោះមនុស្ស ឆ្កែ ឆ្កែចចក ជ្រូក កណ្ដុរ គោ ចៀម ពពែ សេះ និង |

| | |
|---|---|
| បារ. echinococ-cose | អូដ្ឋ។ ព្រូនធំពេញវ័យរស់នៅក្នុងពោះវៀននៃឆ្កែចចុង ដោយបញ្ចេញស៊ុតតាមរយៈលាមកមកមជ្ឈដ្ឋានខាងក្រៅ។ បន្ទាប់មក ស៊ុតនេះត្រូវបានលេបចូលតាមរយៈទឹក ចំណីដោយឆ្កែលកណ្ដាល រួចញាស់ក្នុងពោះវៀនតូច ហើយ បញ្ចេញអុងកូស្វ៊ែ (oncosphère) ដែលជ្រៀតចូលតាមភ្នាសពោះវៀន បន្ទាប់មក ជ្រៀតចូលសរីរាង្គផ្សេងៗ ជាពិសេស សួត ថ្លើម និង ខួរក្បាល។ នៅទីនោះ អុងកូស្វ៊ែក្លាយជាគីស្ត។ ឆ្កែលចុងឆ្លងជំងឺដោយសារស៊ីចំណីដែលមានគីស្តទាំងនោះ។ នៅក្នុងពោះវៀន គីស្តធំលូតលាស់ហើយក្លាយជាព្រូន។ |
| ១៦១- **អេពីហ្វ៊ីត**<br>អ. epiphyte<br>បារ. épiphyte<br>(m.) | រុក្ខជាតិដែលអាស្រ័យនឹងរុក្ខជាតិដទៃទៀត តែមិនស្រូបយកសារធាតុចិញ្ចឹមពីរុក្ខជាតិនោះទេ។<br>ឧ. អ័រគីដេនិងប៉ប្រេកជាអេពីហ្វ៊ីត។ |

**បោះពុម្ពលើកទី១ ចំនួន ១ ៥00ច្បាប់**
**នៅរោងពុម្ព ស៊ី យូ**
ផ្ទះលេខ ៣៨CEo មហាវិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ